UNITED NATIONS
**HUMAN RIGHTS**
OFFICE OF THE HIGH COMMISSIONER
*Cambodia*

# ការចុះបញ្ជីដីសមូហភាពជនជាតិ ដើមភាគតិចនៅក្នុងប្រទេសកម្ពុជា តើជាករណីសម្រាប់ធ្វើកំណែទម្រង់មែនទេ ?



# មាតិកា


ពាក្យបំព្រួញ .................... ២
សេចក្តីផ្តើម .................... ៣
ផ្នែកទីI៖ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋាននានាពាក់ព័ន្ធការទទួលស្គាល់សិទ្ធិកម្មសិទ្ធិដីធ្លីប្រពៃណីរបស់ជនជាតិដើមភាគតិច .................... ១០
ផ្នែកទីII៖ ក្របខ័ណ្ឌគតិយុត្តិរបស់ប្រទេសកម្ពុជា ទាក់ទងនឹងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានដីប្រពៃណី និងធនធានរបស់ខ្លួន .................... ១៨
ផ្នែកទីIII ៖ ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅក្នុងប្រទេសកម្ពុជា៖ ការស្នើសុំសម្រួលដំណើរការចុះបញ្ជី .................... ៣០
ដំណាក់កាលទី១៖ ការទទួលស្គាល់សហគមន៍ជាជនជាតិដើមភាគតិច (ក្រសួងអភិវឌ្ឍន៍ជនបទ) .................... ៣០
ដំណាក់កាលទី២៖ ការចុះបញ្ជីជានីតិបុគ្គល (ក្រសួងមហាផ្ទៃ) .................... ៤១
ដំណាក់កាលទី២.៥៖ ការធ្វើផែនទីបឋម និងការគាក់តែងបទបញ្ជាផ្ទៃក្នុង (បច្ចុប្បន្ននេះគ្មានក្រសួងណាមួយត្រូវបានដាក់ឲ្យទទួលខុសត្រូវការងារនេះឡើយ) .................... ៥២
ដំណាក់កាលទី៣៖ ការស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) .................... ៦៥
ទិដ្ឋភាពទូទៅនៃអនុសាសន៍សំខាន់ៗរបស់ការិយាល័យ OHCHR .................... ៧១
ផ្នែកទី IV ៖បញ្ហាដែលត្រូវពិចារណា .................... ៨០
កង្វះខាតទិន្នន័យបំបែកអំពីជនជាតិដើមភាគតិច .................... ៨០
វិសាលភាពមានកម្រិតនៃការដាក់ ពាក្យស្នើសុំវិធានការការពារបណ្តោះអាសន្ន .................... ៨១
កង្វះខាតកញ្ចប់ថវិកា .................... ៨៣
ការយល់ដឹង និងសមត្ថភាពមានកម្រិតក្នុង ចំណោមជនជាតិដើមភាគតិច អង្គការមិនមែន រដ្ឋាភិបាលដែលគាំទ្រជនជាតិដើម និងអាជ្ញាធរមូលដ្ឋាន អំពីច្បាប់ភូមិបាលឆ្នាំ ២០០១ .................... ៨៤
កិច្ចសហប្រតិបត្តិការមានកម្រិតរវាងក្រសួងពាក់ព័ន្ធ .................... ៨៦
គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច .................... ៨៧
អវត្តមាននៃស្រទាប់យេនឌ័រ .................... ៩០
ឧបសម្ព័ន្ធ៖ .................... ៩១

# ពាក្យបំព្រួញ

| | |
|---|---|
| **ADIC** | Analyzing Development Issues Centre (Cambodia) |
| **CIPO** | អង្គការជនជាតិដើមភាគតិចកម្ពុជា |
| **CLT** | ប័ណ្ណកម្មសិទ្ធិដីសមូហភាព |
| **DP** | ដៃគូអភិវឌ្ឍន៍ |
| **DPA** | អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព |
| **DSA** | ប្រាក់បេសកកម្ម |
| **FAO** | អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ |
| **FLO** | អង្គការដើម្បីជីវភាពនិងព្រៃឈើ |
| **GIZ** | Deutsche Gesellschaft für Internationale Zusammenarbeit (អតីត GTZ) |
| **GPS** | ប្រព័ន្ធកំណត់និយាមការសកល |
| **HA** | សមាគមខ្មែរលើ |
| **HEKS** | HEKS/EPER Swiss Church Aid |
| **ICSO** | អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **IPC** | សហគមន៍ជនជាតិដើមភាគតិច |
| **IRAM** | បណ្តាញសមាជិកសិទ្ធិជនជាតិដើមភាគតិចសកម្ម |
| **LANGO** | ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល |
| **MRLG** | គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ |
| **NGO** | អង្គការក្រៅរដ្ឋាភិបាល |
| **NTFP-EP** | កម្មវិធីផ្លាស់ប្តូរផលិតផលអនុផលព្រៃឈើ |
| **OHCHR** | ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស |
| **PKH** | អង្គការពន្លកខ្មែរ |
| **SDG** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **UNDRIP** | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច |
| **UPR** | ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (ឬ យន្តការត្រួតពិនិត្យតាមកាលកំណត់) |
| **USD** | ដុល្លាសហរដ្ឋអាមេរិក |
| **WCS** | អង្គការសមាគមអភិរក្សសត្វព្រៃ |
| **WWF** | មូលនិធិពិភពលោកសម្រាប់ការអភិរក្សធម្មជាតិ |

# សេចក្តីផ្តើម

បច្ចុប្បន្ននេះ ជនជាតិដើមភាគតិចនៅកម្ពុជាមិនត្រូវបានកំណត់និយមន័យជាផ្លូវការនោះទេក្រៅតែពីគោលបំណងជាក់លាក់របស់ច្បាប់ភូមិបាលឆ្នាំ២០០១ដែលនៅមាត្រា២៣បានពណ៌នា ជនជាតិដើមភាគតិចថា "គឺជាក្រុមមនុស្សដែលបានបង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ ជាសមូហភាព"។ នេះបានបង្កើតឲ្យមានមូលដ្ឋានបទប្បញ្ញត្តិនៃច្បាប់ភូមិបាលសម្រាប់ភាពជាម្ចាស់សមូហភាពចំពោះអចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច។ នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងនូវបទបញ្ញាត្តិសំខាន់ៗ ជាច្រើនស្តីពីការពារដីជនជាតិដើមភាគតិច ដែលអនុញ្ញាតឲ្យពួកគេទទួលបាននូវប័ណ្ណកម្មសិទ្ធិសមូហភាព ជាជាងកម្មសិទ្ធិឯកជន នៅខណៈដែលមានការទប់ស្កាត់ពីការលក់ និងការផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិច។

ខែមេសាឆ្នាំ២០០៩ រាជរដ្ឋាភិបាលបានបន្តកំណត់បន្ថែមលើគោលនយោបាយរបស់ខ្លួនស្តីពីជនជាតិដើមភាគតិច និងបានអនុម័តអនុក្រឹត្យស្តីពីការចុះបញ្ជីដីជនជាតិដើមភាគតិច ដែលបានលម្អិតពីនីតិវិធីដែលជាតំរូវការសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីជនជាតិដើមភាគតិចដោយរួមទាំងពីជំហានសម្រាប់កំណត់ព្រំប្រទល់ ការវិនិច្ឆ័យ និងការផ្សព្វផ្សាយជាសាធារណៈ។

ទោះជាយ៉ាងណា ដំណើរការចុះបញ្ជីដីសមូហភាពដែលបង្កើតឡើងដោយអនុក្រឹត្យគឺមានភាពសាំញ៉ាំ និងត្រូវអនុវត្តនូវបីដំណាក់កាល៖ ទីមួយ៖ សហគមន៍ត្រូវ កំណត់អត្តសញ្ញាណដោយក្រសួងអភិវឌ្ឍន៍ជនបទថាជា "សហគមន៍ជនជាតិដើមភាគតិច" (និងត្រូវមានលក្ខន្តិកៈបង្ហាញថាពួកគេជាសហគមន៍)។

ទីពីរ៖ពួកគេត្រូវចុះបញ្ជីជានីតិបុគ្គលជាមួយក្រសួងមហាផ្ទៃ មិនដាក់ពាក្យសុំចុះបញ្ជីដី។ ទីបី៖ ពួកគេត្រូវដាក់ពាក្យសុំចុះបញ្ជីដីធ្លីសហគមន៍របស់ពួកគេជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

មានការបារម្ភថា ដំណើរការអនុវត្តគឺស្មុគស្មាញពេក ចំណាយច្រើន យឺតយ៉ាវ និងមានការលំបាកក្នុងការធានាការពារសុវត្ថិភាពដីធ្លីជនជាតិដើមភាគតិចជាពិសេសក្នុងបរិបទដែលដីធ្លីត្រូវបានលក់ឬជួលយ៉ាងងាយ ហើយជាញឹកញយនីតិវិធីការពារ និងច្បាប់ជាតិមិនត្រូវបានគោរពតាម។

រាជរដ្ឋាភិបាលកម្ពុជា បានសន្យាជាសាធារណៈថានឹងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពយ៉ាងតិចដប់សហគមន៍ក្នុងមួយឆ្នាំ។ទោះជាយ៉ាងណា នៅខែកក្កដា ឆ្នាំ ២០១៨ កញ្ចប់ថវិការដ្ឋសម្រាប់ការចុះបញ្ជីដីសមូហភាពត្រូវបានកាត់បន្ថយពាក់កណ្តាល មានន័យថាមានតែសហគមន៍ចំនួនប្រាំតែប៉ុណ្ណោះដែលអាចទទួលបាន ប័ណ្ណកម្មសិទ្ធិសមូហភាពក្នុងមួយឆ្នាំៗ។ គិតត្រឹមឆ្នាំ ២០២០ ក្រសួងអភិវឌ្ឍន៍ជនបទបានវិភាជកញ្ចប់ថវិកាចុះបញ្ជីដីសមូហភាពសម្រាប់តែបីសហគមន៍ប៉ុណ្ណោះក្នុងមួយឆ្នាំ[១]។ ជាងនេះទៅទៀត សហគមន៍ជនជាតិដើមភាគតិចត្រូវពឹងផ្អែកលើជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ភ្នាក់ងារសហប្រជាជាតិ និងអង្គការសង្គមស៊ីវិលដើម្បីរៀបចំនិងដាក់ពាក្យស្នើសុំចុះបញ្ជីរបស់ពួកគេ។

ត្រឹមខែកញ្ញា ឆ្នាំ ២០២០ មាន១៥៤ សហគមន៍ត្រូវបានទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទជាសហគមន៍ជនជាតិដើមភាគតិច(ដំណាក់កាលទី១)។ ក្រសួងមហាផ្ទៃបានអនុម័ត និងបានចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចចំនួន១៥០ជា "នីតិបុគ្គល" តាមរយៈដំណើរការរៀបចំជាផ្លូវការនូវលក្ខន្តិកៈសហគមន៍របស់ពួកគេ (ដំណាក់ទី២)។ និង ៣០សហគមន៍បានទទួលនូវប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (ដំណាក់កាលទី៣)។

ប្រសិនបើ មធ្យមភាគនៃការកំណត់អត្តសញ្ញាណប្រចាំឆ្នាំបច្ចុប្បន្ននៅតែបន្ត អាចត្រូវការពេលប្រហែលជា១០០ឆ្នាំទៀតទើបអាច

---

១ យោងតាមកិច្ចប្រជុំរវាងការិយាល័យOHCHRជាមួយនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទកាលពីថ្ងៃទី ០៨ កញ្ញា ឆ្នាំ ២០២០

បញ្ចប់ ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាចំនួន ៣០៤ សហគមន៍ដែលនៅសេសសល់ ឬ មិនទាន់បានចាប់ផ្តើមដំណើរការស្វ័យអត្តសញ្ញាណជាជនជាតិដើមភាគតិច។ សូមចងចាំថា គ្មានស្ថិតិជាក់លាក់អំពីចំនួនសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាទេ បើទោះបីជាបានពិនិត្យឃើញជាទូទៅថាមានសហគមន៍ជនជាតិដើមភាគតិចចំនួន៤៥៥ក្តី ហើយដែលថាកញ្ចប់ថវិកាសម្រាប់ការចុះបញ្ជីក៏អាចត្រូវបានកាត់បន្ថយដោយសារផលប៉ះពាល់សេដ្ឋកិច្ចទៅលើកញ្ចប់ថវិកាជាតិដែលបណ្តាលមកពីការរាតត្បាតនៃមេរោគ Covid-១៩ ច្រើនជាងនេះទៅទៀត។ ដូច្នេះ kar សន្និដ្ឋានថា ១០០ឆ្នាំទៀត គឺអាចនឹងកើតកើនឡើងផងដែរ។

នៅក្នុងអំឡុងពេលបួនឆ្នាំចុងក្រោយនេះ ការិយាល័យ OHCHR បានសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បង្កើតសៀវភៅណែនាំការចុះបញ្ជីដីសម្ភូហភាពសម្រាប់អាជ្ញាធរមូលដ្ឋាន[២] និងបានរៀបចំវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ជាច្រើនស្តីពីដំណើរការចុះបញ្ជីដីសម្ភូហភាពដល់តំណាងអាជ្ញាធរមូលដ្ឋានជាង ៣០០នាក់។ ការិយាល័យក៏បានអមដំណើរមន្ត្រីក្រសួង និងអាជ្ញាធរមូលដ្ឋានទៅកាន់សហគមន៍ ជនជាតិដើមភាគតិចជាងម្ភៃសហគមន៍ដើម្បីដំណើរការដំណាក់កាលទីមួយ ទីពីរ និងទីបីនៃដំណើរការចុះបញ្ជីដីសម្ភូហភាពជនជាតិដើមភាគតិច។

ការិយាល័យ OHCHR បានទទួលបទពិសោធន៍ស្តីពីការងារនេះ ដែលទាមទារអោយមានការកែសម្រួលនីតិវិធី ចុះបញ្ជីដីសម្ភូហភាពជាបន្ទាន់។ ការិយាល័យ OHCHR បានសំរេចចិត្តបង្កើតឯកសារពិគ្រោះយោបល់ស្តីពីការកែទម្រង់នីតិវិធីចុះបញ្ជីដីសម្ភូហភាពដោយមានអនុសាសន៍សម្រាប់ការកែសម្រួលដល់បទប្បញ្ញត្តិច្បាប់បច្ចុប្បន្នដែលគ្របដណ្តប់លើការចុះបញ្ជីដី សម្ភូហភាព។ វាឆ្លុះបញ្ចាំងការវាយតម្លៃរបស់ការិយាល័យ OHCHR ទៅលើការអនុវត្តនីតិវិធីចុះបញ្ជីដីសម្ភូហភាពដែល

២ សៀវភៅណែនាំស្តីពី ដំណើរការនៃការកំណត់អត្តសញ្ញាណ ការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្ភូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។ សហការផលិតដោយការិយាល័យOHCHR ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅខែមករា ឆ្នាំ២០១៩។ អាចរកអានបាននៅ៖ https://cambodia.ohchr.org/sites/default/files/Promotional-materials-soft/CLT%២0Manual-Khmer.pdf

បានបង្កើតឡើងតាំងពីឆ្នាំ ២០០៩ ដោយរាជរដ្ឋាភិបាលកម្ពុជា និងបានកំណត់នូវបញ្ហាប្រឈមនានា ក៏ដូចជាមេរៀនល្អៗផងដែរ។

ឯកសារនេះត្រូវបានរៀបរៀងជាបួនផ្នែក ដែលរួមមាន ៖

**ផ្នែកទីI** រៀបរាប់អំពីទិដ្ឋភាពរួមស្តីពីសិទ្ធិកាន់កាប់កម្មសិទ្ធិដីធ្លីប្រពៃណី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការពារ និងទទួលស្គាល់សិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិចជាអន្តរជាតិ។ ផ្នែកនេះបានកត់សម្គាល់ទៅលើកាតព្វកិច្ចរបស់រដ្ឋ ក្នុងការទទួលស្គាល់ និងគាំពារសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបានដីប្រពៃណី និងធនធានរបស់ដូចដែលបានរៀបរាបពីកំរិតជាក់លាក់មួយចំនួនតាមរយៈយន្តការសិទ្ធិមនុស្សអន្តរជាតិ ហើយផ្នែកនេះក៏បានលើកឡើងនូវសមាសធាតុចម្បងៗមួយចំនួនដែលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គួរដាក់បញ្ចូលដើម្បីឲ្យដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិគួរជាទីពេញចិត្ត។ ក្រៅពីនេះផ្នែកទី១ នេះក៏ពិចារណាទៅលើការធ្វើច្បាប់នៅក្នុងកម្រិតអន្តរជាតិដើម្បីគាំទ្រឲ្យមានវិសាលភាពកាន់តែទូលំទូលាយក្នុងការអនុវត្តការទទួលស្គាល់ដីសមូហភាពដោយមិនបញ្ចូលត្រឹមតែជនជាតិដើមភាគតិចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រុមជនជាតិទាំងអស់ដែលកាន់កាប់កម្មសិទ្ធិដីធ្លីជាលក្ខណៈប្រពៃណីរបស់ពួកគេផងដែរ។

**ផ្នែកទីII** ពិពណ៌នាអំពីកាតព្វកិច្ចតាមផ្លូវច្បាប់អន្តរជាតិរបស់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាតិដើមភាគតិច ជាពិសេសសិទ្ធិរបស់ពួកគេក្នុងការទទួលបានដីធ្លី និងធនធានធម្មជាតិ។

**ផ្នែកទីIII** បកស្រាយអំពីការគាំទ្រដ៏រឹងមាំចំពោះ ឯកសារពិគ្រោះយោបល់នេះ ដែលបែងចែកនូវដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពដោយស្នើឡើងនូវវិធីសាស្ត្រមួយចំនួនដែលអាចអនុវត្តបានសម្រាប់ដំណាក់កាលនីមួយៗ ដើម្បីធ្វើឲ្យកាន់តែងាយស្រួលនូវដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ផ្នែកនេះប្រើប្រាស់នូវការវិភាគប្រៀបធៀបដែលមាននៅក្នុងមេរៀនដែលទទួលបានពីបណ្តាប្រទេសដទៃទៀតដែលទទួលស្គាល់តាមផ្លូវច្បាប់នូវ

សិទ្ធិដីធ្លីព្រៃឈើរបស់ជនជាតិដើមភាគតិច និង/ឬរបស់សហគមន៍មូលដ្ឋាន រួចហើយ បង្កើតនូវដំណើរការតាមគោលដៅដែលចង់បាននោះ។ នៅចុងបញ្ចប់នៃផ្នែកនេះ ក៏មានការផ្តល់ជាតារាងអនុសាសន៍ និងសេចក្តីកែសម្រួលដែលតម្រូវទៅលើក្របខ័ណ្ឌគតិយុត្តិផងដែរ (ប្រសិនបើមានការកែសម្រួលមែននោះ)។

**ផ្នែកទីIV** ពិភាក្សាអំពីបញ្ហាប្រឈមខាងសិទ្ធិមនុស្សផ្សេងៗ ដែលជនជាតិដើមភាគតិចកំពុងតែជួបប្រទះនៅក្នុងប្រទេសកម្ពុជា រួមមានវិសាលភាពមានកម្រិតនៃវិធានការការពារបណ្តោះអាសន្ន ការកំណត់ផ្ទៃដីត្រឹមតែទំហំប្រាំពីរហិកតា ប៉ុណ្ណោះសម្រាប់កម្មសិទ្ធិដីធ្លីព្រៃអារក្ស និងដីកប់សព កង្វះថវិកាសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងក្រសួងពាក់ព័ន្ធសំខាន់ៗ ដើម្បីអាចចូលរួមដោយប្រសិទ្ធភាពនៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព កម្រិតនៃការយល់ដឹងក្នុងចំណោមអាជ្ញាធរមូលដ្ឋានទៅលើបញ្ហាជនជាតិដើមភាគតិច និងច្បាប់ជាតិដែលពាក់ព័ន្ធចំនួន ការកំណត់ពីគោលនយោបាយជាតិហើយ និងភាពអវត្តមាននៃសមភាពយេនឌ័រដ៏ច្រើន នៅពេលដែលនិយាយទៅដល់ការផ្តល់សិទ្ធិអំណាចដល់ស្រ្តី។ ផ្នែកទីIVនេះ ក៏ពិចារណាផងដែរទៅលើគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអភិវឌ្ឍសហគមន៍ជនជាតិដើមភាគតិច ព្រមទាំងលើកឡើងនូវវិធានការមួយចំនួន ដែលចាត់ឡើង ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព។

ឯកសារពិគ្រោះយោបល់នេះ ត្រូវបានរៀបចំឡើង អនុលោមតាមអាណត្តិរបស់ការិយាល័យ OHCHR នៅកម្ពុជាក្នុងការផ្តល់ការគាំទ្រដល់ការបង្កើតច្បាប់ និងក្របខណ្ឌស្ថាប័នដែលការពារសិទ្ធិមនុស្សស្របតាមវិធាន និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងកាតព្វកិច្ចសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ វាជាលទ្ធផលកើតចេញពីកិច្ចពិគ្រោះយោបល់ យ៉ាងទូលំទូលាយក្នុងអំឡុងឆ្នាំ២០១៧ ដល់ឆ្នាំ ២០២០ ជាមួយក្រសួងពាក់ព័ន្ធ និងអង្គការសង្គម

ស៊ីវិលដែលធ្វើការពាក់ព័ន្ធដំណើរការចុះបញ្ជីដីសម្ូហភាព។[៣]

ការិយាល័យ OHCHR ជឿជាក់ថា ការអង្កេត និងការផ្ដល់អនុសាសន៍សម្រាប់ការកែទម្រង់ ដែលបានលើកឡើងក្នុងឯកសារពិគ្រោះយោបល់នេះ អាចមានសារប្រយោជន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដោយសារវាបានបញ្ចូលនូវវិធានការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិពាក់ព័ន្ធជនជាតិដើមភាគតិច ជាពិសេសការអនុម័តសេចក្ដីថ្លែងការណ៍អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងគោលការណ៍នៃការមិនទុកនរណាម្នាក់ចោល និងការសន្យាប្ដេជ្ញារបស់ខ្លួនចំពោះយន្តការត្រួតពិនិត្យតាមកាលកំណត់ (UPR) ពាក់ព័ន្ធនឹងការពង្រឹង

៣ ឯកសារពិគ្រោះយោបល់នេះត្រូវបានផ្ដួចផ្ដើមនៅឆ្នាំ២០១៧។បន្ទាប់ពីមានកិច្ចពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយតំណាងក្រសួងសំខាន់ៗចំនួនបីរួមមាន៖ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាងនេះទៅទៀត ការិយាល័យOHCHR បានទទួលធាតុចូលពីភាគីពាក់ព័ន្ធថ្នាក់ជាតិ និងអន្តរជាតិដែលធ្វើការជាមួយជនជាតិដើមភាគតិចនៅកម្ពុជា រួមមានអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (ICSO) អង្គការជនជាតិដើមភាគតិចកម្ពុជា (CIPO) អង្គការពន្លកខ្មែរ (PKH) អង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) សមាគមខ្មែរលើ (HA) គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ (MRLG) អង្គការដើម្បីជីវភាពនិងព្រៃឈើ (FLO) មូលនិធិពិភពលោកសម្រាប់ការអភិរក្សធម្មជាតិ (WWF) បណ្ដាញសមាជិកសិទ្ធិជនជាតិដើមភាគតិចសកម្ម (IRAM) ធនាគារពិភពលោក (WB) អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ (FAO)។នៅខែមករា ឆ្នាំ២០១៧ ការិយាល័យOHCHRបានធ្វើការស្ទង់មតិដើម្បីទទួលធាតុចូលកាន់តែទូលំទូលាយពីអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (ទាំងជាភាសាខ្មែរ និងអង់គ្លេស)។ ការឆ្លើយតបរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងក្នុងឯកសារពិគ្រោះយោបល់នេះ។បន្ទាប់ពីនោះកាលពីខែឧសភាឆ្នាំ២០១៨ការិយាល័យ OHCHR បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន ដែលសុទ្ធសឹងតែជាក្រសួងដែលបានផ្ដល់នូវ អនុសាសន៍ដល់ឯកសារពិគ្រោះយោបល់នេះ។ ទន្ទឹមគ្នានេះ យើងក៏បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដាច់ដោយឡែកជាមួយអង្គការសង្គមស៊ីវិលមួយចំនួនមានដូចជាអង្គការ DPA, NGO Forum, CIPO, IRAM, HA, ICSO, FLO, WWF, និង PKH នៅខែឧសភា ឆ្នាំ ២០១៨ ដូចគ្នា។ ការិយាល័យ OHCHR បានបន្តកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល។ នៅថ្ងៃទី ១៦ មេសា ២០២០ ការិយាល័យOHCHR បានស្នើសុំអនុសាសន៍ផ្លូវការចំពោះសេចក្ដីព្រាងចុងក្រោយពីក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គការសង្គមស៊ីវិលដែលធ្វើការទៅលើបញ្ហាជនជាតិដើមភាគតិច អង្គការពលកម្មអន្តរជាតិ និងធនាគារពិភពលោក។ ដោយមូលហេតុការរាតត្បាតនៃមេរោគកូរ៉ូណា (COVID -១៩) កិច្ចប្រជុំពិគ្រោះយោបល់តាមអនឡាញត្រូវបានរៀបចំជាមួយអង្គការ WWF, FLO,NGO Forum, ICSO, HEKS, CIPA, WCS និងអង្គការ NTFP-EP។ ឯកសារពិគ្រោះយោបល់នេះត្រូវបានដាក់នៅក្នុងប្រអប់ទិន្នន័យសាធារណៈរបស់បណ្ដាញអង្គការជនជាតិដើមភាគតិច និងព្រៃឈើដើម្បីធ្វើការផ្ដល់អនុសាសន៍បន្តរហូតដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០។ មុនការបញ្ចប់សេចក្ដីព្រាងឯកសារពិគ្រោះយោបល់ និងធ្វើការបោះពុម្ពផ្សាយ ការិយាល័យOHCHRបានរៀបចំកិច្ចប្រជុំចុងក្រោយជាមួយនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយរបស់ក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០ និងជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ វេទិកាអង្គការក្រៅរដ្ឋាភិបាលស្ដីពីកម្ពុជា (NGO Forum) និងមជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍នៅកម្ពុជា (ADIC)នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២០។

ក្របខណ្ឌច្បាប់ដែលស្របទៅតាមបទដ្ឋានអន្តរជាតិនានា។ ការិយាល័យ OHCHR រំពឹងថា ឯកសារពិគ្រោះយោបល់នេះ នឹងត្រូវបានបន្តដោយកិច្ចប្រជុំជាន់ខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបង្រួបបង្រួមការគាំទ្ររបស់ពួកគេចំពោះកំណែទម្រង់ការចុះបញ្ជីដីសម្ហភាព។

# ផ្នែកទី៛



# បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងបទដ្ឋាននានាពាក់ព័ន្ធការទទួលស្គាល់សិទ្ធិកម្មសិទ្ធិដីធ្លីព្រៃឈើរបស់ជនជាតិដើមភាគតិច

សម្រាប់ ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា[៤] ក៏ដូចជានៅតំបន់ផ្សេងទៀតដែរ ការធានានូវសិទ្ធិទទួលបានដីធ្លី និងទទួលបានធនធានរបស់ខ្លួន គឺជា*លក្ខខណ្ឌដែលមិនអាចខ្វះបាន*សម្រាប់សុខុមាលភាពរយៈពេលវែង និងជាបុរេលក្ខខណ្ឌសម្រាប់ពួកគេ ដើម្បីអាចបន្តវត្តមាន ជាជនជាតិមួយដែលមានអត្តសញ្ញាណដោយឡែករបស់ខ្លួន។ សិទ្ធិទទួលបានដីធ្លី និងធនធាន គឺជាសិទ្ធិមួយក្នុងចំណោម សិទ្ធិមនុស្សមូលដ្ឋានបំផុតសម្រាប់ជនជាតិដើមភាគតិច រួមទាំងស្ត្រីជនជាតិដើមភាគតិច[៥] និងជាអាទិភាពចម្បងសម្រាប់ការទទួលស្គាល់ជាអន្តរជាតិនូវសិទ្ធិរបស់ជនជាតដើម។ វាក៏ជាជំហានឆ្ពោះទៅរកសមិទ្ធិផល នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ១ ស្តីពីការបញ្ចប់ភាពក្រីក្រតាមរយៈការធានាឲ្យទទួលបានសិទ្ធិកម្មសិទ្ធិ និងការគ្រប់គ្រងលើដីដោយសមភាព និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពលេខ២ ស្តីពីការបញ្ចប់ភាពអត់ឃ្លាន និងការសម្រេចបាននូវសន្តិសុខស្បៀងអាហារតាមរយៈការផ្តល់សុវត្ថិភាព ទទួលបានសិទ្ធិលើដីធ្លីដោយសមភាព ជាពិសេសសម្រាប់ស្ត្រី និងជនជាតិដើមភាគតិច។ ការកាន់កាប់ដីធ្លី និងធនធាននានារយៈពេលវែងរបស់ជនជាតិ

៤ ជាភាសាខ្មែរ ក្រុមដែលត្រូវបានកំណត់ថាជាជនជាតិដើមភាគតិច និង/ឬត្រូវបានចាត់ទុកថាដូច្នេះគឺចេញពីពាក្យថា ជនជាតិដើមភាគតិច ដែលពាក្យ “ដើម”ត្រូវបានប្រើប្រាស់សម្រាប់បែងចែកពួកគេចេញពីជនជាតិភាគតិចដទៃទៀតដូចជា ចាម ចិន និងវៀតណាមជាដើម។ ការបកប្រែច្បាប់ និងគោលនយោបាយពាក់ព័ន្ធជនជាតិដើមភាគតិចជាភាសាអង់គ្លេស ត្រូវបានប្រើប្រាស់ពាក្យ “សហគមន៍ជនជាតិដើមភាគតិច”។ ដើម្បីឲ្យមានភាពស៊ីសង្វាក់ជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ឯកសារពិគ្រោះយោបល់នេះប្រើប្រាស់ពាក្យ “ជនជាតិដើមភាគតិច” សំដៅទៅលើជនជាតិដើមភាគតិចនៅក្នុងប្រទេសនេះ។

៥ សម្រាប់ព័ត៌មានបន្ថែមស្តីពីផលប៉ះពាល់វិសមាមាត្រនៃការរឹបអូសដីចំពោះស្ត្រីជនជាតិដើមភាគតិចកម្ពុជា។ សូមមើលរបាយការណ៍ផលប៉ះពាល់នៃការរឹបអូសដីចំពោះស្ត្រីជនជាតិដើមភាគតិច Asia Indigenous Peoples Pact, ២០១៥.

ដើមភាគតិច គឺជាមូលដ្ឋានសម្រាប់ផ្ដល់សិទ្ធិជាម្ចាស់កម្មសិទ្ធិស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋមានកាតព្វកិច្ចក្នុងការគោរព និងគាំពារ។

កាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការគោរព ការពារ និងបំពេញនូវសិទ្ធិរបស់ជនជាតិកើតចេញពីសន្ធិសញ្ញាអន្តរជាតិមួយចំនួនដែលខ្លួនជារដ្ឋភាគី។រួមមានកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[៦] កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR)[៧] និងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)[៨]។ នៅខែធ្នូ ឆ្នាំ ២០១៩ គណៈកម្មការស្តីពី ការលុបបំបាត់ការរើសអើងពូជសាសន៍ដែលតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃ

៦ ពាក់ព័ន្ធនឹងមាត្រា២៧(សិទ្ធិរបស់ជនជាតិភាគតិច)ដែលមាននៅក្នុងICCPRគណៈកម្មការសិទ្ធិមនុស្សបានថ្លែងថា“វប្បធម៌នោះបង្ហាញនូវអត្តសញ្ញាណរបស់ខ្លួនវាក្នុងទម្រង់ជាច្រើន រួមមានដូចជារបៀបរបបនៃការរស់នៅជាក់លាក់របស់ជនជាតិណាមួយដែលពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ធនធានដីធ្លី ជាពិសេសសម្រាប់ករណីជនជាតិដើមភាគតិច [...] ការទទួលបាននូវសិទ្ធិទាំងនោះនឹងតម្រូវឲ្យមានវិធានការតាមផ្លូវច្បាប់ជាវិជ្ជមានសម្រាប់ការការពារ និងធានានូវការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សមាជិកសហគមន៍ជនជាតិភាគតិច នៅក្នុងការធ្វើសេចក្តីសម្រេចទាំងឡាយណា ដែលប៉ះពាល់ដល់ពួកគាត់។” មតិយោបល់ទូទៅរបស់ CCPR លេខ ២៣ ៖ មាត្រា ២៧ (សិទ្ធិរបស់ជនជាតិភាគតិច) CCPR/C/២១/កំណែទី ១/បន្ថែម ៥, កថាខណ្ឌទី៧ (១៩៩៤) មាត្រា ១ នៃកតិកាសញ្ញានេះក៏ពាក់ព័ន្ធផងដែរ ដោយបានចែងថា “រាល់ជនជាតិទាំងអស់មានសិទ្ធិក្នុងការកំណត់នូវជោគវាសនារបស់ខ្លួន។ តាមរយៈនៃសិទ្ធិនោះ ជនជាតិភាគតិចទាំងនោះអាចកំណត់នូវស្ថានភាពនយោបាយរបស់ពួកគាត់ដោយសេរី និងអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ពួកគាត់ដោយសេរីផងដែរ។”

៧ គណៈកម្មការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌តាមរយៈមតិយោបល់ទូទៅរបស់ខ្លួនលេខ២១ស្តីពីសិទ្ធិរបស់ពលរដ្ឋគ្រប់រូបនៅក្នុងការចូលរួមក្នុងជីវិតតាមវប្បធម៌របស់ខ្លួន បានកត់សម្គាល់ថា “ភាពរស់រវើករឹងមាំនៅក្នុងសហគមន៍នូវជីវិតតាមវប្បធម៌របស់ជនជាតិដើមភាគតិចគឺមិនអាចខ្វះបានឡើយសម្រាប់ការរស់រាន សុខុមាលភាព និងការអភិវឌ្ឍពេញលេញសម្រាប់ពួកគាត់ និងត្រូវដាក់បញ្ចូលនូវសិទ្ធិទទួលបានដីធ្លី ដែនដី និងធនធានរបស់ពួកគាត់ដែលពួកគាត់ធ្វើជាម្ចាស់ ឬបានកាន់កាប់តាំងពីដើម ឬក៏បានប្រើប្រាស់ ឬបានទទួល” (UN Doc E/C.១២/GC/២១)។ គណៈកម្មការនេះ យោងតាមការត្រួតពិនិត្យរបស់ខ្លួនទៅលើការអនុវត្តកាតព្វកិច្ចរបស់រដ្ឋជាភាគីចំពោះ កតិកាសញ្ញា ICESCR បានលើកឡើងជារួមនូវបញ្ហាទាក់ទងនឹងសិទ្ធិរបស់ជនជាតិដើមភាគតិច និងការទទួលបានដី ហើយក៏បានធ្វើដូច្នេះដែរនៅក្នុងការត្រួតពិនិត្យរបស់ខ្លួនចំពោះប្រទេសកម្ពុជា។

៨ ការបកស្រាយកាតព្វកិច្ចរបស់រដ្ឋនៅក្រោមអនុសញ្ញា គណៈកម្មការទទួលបន្ទុកលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍បានអំពាវនាវដល់រដ្ឋឲ្យ “ទទួលស្គាល់ និងការពារសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិ អភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ដីសហគមន៍ ដែនដី និងធនធានរបស់ពួកគាត់ ហើយនៅក្នុងករណីដែលពួកគាត់ត្រូវបានគេដកហូតយកនូវដីធ្លី និងដែនដីពួកគាត់ដែលធ្លាប់បានកាន់កាប់តាំងពីដើម ឬបានមករស់នៅ ឬបានប្រើប្រាស់ ដោយគ្មានការយល់ព្រមដោយសេរី និងទទួលបានព័ត៌មានគ្រប់គ្រាន់ នោះត្រូវចាត់វិធានការ ប្រគល់ដីធ្លី និងដែនដីទាំងនោះមកឲ្យពួកគាត់វិញ។ ស្ថិតនៅក្រោមហេតុផលជាក់ស្តែងដែលមិនអាចអនុវត្តបានតែប៉ុណ្ណោះ ដែលសិទ្ធិក្នុងការទទួលបានធ្វើបដិទាន (ការប្រគល់ឲ្យមកវិញ) នឹងត្រូវជំនួសដោយសិទ្ធិទទួលបានសំណងសមរម្យ យុត្តិធម៌ និងទាន់ពេលវេលា។ សំណងនេះត្រូវសងឲ្យបានច្រើនបំផុតឲ្យប្រហាក់ប្រហែលស្មើនឹងតម្លៃដីធ្លី និងដែនដីដែលបានយកទៅ។” អនុសាសន៍ទូទៅស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចលេខ A/៥២/១៨, ឧបសម្ព័ន្ធ V កថាខណ្ឌ ៥ (១៩៩៧)។

ការរើសអើងពូជសាសន៍ (ICERD) បានសម្តែងនូវការព្រួយបារម្ភថា "ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពបច្ចុប្បន្ន គឺមានសភាពវែងអន្លាយ និងការិយាធិបតេយ្យពេក (...) មានការទប់ស្កាត់ក្រុមជនជាតិដើមភាគតិចមួយចំនួនពីការទទួលបានការចុះបញ្ជីកម្មសិទ្ធិដីសមូហភាពរបស់ពួកគេប្រកបដោយប្រសិទ្ធភាព"។[៩] គណៈកម្មាធិការនេះ បានផ្តល់អនុសាសន៍ដល់កម្ពុជា "កែសម្រួលដំណើរការចុះបញ្ជីដីធ្លីដើម្បីអនុញ្ញាតអោយជនជាតិដើមភាគតិចអាចទទួលបានផលប្រយោជន៍ពីការទទួលស្គាល់ និងការទាមទារដីធ្លីរបស់ពួកគេ។ (និង) ពន្លឿនការដោះស្រាយវិវាទដីធ្លី និងចាត់វិធានការការពារការបាត់បង់ទីលំនៅ និងគ្មានលំនៅឋានរបស់ជនជាតិដើមភាគតិច។[១០]

នៅក្នុងរបាយការណ៍ខែកញ្ញាឆ្នាំ២០១៩ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាបានបង្ហាញក្តីបារម្ភរបស់គាត់ថា "ការចុះបញ្ជីដីធ្លី គឺនៅតែជាបញ្ហា។ ដើម្បីអាចធានាដំណើរការចុះបញ្ជីដីសមូហភាពនៅកម្ពុជាបាន ដំណើរការនៅមានភាពយឺតយ៉ាវ និងរញ៉េរញ៉ៃ និងស្មុគស្មាញ។ ខណៈដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងមានវឌ្ឍនភាពលើការធ្វើផែនការប្រកបដោយមហិតារបស់ខ្លួន ដើម្បីដោះស្រាយវិវាទការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីឲ្យបានរួចរាល់ នៅឆ្នាំ២០២៣ នោះក៏មានភស្តុតាងបង្ហាញថាជនជាតិដើមភាគតិចត្រូវបានបំភ្លេចចោល"។[១១]

នៅខែមករា ឆ្នាំ ២០១៩ កម្ពុជាបានឆ្លងកាត់យន្តការត្រួតពិនិត្យតាមកាលកំណត់ (UPR)របស់ខ្លួន។ អនុសាសន៍ចំនួនពីរដែលទទួលយកដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសផ្តោតទៅលើតម្រូវការកែសម្រួលប្រព័ន្ធចុះបញ្ជីដីសម្រាប់ជនជាតិដើមភាគតិចដែលមានស្រាប់។[១២]

៩ CERD/C/KHM/CO/១៤-១៧, វគ្គខ័ណ្ឌ ២៧ (e).

១០ CERD/C/KHM/CO/១៤-១៧, វគ្គខ័ណ្ឌ ២៨ (e) (f).

១១ របាយការណ៍អ្នករាយការពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ការវាយតម្លៃកិច្ចការពារជនដែលប្រឈមនឹងការបំភ្លេចចោល។ ក្រុមប្រឹក្សាសិទ្ធិមនុស្ស កិច្ចប្រជុំលើកទី ៤២ ថ្ងៃទី ៩-២៧ កញ្ញា ២០១៩ (របៀបវារៈ ១០, វគ្គខណ្ឌ ៤៤). A/HRC/៤២/៦០/Ad.១

១២ "ចាត់វិធានការកែសម្រួលការផ្តល់សម្បទានដីសហគមន៍ដល់ជនជាតិដើមភាគតិច"។ និង"អនុវត្តគោលនយោបាយតាំងលំនៅថ្មីដែលផ្សាភ្ជាប់ និងការកែសម្រួលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ការពិគ្រោះយោបល់ជាមួយសហគមន៍ អង្គការសង្គមស៊ីវិល និងក្រុមជនជាតិដើមភាគតិច"។ A/HRC/៤១/១៧, ៥ April ២០១៩, paragraphs ១១០.២១, ១១០.២២.

កម្ពុជាក៏ជារដ្ឋភាគីនៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិឆ្នាំ១៩៥៨(លេខ១១១)ស្តីពីការរើសអើង (ការងារនិងមុខរបរ) ដែលផ្តល់នូវសិទ្ធិស្មើគ្នា ដល់សហគមន៍ជនជាតិដើមភាគតិចក្នុងការទទួលបានការងារ និងមុខរបរ ព្រមទាំងមុខរបរប្រពៃណីផងដែរ។[១៣] នៅក្នុងបរិបទនេះ គណៈកម្មាធិការជំនាញរបស់អង្គការពលកម្មអន្តរជាតិស្តីពីការអនុវត្តអនុសញ្ញា និងអនុសាសន៍ (CEACR) នៅក្នុងអនុសាសន៍ថ្មីៗ នេះដែលបានដាក់ជូនកម្ពុជា បានបញ្ជាក់ពីសារសំខាន់នៃការធានាបាននូវសិទ្ធិទទួលបានដីធ្លីនិងធនធានធម្មជាតិដល់ជនជាតិដើមភាគតិចសម្រាប់ការប្រើប្រាស់កាន់កាប់ជាប្រពៃណីរបស់ពួកគេ។ ដោយសំខាន់ជាងនេះទៀត គឺ CEACR បានស្នើរដ្ឋាភិបាលឲ្យជម្រាបជូននូវវិធានការអនុវត្តដើម្បីធានាថាជនជាតិដើមភាគតិចទទួលបានដីធ្លី និងធនធានធម្មជាតិដទៃទៀត ដោយពុំមានការរើសអើង និង "វិធានការអនុវត្តដើម្បីលើកកម្ពស់កិច្ចការពារសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច"[១៤]

គួរកត់សម្គាល់ថា ប្រទេសកម្ពុជាបានបោះឆ្នោតគាំទ្រការអនុម័តនូវសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ(UNDRIP)[១៥]។ UNDRIP នេះបានសង្ខេប និងបកស្រាយយ៉ាងលម្អិតអំពីបទដ្ឋានអន្តរជាតិ ដែលទទួលស្គាល់យ៉ាងទូលំទូលាយ អំពីខ្លឹមសារអប្បបរិមានៃសិទ្ធិរបស់ជនជាតិដើមភាគតិច។ បើទោះបីជា UNDRIP នេះមិនមែនជាកាតព្វកិច្ចតាមផ្លូវច្បាប់ក៏ដោយវា គឺជាការប្តេជ្ញាចិត្តដែលទទួលយកដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ - រួមទាំងកម្ពុជាផង - ដើម្បីលើកកម្ពស់ និងគោរពសិទ្ធិមនុស្សរួមទាំងបទដ្ឋានស្តីពីជនចាស់ជរា ស្ត្រី យុវជន កុមារ និងជនពិការ នៅក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិ ច្បាប់អន្តរជាតិតាមបែបប្រពៃណី និងសន្ធិសញ្ញាសិទ្ធិមនុស្សពហុភាគី ដែលប្រទេសកម្ពុជា ក៏ជាភាគីមួយដែរ។[១៦]

UNDRIP នេះចែងអំពីការទទួលស្គាល់យ៉ាងទូលំទូលាយនូវសិទ្ធិបុគ្គល និងសិទ្ធិ

---

១៣ សូមមើល សេចក្តីណែនាំចំពោះអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១១១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងជនជាតិដើមភាគតិចនិងកុលសម្ព័ន្ធក្នុងវិស័យការងារនិងមុខរបរ។, Eliminating discrimination against Indigenous and Tribal peoples in employment and occupation – A guide to ILO Convention no. ១១១

១៤ CEACR, Direct Request, សំណើរផ្ទាល់, ២០១៦.

១៥ A/៦១/២៩៥។ https://www.un.org/esa/socdev/unpfii/documents/DRIPS_en.pdf

១៦ សូមមើលជាទូទៅ A/HRC/២១/៤៧/add.១, កថាខណ្ឌ ៧៩ ដល់ ៨៤។

សមូហភាពរបស់ជនជាតិដើមភាគតិច ហើយត្រូវបានចងនៅក្នុងសិទ្ធិមនុស្សដែលមានសិទ្ធិស្មើគ្នាៗនិងសិទ្ធិស្វ័យសម្រេច។ UNDRIP នេះគូសបញ្ជាក់នូវសិទ្ធិមួយចំនួន នៅក្នុងផ្នែកពិសេសសំខាន់ៗ ចំពោះជនជាតិដើមភាគតិច ដូចជាសិទ្ធិទទួលបានស្វ័យគ្រប់គ្រង និងចូលរួម (រួមមានចូលរួមក្នុងការប្រឹក្សាយោបល់រួចហើយយល់ព្រម) សិទ្ធិរក្សាកេរដំណែលវប្បធម៌ និងកេរដំណែលដូងព្រលឹង ដីធ្លីដែនដី និងធនធានធម្មជាតិ ការអភិវឌ្ឍ និងសេវាសង្គម។ UNDRIP នេះ ក៏បានចែងផងដែរថា "ជនជាតិដើមភាគតិចមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ ប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងដីធ្លី ដែនដី និងធនធាននានាដែលពួកគេបានកាន់កាប់នៅក្រោមមូលដ្ឋានជាម្ចាស់កម្មសិទ្ធិតាំងពីដើម ឬតាមបែបផ្សេងណាមួយទៀត ឬប្រើប្រាស់តាំងពីដើមនូវដីធ្លី និងធនធាន ដែលពួកគេបានទទួលតាមរបៀបផ្សេងៗ"។[១៧] សេចក្តីប្រកាសនេះ ក៏តម្រូវឲ្យរដ្ឋ "មានការទទួលស្គាល់ និងការពារតាមផ្លូវច្បាប់ចំពោះដីធ្លី ដែនដី និងធនធានទាំងនោះផងដែរ។ ការទទួលស្គាល់នេះ ត្រូវធ្វើឡើងដោយគោរពឲ្យបានខ្ជាប់ខ្ជួន តាមប្រពៃណី ទំនៀមទម្លាប់ និងប្រព័ន្ធនៃការកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិចដែលពាក់ព័ន្ធ។"[១៨]

ទោះបីជាកម្ពុជាមិនទាន់បានផ្តល់សច្ចាប័នអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៦៩ ដែលបានចែងពីគោលការណ៍ឆ្លុះបញ្ចាំងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះសិទ្ធិដីធ្លី និងធនធាន ធម្មជាតិរបស់ជនជាតិដើមភាគតិច ដែលអាចផ្តល់ការណែនាំ ដល់សកម្មភាពនាពេលអនាគតរបស់រដ្ឋាភិបាលបាន។ អនុសញ្ញាបានពន្លេចនូវសារៈសំខាន់ស្តីពី ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងដីធ្លីខណៈលើកឡើងនូវភារកិច្ចក្នុងការកំណត់ និងកិច្ចការពារដីធ្លីរបស់ពួកគេ រួមទាំងតាមរយៈការទទួលស្គាល់ផ្លូវការ និងការពារនិងការដាក់ពិន័យដល់ការទន្ទ្រានដោយពុំមានការអនុញ្ញាត។[១៩]

គួរកត់សម្គាល់ផងដែរថា មិនមានគំរូ "ទម្រង់មួយដោះស្រាយគ្រប់រឿង" ឬ "ត្រឹមត្រូវ" ណាមួយសម្រាប់ទទួលស្គាល់នូវសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានដីប្រពៃណី និងធនធានរបស់ខ្លួននោះទេ

១៧ សេចក្តីប្រកាសរបស់ អសប ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច មាត្រា២៦

១៨ Ibid.

១៩ អនុសញ្ញាលេខ. ១៦៩, ផ្នែកទី II (ដីធ្លី). សូមមើល ILO, ស្វែងយល់ពីអនុសញ្ញាជនជាតិដើមភាគតិចនិងកុលសម្ព័ន្ធ, ឆ្នាំ១៩៨៩ (លេខ ១៦៩): សៀវភៅណែនាំសម្រាប់សមាសភាពត្រីភាគី ILO, ឆ្នាំ ២០១៣, វគ្គខណ្ឌ ២១-២៣.

ប៉ុន្តែបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិបានផ្តល់សេចក្តីណែនាំ សម្រាប់ការបង្កើតច្បាប់ជាតិ គោលនយោបាយ និងក្របខណ្ឌស្ថាប័ន ដោយគោរពសិទ្ធិទាំងនេះ និងពិចារណាដល់កាលៈទេសៈជាក់លាក់របស់ជាតិ។ វាច្បាស់ណាស់ថា ការបត់បែនដោយយកចិត្តទុកដាក់នូវវិធីដោះស្រាយចំពោះការទទួលស្គាល់ដីធ្លី ហើយ និងធនធានវាតម្រូវឲ្យមានការឈ្វេងយល់ល្អិតល្អន់អំពីបរិបទជាតិ និងភាពចម្រុះនៃការអនុវត្តសិទ្ធិដីធ្លី ដែលមានស្រាប់ ដែលកំពុងចូលជាធរមាន។[20] នៅក្នុងករណីជាច្រើន ការរៀបចំបទប្បញ្ញត្តិស្តីពីកម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច គឺជាភារកិច្ចដ៏ស្មុគស្មាញ ដោយសារវាជាប់ទាក់ទងជាមួយនឹងភាគីពាក់ព័ន្ធ និងដំណាក់កាលជាច្រើន ដោយរាប់ចាប់តាំងពីការអនុម័តច្បាប់ ការកំណត់ដំណាក់កាលដំណើរការឲ្យបានគ្រប់គ្រាន់ និងការបង្កើតនូវយន្តការស្ថាប័នសម្រាប់អនុវត្ត ក៏ដូចជាការធ្វើសេចក្តីសម្រេចចិត្តក្នុងការដាក់សំណើសុំដីឲ្យបាន។[21]

សមាសធាតុចម្បង ដែលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព *គួរ*ដាក់បញ្ចូលនោះ ត្រូវបានស្ថាប័នសិទ្ធិមនុស្សអន្តរជាតិនានាពន្យល់បកស្រាយនៅក្នុងកម្រិតជាក់លាក់មួយ។ ឧទាហរណ៍៖ តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស យោងតាមការពិចារណារបស់ខ្លួនទៅលើកាតព្វកិច្ចរបស់រដ្ឋក្នុងការទទួលស្គាល់ និងធានាការអនុវត្តសិទ្ធិទទួលបានទ្រព្យសម្បត្តិសហគមន៍ ដោយជនជាតិដើមភាគតិចបានកត់សម្គាល់ឃើញថាការអនុម័តសំខាន់ៗនៃយន្តការច្បាប់ និងយន្តការរដ្ឋបាល គឺនឹងមានភាពខ្វះខាត ប្រសិនបើពុំមានការដឹកនាំនៅក្នុងការពិនិត្យពីកាតព្វកិច្ចរបស់រដ្ឋក្នុងការទទួលស្គាល់ និងការធានាការប្រើប្រាស់នូវសិទ្ធិដើម្បីទទួលបានទ្រព្យរួមតាមបែបលក្ខណៈជនជាតិដើមភាគតិច ដើម្បីឲ្យមានការធានាដល់សិទ្ធិទទួលបានទ្រព្យរួម នៅក្នុងពេលវេលាដែលសមស្រប។[22] តុលាការក៏បានកត់សម្គាល់ផងដែរទៀតថា ទោះបីជាបទដ្ឋានអន្តរជាតិ និងការអនុវត្តច្បាស់លាស់ក្នុងការ

---

២០ USAID ៖ ការទទួលស្គាល់សិទ្ធិទទួលបានដីសហគមន៍ និងធនធានរបស់ខ្លួន ៖ ការពិនិត្យមើលបទពិសោធន៍ប្រទេស ឆ្នាំ ២០១៦, vii

២១ ILO ៖ ការអនុវត្តសិទ្ធិរបស់ជនជាតិដើមភាគតិច និងសិទ្ធិរបស់កុលសម្ព័ន្ធ – ការណែនាំអំពីអនុសញ្ញាអន្តរជាតិខាងការងារលេខ ១៦៩ (២០០៩), ៩៦

២២ [តុលាការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស ករណីនៃជនជាតិ Saramaka ជាមួយនឹងសាធារណរដ្ឋ Suriname ការជំទាស់ពីដំបូង គុណសម្បត្តិ ការជួសជុលជាសំណង និងចំណាយ ៖ សាលក្រមចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៧។ ស៊េរី គ លេខ ១៧២ កថាខណ្ឌ ១១៥]

តម្រូវឲ្យជនជាតិដើមភាគតិច ទទួលបានការប្រឹក្សាយោបល់ និងចូលរួមពេញលេញនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើការរួមមាន ដូចជាការរៀបចំក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌគោលនយោបាយ និងការអនុវត្តនីតិវិធីរដ្ឋបាលទាំងនោះ ក៏ដោយ ក៏រដ្ឋត្រូវមានតួនាទីនាំមុខ ជាពិសេសនៅក្នុងការធានាថា ការកំណត់ព្រំប្រទល់ និងការបោះបង្គោលព្រំដីនៅក្នុងដែនដីដែលវិសាលភាពសិទ្ធិធ្វើជាម្ចាស់ទ្រព្យសម្បត្តិរបស់ជនជាតិដើមត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។[២៣] រដ្ឋក៏ត្រូវបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការកំណត់ព្រំប្រទល់ និងការបោះបង្គោលព្រំដីរបស់ជនជាតិដើមភាគតិច ដោយគ្មានការអូសបន្លាយពេលតទៅទៀតឡើយ។[២៤]

ការពិចារណាដ៏សំខាន់នោះ គឺថវិកាចំណាយសម្រាប់អនុវត្តវិធានការកំណត់ព្រំប្រទល់ ការបោះបង្គោលព្រំដី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិច។ ដោយសារភាពស្មុគស្មាញនៃនីតិវិធីរដ្ឋបាលដែលរដ្ឋបានអនុម័តឲ្យដំណើរការនោះ ការចំណាយ គឺជារឿងសំខាន់ណាស់ ហេតុដូច្នេះហើយ ធនធានហិរញ្ញវត្ថុ និងត្រូវបែងចែកធនធានមនុស្សក្នុងចំនួនគ្រប់គ្រាន់ ជាប់ជាប្រចាំដល់ដល់បណ្តាទីភ្នាក់ងារដែលត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តវិធានការទាំងនេះ។ នៅក្នុងការពិចារណារបស់ខ្លួនទៅលើស្ថានភាពជាក់លាក់របស់ជនជាតិដើមភាគតិចតាមប្រទេស អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចថ្មី បានគូសបញ្ជាក់អំពីការតម្រូវឲ្យរដ្ឋត្រូវធានាថា ជនជាតិដើមភាគតិចទទួលបានការគាំទ្រផ្នែកបច្ចេកទេស រួមមានការវាស់វែងចុះបញ្ជីផ្លូវការដីសហគមន៍ពួកគេ ការទទួលស្គាល់ឋានៈផ្លូវការរបស់ពួកគេ និងដំណើរការអោយរួចរាល់នូវរាល់នីតិវិធីចាំបាច់នានាបន្ទាប់ពីទទួលបានពាក្យសុំការចុះបញ្ជី។[២៥]

ជាចុងក្រោយ យន្តការសិទ្ធិមនុស្សបានបញ្ជាក់ថា នៅពេលដែលដីរបស់ជនជាតិ

---

២៣ IACHR ៖ របាយការណ៍លេខ ៤០/០៤ ករណីលេខ ១២.០៥៣ សហគមន៍ជនជាតិដើមភាគតិច Maya នៅក្នុងស្រុក Toledo (Belize) ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣២-បានបញ្ជាក់បន្ថែម។

២៤ IACHR ៖ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅក្នុងប្រទេសវេណេហ្សុយអេឡា ៖ Doc. OEA/Ser.L/V/II, Doc ៥៤ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌទី១០៦០, ១០៧១, ១១៣៧ – អនុសាសន៍ទី ១។

២៥ A/HRC/១២/៣៤/add.២, កថាខណ្ឌទី៨៣ A/HRC/១៨/៣៥/add.៥ កថាខណ្ឌ ៨០ A/HRC/១៨/៣៥/add.៤ កថាខណ្ឌទី៧០ A/HRC/១៥/៣៧/add.៤ កថាខណ្ឌទី ៨៧។

ដើមភាគតិចត្រូវបាន*កំណត់ព្រំប្រទល់ បោះបង្គោលព្រំដី និងចេញប័ណ្ណកម្មសិទ្ធិ* រួចហើយ នោះរដ្ឋត្រូវជៀសវាងពីការធ្វើសកម្មភាពណាមួយដែលបង្កផលប៉ះពាល់ដល់ការរស់រានតម្លៃ ការប្រើប្រាស់ ឬការអាស្រ័យផលពីទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រដែលកាន់កាប់ និងប្រើប្រាស់ដោយជនជាតិដើមភាគតិចពាក់ព័ន្ធ។[២៦] គួរអនុវត្តវិធានការការពារបណ្តោះអាសន្ន នៅពេលណាដែលជនជាតិដើមភាគតិចមានវត្តមាននៅលើដីធ្លីដែលបានស្នើសុំឲ្យមានសកម្មភាពអភិវឌ្ឍន៍ ហើយពួកគេគួរបន្តរស់រាននៅទីកន្លែងនោះរហូត ដល់ដំណើរការកំណត់ព្រំប្រទល់ ការបោះបង្គោលព្រំដី និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានបញ្ចប់សព្វគ្រប់។ ហេតុដូច្នេះ ក្នុងក្របខ័ណ្ឌបញ្ញត្តិទូទៅ វិធានការការពារបណ្តោះអាសន្នមិនអនុវត្តទៅលើតែដីរបស់ជនជាតិដើមភាគតិច ដែលត្រូវបានកំណត់ព្រំប្រទល់ ឬបានបោះបង្គោលព្រំដីរួចហើយនោះទេ ប៉ុន្តែបញ្ញត្តិទូទៅនេះ គឺជាការការពារដ៏សំខាន់ ដើម្បីធានាឲ្យមានការគោរពនូវសិទ្ធិរបស់ជនជាតិដើមភាគតិច មុននឹងសិទ្ធិទាំងនេះត្រូវបានបញ្ជាក់ និងផ្តល់ភាពស្របច្បាប់ តាមរយៈក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីជាតិនានា។

២៦ IACHR របាយការណ៍លេខ ៤០/០៤ ករណីលេខ ១២.០៥៣ សហគមន៍ជនជាតិដើមភាគតិច Maya នៅក្នុងស្រុក Toledo (Belize) ថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៤ កថាខណ្ឌទី១៩៧-អនុសាសន៍ទី ២។

# ផ្នែកទី៣៖



# ក្របខ័ណ្ឌគតិយុត្តិរបស់ប្រទេសកម្ពុជាទាក់ទងនឹងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការទទួលបានដីព្រៃឈើ និងធនធានរបស់ខ្លួន

នៅក្នុងប្រទេសកម្ពុជា ច្បាប់ភូមិបាលគឺជាក្របខ័ណ្ឌគតិយុត្តិដ៏សំខាន់មួយសម្រាប់ផ្តល់ភាពស្របច្បាប់ ដល់កម្មសិទ្ធិដីធ្លីព្រៃឈើរបស់ជនជាតិដើមភាគតិចតាមរយៈការផ្តល់នូវប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។ ច្បាប់នេះទទួលស្គាល់ការអនុវត្តការគ្រប់គ្រងដីសមូហភាពរបស់ជនជាតិដើមភាគតិច និងបានតម្រូវឲ្យមានការការពារសិទ្ធិរបស់ពួកគេ ដើម្បីថែរក្សារបៀបរបបនៃការរស់នៅ តាមបែបប្រពៃណី ដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការប្រើប្រាស់ដីធ្លី និងធនធាននានា ដែលត្រូវបានប្រើប្រាស់តាមទំនៀមទម្លាប់ពួកគេ។

ច្បាប់បានបែងចែកដីធ្លីជាពីរប្រភេទដែលជនជាតិដើមភាគតិចអាចស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពបានគឺ ៖

- ដីឯកជន៖ ដែលមានដូចជាដីលំនៅឋាន និងដីកសិកម្មដាំដុះដាក់ស្ពែង និង



- ដីគ្រប់គ្រងជាសមូហភាព៖ ដែលមានដូចជាដីកប់ខ្មោច ដីព្រៃអារក្ស និងដីបម្រុងទុក (ដីបម្រុងនេះ គឺត្រូវបានលៃទុកដើម្បីធានាថា អ្នកជំនាន់ក្រោយមានដីប្រើប្រាស់ ហើយដោយមិនត្រូវកំណត់តែត្រឹមទំហំដីបច្ចុប្បន្នរបស់សហគមន៍ទេ ប៉ុន្តែអាចមានទំហំធំជាងនេះ)។

ច្បាប់បានដាក់ចេញនូវវិធានការចាំបាច់ដើម្បីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព នៃដីប្រពៃណីជូនជនជាតិដើមភាគតិច។[២៧] បញ្ញត្តិនេះបានបង្កើតឲ្យមាននូវសិទ្ធិសំខាន់ៗ ចំនួនពីរ ៖ សិទ្ធិសម្រាប់ជនជាតិដើមភាគតិចក្នុងការ “គ្រប់គ្រងសហគមន៍ និងអចលនវត្ថុតម្រូវទៅតាមបែបប្រពៃណីទំនៀមទម្លាប់[របស់

---

២៧ មាត្រា ២៣ សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែង មកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។

មាត្រា ២៤ ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិនិងការការពារ ដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌ និងសង្គមធម៌របស់សហគមន៍ ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀតនិងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឲ្យមានការចូលក្នុងសហគមន៍។

មាត្រា ២៥ ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាននិងប្រកបរបរកសិកម្មប្រពៃណី។ ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបម្រុងចោលក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាងនិងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី ៦ នៃច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ។

មាត្រា ២៦ កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឲ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ។ ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុដូចជា ច្បាប់ការពារបរិស្ថានជាដើម។ បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋដែលជាតម្រូវការ នៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ។

មាត្រា ២៧ ដើម្បីសម្រួលការវិវត្តន៍វប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិដើមភាគតិច និងដើម្បីអនុញ្ញាតឲ្យពួកគេបានចេញដោយសេរីពីសហគមន៍ ឬរួចផុតពីការបង្ខិតបង្ខំសិទ្ធិនៃកម្មសិទ្ធិឯកជន អាចនឹងត្រូវផ្ទេរជាពិសេសឲ្យពួកគេបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍ ប៉ុន្តែចំណែកនៃដីដែលជាកម្មវត្ថុនៃការយកធ្វើជាកម្មសិទ្ធិឯកជននោះមិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិ សាធារណៈរបស់រដ្ឋទេ។

មាត្រា ២៨ គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

ពួកគេ]" (មាត្រា ២៣) និងសិទ្ធិកំណត់ព្រំប្រទល់ដីដែលជា ទ្រព្យសម្បត្តិសមូហភាពរបស់ពួកគេ រួចហើយចុះបញ្ជីទ្រព្យទាំងនោះតាមច្បាប់ភូមិបាល (មាត្រា ២៥)។

នៅ ឆ្នាំ២០០២ មួយឆ្នាំបន្ទាប់ពីច្បាប់ភូមិបាលត្រូវបានអនុម័ត ក្រុមប្រឹក្សាគោលនយោបាយដីធ្លី[២៨] បានចេញនូវយុទ្ធសាស្ត្របណ្ដោះអាសន្នស្ដីពីក្របខ័ណ្ឌគោលនយោបាយដីធ្លី។ ពាក់ព័ន្ធនឹងបញ្ញត្តិនៅក្នុងច្បាប់ភូមិបាលស្ដីពី ការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិច យុទ្ធសាស្ត្រនេះបានកត់សម្គាល់ថា ដំណើរការផ្ទេរដីទៅឲ្យសហគមន៍ជនជាតិដើមភាគតិច *"តម្រូវឲ្យមានការស្រាវជ្រាវយ៉ាងប្រុងប្រយ័ត្ន និងការខិតខំប្រឹងប្រែងសាកល្បងសិន ដែលទាមទារឲ្យមានការចូលរួមពីសំណាក់ជនជាតិដើមភាគតិច។ ការស្រាវជ្រាវ និងការសាកល្បងនេះធ្វើឲ្យមានការបង្កើតឡើងនូវអនុក្រឹត្យមួយដែលស្ថិតនៅក្រោមច្បាប់ភូមិបាល ដើម្បីឲ្យសហគមន៍ជនជាតិដើមអាចចុះបញ្ជីដី សុំប័ណ្ណកម្មសិទ្ធិដីសមូហភាពបាន។"*[២៩]

ជាលទ្ធផល រដ្ឋាភិបាល រួមជាមួយនឹងដៃគូអភិវឌ្ឍអន្តរជាតិអង្គការពលកម្មអន្តរជាតិ ព្រមទាំងអង្គការសង្គមស៊ីវិលដែលគាំទ្រយ៉ាងសកម្មដល់ សហគមន៍ជនជាតិដើមភាគតិច បានអនុវត្តសាកល្បងនូវដំណើរការមួយក្នុងការចុះបញ្ជីដីកម្មសិទ្ធិជា សមូហភាពនៅក្នុងសហគមន៍ចំនួនពីរ ដែលស្ថិតនៅក្នុងខេត្តរតនគិរី (ភូមិឡា អិន ឃុំ តឺន ស្រុក កូនមុំ និងនៅក្នុងភូមិល្មឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ) និងសហគមន៍មួយទៀតនៅក្នុងខេត្តមណ្ឌលគិរី (ភូមិអណ្ដូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូររាំង)។

បញ្ញត្តិនៅក្នុងច្បាប់ភូមិបាល ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបានដីធ្លី និងធនធានតាមបែបប្រពៃណីក៏ត្រូវបាន ពង្រឹងបន្ថែមតាមរយៈ *គោលនយោបាយស្ដីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា* ដែលអនុម័តដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លីកាលពីខែមេសា ឆ្នាំ២០០៩។ អ្វីដែលសំខាន់នោះ គោល

---

២៨ ក្រុមប្រឹក្សាជាតិនៃគោលនយោបាយដីធ្លីត្រូវបានបង្កើតឡើងនៅក្រោមកម្មវិធីរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ដោយមានអាណត្តិក្នុងការអនុម័តអនុក្រឹត្យ និងគោលនយោបាយចាំបាច់ ដោយដាក់បញ្ចូលទាំងការផ្ដល់ប័ណ្ណកម្មសិទ្ធិដល់ដីជនជាតិដើមភាគតិច ដើម្បីឲ្យច្បាប់ភូមិបាលឆ្នាំ ២០០១ មានសុពលភាពពិតប្រាកដ។

២៩ គម្រោងរបស់អង្គការ ILO គាំទ្រជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ៖ ការតាក់តែងលក្ខន្តិកៈសម្រាប់ជនជាតិដើមភាគតិច ទំព័រទី៥។

នយោបាយនេះ បានតម្រូវឲ្យ ដំណើរការចុះបញ្ជីដីសហគមន៍ *"ត្រូវមានលក្ខណៈសាមញ្ញ ទាំងផ្នែករដ្ឋបាល និងបច្ចេកទេស និងត្រូវមានតម្លាភាព ។"*[៣០]

គោលនយោបាយ និងគម្រោងសាកល្បងនេះ នាំឲ្យមានការរៀបចំអនុក្រឹត្យមួយស្តីពីជំហានដំណើរការ និងលក្ខខណ្ឌតម្រូវសម្រាប់នីតិវិធីចុះបញ្ជីដីសហគមន៍ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ដែលនោះ គឺជា*អនុក្រឹត្យលេខ៨៣ អនក្រ/បក ស្តីពីនីតិវិធីនៃ ការចុះបញ្ជីដី សហគមន៍ជនជាតិដើមភាគតិច ។*

អនុក្រឹត្យលេខ៨៣ នេះបង្កើតឡើងនូវដំណើរការមួយដែលមានបីដំណាក់កាលដែលសហគមន៍ត្រូវគោរពតាមដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងដែលមានក្រសួងមួយចំនួនជាប់ពាក់ព័ន្ធដូចជា៖

ជាដំបូង សហគមន៍ជនជាតិដើមភាគតិចត្រូវប្រកាសស្វ័យអត្តសញ្ញាណជាជនជាតិដើមភាគតិចសិន រួចហើយដាក់ពាក្យស្នើសុំការទទួលស្គាល់ជាសហគមន៍ជនជាតិដើមភាគតិច ។ ទីពីរ សហគមន៍ត្រូវចុះបញ្ជីជានីតិបុគ្គល និងទីបីសហគមន៍ត្រូវដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដី សមូហភាព ។ ក្រសួងអភិវឌ្ឍន៍ជនបទ (តាមរយៈនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច) ជាអ្នកដំណើរការដំណាក់កាលទី១ ក្រសួងមហាផ្ទៃត្រួតពិនិត្យ និងអនុម័តដំណាក់កាលទី២ រីឯក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកដោះស្រាយដំណាក់កាលទី៣ ។ ក្រៅពីនេះ ប្រសិនបើដីដែលបានកំណត់ថាជាផ្នែកមួយនៃតំបន់ការពារ ហើយត្រូវបានដាក់បញ្ចូលក្នុងពាក្យស្នើសុំ ការចុះបញ្ជីជាដីសមូហភាព នោះក្រសួងបរិស្ថាន ក៏ត្រូវចូលរួមពាក់ព័ន្ធដែរ ។

គិតចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទលែងមាន ភារៈទទួលខុសត្រូវទៅលើការត្រួតពិនិត្យតំបន់ព្រៃការពារទៀតហើយ ។ ជាជំនួសមកវិញ អាណត្តិនេះត្រូវបានផ្ទេរឲ្យក្រសួងបរិស្ថាន នេះមានន័យថាមានតែក្រសួងបន្ថែមមួយទៀតប៉ុណ្ណោះ ដែលជាប់ពាក់ព័ន្ធ ។[៣១]

---

៣០ គោលនយោបាយស្តីពីការចុះបញ្ជី និងប្រើប្រាស់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ឆ្នាំ (២០០៩), ១។

៣១ ក្នុងខែឧសភា ឆ្នាំ២០១៦ តាមរយៈអនុក្រឹត តំបន់ព្រៃការពារទាំងនេះត្រូវបានប្តូរទៅជាតំបន់ការពារធម្មជាតិ ជាមួយនិងការលើកលែងតំបន់ព្រៃការពារតាម័ក្នុងខេត្តតាកែវ។ យោងតាមអង្គការទិន្នន័យអំពីការអភិវឌ្ឍ មានជាង៥០%នៃតំបន់ការពារធម្មជាតិត្រូវបានចាត់ចំណាត់ថ្នាក់ថាជាដែនជម្រកសត្វព្រៃ ។https://opendevelopmentcambodia.net/topics/protected-forest/ accessed on ២០ July ២០១៨.

ទោះជាយ៉ាងនេះក្តី តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងនេះ មិនត្រូវបានចែងនៅក្នុងច្បាប់ ឬអនុក្រឹត្យលេខ៨៣ ឡើយ ហើយបច្ចុប្បន្ននេះ មិនមានមធ្យោបាយណាមួយសម្រាប់ជនជាតិដើមភាគតិច អាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រសួងបរិស្ថានពាក់ព័ន្ធនឹងការដកចេញនូវតំបន់ការពារ និងតំបន់ការពារធម្មជាតិចេញពីប័ណ្ណកម្មសិទ្ធិដីសមូហភាព បាននៅឡើយទេ។

នៅខែធ្នូ២០១៧អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានសម្តែងកង្វល់របស់ពួកគាត់តាមរយៈលិខិតទំនាក់ទំនងទៅកាន់រាជរដ្ឋាភិបាលកម្ពុជា អំពីភាពស្មុគស្មាញ និងភាពយឺតយ៉ាវនៃនីតិវិធីចុះបញ្ជីដីសមូហភាព "ជាពិសេសនៅក្នុងបរិបទនៃដីដែលអាចលក់ ឬជួលបានដោយងាយស្រួលហើយជាញឹកញយគេឃើញថា មិនបានពិចារណាទៅលើច្បាប់ជាតិ និងនីតិវិធីការពារឡើយ"។[៣២] ពួកគាត់បានកត់សម្គាល់ថា "នីតិវិធីស្មុគស្មាញបន្តការរំខាន ដោយការសម្របសម្រួលមិនគ្រប់ជ្រុងជ្រោយរបស់ក្រសួងពាក់ព័ន្ធសំខាន់ៗ (...) និងដោយហេតុថាអាជ្ញាធរមូលដ្ឋានជារឿយៗខ្វះចំណេះដឹងអំពីក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធសិទ្ធិជនជាតិដើមភាគតិចចំពោះដីធ្លី និងធនធានរបស់ពួកគាត់ និងនីតិវិធីទាំងមូលដើម្បីធានាសិទ្ធិទាំងនេះ បូករួមទាំងតួនាទី និងការទទួលខុសត្រូវ របស់ពួកគាត់នៅក្នុងរឿងនេះផងដែរ"។ អនុសាសន៍ទាំងនេះត្រូវបានបន្ថែមលើលិខិតទំនាក់ទំនងការទូតដែលបានចេញកាលពីឆ្នាំ២០០៨និង២០០៩ដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជា

៣២ OL KHM ៦/២០១៧.

ជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច បន្ទាប់ពីអនុក្រឹត្យលេខ៨៣អនក្រ/បកត្រូវបានអនុម័ត។[៣៣]

នៅក្នុងខែឧសភា ឆ្នាំ ២០១១ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញនូវសារាចរអន្តរក្រសួងមួយ ដែលផ្តល់នូវវិធានការការពារបណ្តោះអាសន្នដល់ជនជាតិដើមភាគតិចដែលកំពុងតែរង់ចាំការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេ។[៣៤] ទន្ទឹមនឹងការស្វាគមន៍ចំពោះការចេញ វិធានការការពារបណ្តោះអាសន្នដល់សហគមន៍ វិធានការការពារបណ្តោះអាសន្ននេះ គឺត្រូវបានអនុវត្តតែចំពោះសហគមន៍ជនជាតិដើមភាគតិចដែលបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់រួចរាល់ហើយតែប៉ុណ្ណោះ។[៣៥]

---

៣៣ នៅក្នុងលិខិតមួយចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៨ អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថា សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិចមិនបានដាក់បញ្ចូលនូវបញ្ញត្តិ ដើម្បីការពារដីរបស់ជនជាតិដើមភាគតិចមុនធ្វើការចុះបញ្ជីស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីជាសមូហភាពទេ។ គាត់ក៏បានសម្តែងនូវកង្វល់ផងដែរថាការខកខានមិនបានការពារដីជនជាតិដើមភាគតិចមុននឹងធ្វើការចុះបញ្ជីស្នើសុំប័ណ្ណកម្មសិទ្ធិ នឹងធ្វើឲ្យដីងាយត្រូវបានផ្ទេរកម្មសិទ្ធិឲ្យអ្នកផ្សេងឬរងការគំរាមកំហែងផ្សេងៗទៀតនៅក្នុងរយៈពេលអន្តរកាលនេះ។ លោកបានកត់សម្គាល់ទៀតថា ករណីបែបនេះអាចនឹងកើតមានឡើងជាក់ស្តែង ដោយហេតុថាអនុក្រឹត្យនេះបានចែងនូវបញ្ញត្តិមួយចំនួន ដែលអាចមានផលប៉ះពាល់ធ្វើឲ្យដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិយឺតយូរវិញ ដូចជាលក្ខខណ្ឌតម្រូវឲ្យសហគមន៍ជនជាតិដើមភាគតិចទាំងអស់ត្រូវចុះបញ្ជីជានីតិបុគ្គលសិន មុននឹងដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព(មាត្រា៣) ហើយលក្ខខណ្ឌតម្រូវដែលថា រាល់ជម្លោះដីធ្លីទាំងអស់ត្រូវដោះស្រាយឲ្យរួចរាល់សិន មុននឹងចេញប័ណ្ណកម្មសិទ្ធិដី សមូហភាព(មាត្រា៣រួមជាមួយមាត្រា៧)។អ្នករាយការណ៍ពិសេសក៏បានផ្តល់នូវអនុសាសន៍ថា មាត្រា៣នៃអនុក្រឹត្យ ត្រូវធ្វើវិសោធនកម្ម ដើម្បីអនុញ្ញាតឲ្យសហគមន៍ជនជាតិដើមភាគតិចអាចចុះបញ្ជីជានីតិបុគ្គល នៅដំណាលពេលគ្នាដែលពួកគេដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី។ A/HRC/១២/៣៤/Add.១, វគ្គខណ្ឌទី ២០. បន្ថែមពីនេះ អ្នករាយការណ៍ពិសេសបានកត់សម្គាល់ថា "លក្ខខណ្ឌតម្រូវទីមួយក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះខុសពីស្មារតីនៃច្បាប់ភូមិបាលកម្ពុជា ដែលគ្រាន់តែតម្រូវឲ្យសហគមន៍ចុះបញ្ជីជានីតិបុគ្គលប៉ុណ្ណោះ មុននឹងកាន់កាប់ប័ណ្ណកម្មសិទ្ធិរបស់ខ្លួន ជាជាងមុននឹងដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិនោះទេ"។ A/HRC/១២/៣៤/Add.១, វគ្គខណ្ឌទី ២០។ នៅថ្ងៃទី ១៩ ឧសភា ២០០៩ អ្នករាយការណ៍ពិសេសបានផ្ញើលិខិតមួយទៀតជូនរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាដដែលនេះ។ អ្នករាយការណ៍ពិសេសបានបញ្ចូលលិខិតទំនាក់ទំនងការទូតក្នុងលិខិតចុះថ្ងៃទី ១៩ ឧសភា ២០០៩ របស់គាត់នេះផងដែរ។ សម្រាប់ពត៌មានបន្ថែមសូមអាន A/HRC/១២/៣៤/Add.១, វគ្គខណ្ឌ ១២-២៤។

៣៤ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្តោះអាសន្នការពារដីរបស់ជនជាតិដើមភាគតិចដែលបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីជាសមូហភាពរួចហើយ ខណៈពេលដែលរង់ចាំដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ អនុលោមតាមនីតិវិធីបំពេញចប់សព្វគ្រប់។ ចេញនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១។

៣៥ ដំណោះស្រាយនេះគឺមិនស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធជនជាតិដើមភាគតិចទេ ដែលរដ្ឋថារហូតដល់ដីជនជាតិដើមភាគតិចត្រូវបានកំណត់ព្រំដែន កំណត់ព្រំប្រទល់ និងផ្តល់ប័ណ្ណកម្មសិទ្ធិរួចរាល់។ រដ្ឋត្រូវជៀសវាងពីរាល់សកម្មភាពដែលអាចនាំអោយប៉ះពាល់ដល់វត្តមាន តម្លៃ ការប្រើប្រាស ឬការរីករាយនៃទ្រព្យបិតនៅក្នុងភូមិសាស្ត្រកាន់កាប់ និងប្រើប្រាសដោយពលរដ្ឋពាក់ព័ន្ធ (របាយការណ៍IACHR លេខ ៤០/០៤, ករណីលេខ ១២.០៥៣, សហគមន៍ជនជាតិដើមភាគតិច ម៉ាយ៉ា (Maia) នៃស្រុក Toledo (Belize), ថ្ងៃទី ១២ តុលា ២០០៤, វគ្គខណ្ឌ ១៩៧, អនុសាសន៍ទី ២; យោងទៅលើ OL KHM ៦/២០១៧).

នៅក្នុងឆ្នាំ ២០១៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក៏បានចេញនូវ "សេចក្តីណែនាំស្តីពី ការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីដែលត្រូវដាក់បញ្ចូលជាដីកម្មសិទ្ធិសមូហភាព ឬដែលត្រូវកាត់ចេញពីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីជានីតិបុគ្គលរួច" ដល់មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី ការិយាល័យ OHCHR កត់សម្គាល់ឃើញថា សារាចរនេះស្ទើរតែមិនមានសហគមន៍ណាបានដឹង មានន័យថា អ្នកភូមិជនជាតិដើមភាគតិចដែលបានស្នើសុំរើសយកប័ណ្ណកម្មសិទ្ធិដីផ្លូវឯកជនប៉ុន្តែមានបំណងចង់ចូលរួមនៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាពវិញ (ឬបញ្ច្រាសមកវិញ អ្នកភូមិដែលបានបញ្ចូលនៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាពតាំងពីដើមមក ប៉ុន្តែមានបំណងចង់បានប័ណ្ណកម្មសិទ្ធិដីផ្លូវឯកជនវិញ) មិនបានដឹងអំពីសិទ្ធិរបស់ពួកគេនៅក្នុងការអាចធ្វើបានបែបនេះបាននោះទេ។ ដោយសារប័ណ្ណកម្មសិទ្ធិដីធ្លីទាំងនេះអាចផ្ទេរបាន ផ្អែកតាមសំណើរបស់សមាជិកសហគមន៍ ហើយសារាចរនេះ នឹងមានប្រសិទ្ធភាព តែនៅក្នុងកម្រិតណាមួយប៉ុណ្ណោះ ប្រសិនបើគំនិតផ្តួចផ្តើមផ្សព្វផ្សាយការយល់ដឹង មិនត្រូវបានអនុវត្តឡើងដោយក្រសួងនិងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលធ្វើការនៅក្នុង សហគមន៍ជនជាតិដើមភាគតិចនោះទេ។

ក្រៅពីអនុក្រឹត្យលេខ៨៣ក៏នៅមានគោលការណ៍ណែនាំផ្ទៃក្នុង មួយទៀតរបស់ក្រសួងអភិវឌ្ឍន៍ជនបទ[៣៦] ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទីមួយ នៃដំណើការចុះបញ្ជីដីសមូហភាព។ សេចក្តីព្រាងកូនសៀវភៅព័ត៌មានដែលមិនទាន់បោះពុម្ព (ចុះនៅឆ្នាំ ២០១០) ពាក់ព័ន្ធនឹងការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃស្តីពីតួនាទីរបស់ពួកគេក្នុងអំឡុងពេលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពក៏ត្រូវបានយោងនៅក្នុងឯកសារច្បាប់ និងគោលនយោបាយដែលមានពីមុនផងដែរ។[៣៧] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបង្កើតសេចក្តីណែនាំ ដាច់ដោយឡែកមួយ

៣៦ សារាចរលេខ០៩៧៤ស្តី/០៩ "ស្តីពីនីតិវិធី និងវិធីសាស្ត្រអនុវត្តន៍គោលនយោបាយជាតិស្តីពីការអភិវឌ្ឍ និងការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០០៩

៣៧ ឯកសារយោង គឺយោងលើសៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណនៃជនជាតិដើមភាគតិច ការតាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការគូរផែនទីបឋម ការវិនិច្ឆ័យដី និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (Kirsten Ewers Andersen និង Loeung Kesaro, គាំទ្រដោយអង្គការ GIZ),ទំព័រ ៥។

ទៀតស្តីពីដំណើរការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។[៣៨]

គួរកត់សម្គាល់ថា ទោះបីជាច្បាប់ភូមិបាលបានផ្តល់ការការពារដ៏សំខាន់ដល់ជនជាតិដើមភាគតិចក៏ដោយ ក៏ការទទួលស្គាល់នូវសិទ្ធិពួកគេក្នុងការទទួលបានដីប្រពៃណី និងធនធានពួកគេ មិនត្រូវបានអនុវត្តស្មើគ្នាតាមគ្រប់ប្រភេទនៃការប្រើប្រាស់ដីផ្សេងៗគ្នានោះដែរ។ ការពិតច្បាប់ភូមិបាលចែងតែអំពីដីកសិកម្ម ដីលំនៅឋាន និងដីដំណាំវិលជុំដែលរួមបញ្ចូលទាំងដីបម្រុងចាំបាច់ក្នុងការដូរវេនដាំដំណាំប៉ុណ្ណោះ (មាត្រា២៥)។ ដូច្នេះសហគមន៍ជនជាតិដើមភាគតិច និងជនជាតិដើមភាគតិចមានសុវត្ថិភាពកាន់តែតិចចំពោះសិទ្ធិតាមបែបប្រពៃណីទៅលើដីព្រៃ ស្ទឹង និងទន្លេ។ ការកម្រិតបន្ថែមទៅលើដីដែលអាចស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏ត្រូវបានដាក់បញ្ចូលនៅក្នុងអនុក្រឹត្យលេខ ៨៣ នេះដែរ ដោយចែងថា ដីព្រៃអារក្ស និងដីកប់ខ្មោចរបស់សហគមន៍ ជនជាតិដើមភាគតិចមិនត្រូវមានទំហំសរុបលើសពី៧ហិកតាសម្រាប់ដីនីមួយៗឡើយ(មាត្រា៦)[៣៩]។ ការកម្រិតនេះមិនមែនជាប្រធានបទមួយដែលស្ថិតនៅក្នុងការពិភាក្សាពិគ្រោះយោបល់ដែលនាំទៅដល់ការអនុម័តអនុក្រឹត្យលេខ៨៣ ទេហើយវាអាចបង្កឲ្យមានកង្វល់ដល់សហគមន៍ជនជាតិដើមភាគតិច ដែលដីកប់ខ្មោច និងដីព្រៃអារក្សរបស់ពួកគេមានទំហំសរុបធំជាង១៤ហិកតាដែលពួកគេអាចស្នើសុំបាន ការណ៍នេះអាចបង្ខំឲ្យពួកគេជ្រើសរើសថា តើតំបន់ណាខ្លះត្រូវដាក់បញ្ចូលទៅក្នុងប័ណ្ណកម្មសិទ្ធិរបស់ពួកគេ និងតំបន់ណាខ្លះត្រូវដកយកចេញ។ នៅក្នុងលិខិតទំនាក់ទំនងរួមគ្នាទៅកាន់រាជរដ្ឋាភិបាលកម្ពុជា អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពី សិទ្ធិជនជាតិដើមភាគតិច និងអ្នករាយការណ៍

៣៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖ ការណែនាំបណ្តុះបណ្តាលអំពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ខែកុម្ភៈ ឆ្នាំ ២០១២។

៣៩ នៅក្នុងកិច្ចពិគ្រោះយោបល់ជាមួយតំណាងក្រសួងអភិវឌ្ឍន៍ជនបទនៅថ្ងៃទី ០៨ ធ្នូ ២០១៦។ ការិយាល័យOHCHR ត្រូវបានផ្តល់ដំណឹងថាមាន សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាជាច្រើនមិនទាន់មាន ឬទាមទារ ដីព្រៃអារក្ស ឬដីកប់សពលើសពី៧ហិកតានោះទេ។ ទោះជាយ៉ាងណា យើងមិនអាចចាត់ទុកថាសហគមន៍ជនជាតិដើមភាគតិចនៅទូទាំងប្រទេសសុទ្ធសឹងតែមានស្ថានភាពបែបនេះនោះទេ។ ខណៈដែលសហគមន៍ខ្លះមានសល់ព្រៃអារក្សត្រឹមតែពីរហិកតាទេ និងសហគមន៍ផ្សេងទៀតអាចកាន់កាប់ដីប្រពៃណីធំជាងប្រាំពីរហិកតា។ ការិយាល័យOHCHR បានកត់សម្គាល់ផងដែរថា ការកម្រិតទំហំព្រៃអារក្ស និងដីកប់សពគឺផ្ទុយពីស្មារតីនៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលបានចែងថា "ការវាស់វែង និងការកំណត់ព្រំប្រទល់អចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវកំណត់តាមស្ថានភាពជាក់ស្តែងដែលអះអាងដោយសហគមន៍ដោយមានកិច្ចព្រមព្រៀងពីសហគមន៍ជិតខាងរបស់ពួកគេ"។

ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានរំលឹករាជរដ្ឋាភិបាលកម្ពុជាថា "បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមមានសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចមាត្រា២៦បានចែងថា ជនជាតិដើមភាគតិចមានសិទ្ធិដីធ្លី ដែនដី និងធនធានដែលពួកគេបានកាន់កាប់តាមលក្ខណៈប្រពៃណីគ្រប់គ្រង ឬប្រើប្រាស់ ឬបានទិញ។ ដូច្នេះ ចំណែកដី និងធនធានរបស់ជនជាតិដើមភាគតិច មានដូចជាដីព្រៃអារក្ស និងព្រៃកប់សព មិនត្រូវបានផាត់ចេញពីការពិចារណាផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ឬកម្រិតទំហំឡើយ-ដូចជាការកម្រិត៧ហិកតាចំពោះដីព្រៃអារក្ស និងដីព្រៃកប់សពកំនត់ដោយអនុក្រឹត្យលេខ៨៣-ដែលត្រូវបានអនុវត្តចំពោះសហគមន៍ ជនជាតិដើមភាគតិចនោះឡើយ។[៤០]

ដោយហេតុថា ក្រុមភាគច្រើនដែលបានធ្វើស្វ័យអត្តសញ្ញាណកម្មជាជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជាទាំងនោះ សុទ្ធតែបានផ្សារភ្ជាប់ជីវភាពរស់នៅ និងចំណងវប្បធម៌របស់ពួកគេយ៉ាងជិតស្និទ្ធជាមួយនឹងព្រៃឈើ។ ច្បាប់ស្តីពីព្រៃឈើបញ្ជាក់អំពីការការពារសិទ្ធិប្រមូលផលចេញ្ចាះជ័រទឹក របស់សហគមន៍មូលដ្ឋាន និងសិទ្ធិរបស់ពួកគេក្នុងការប្រមូលអនុផលព្រៃឈើ (មាត្រា ៤០) និងហាមឃាត់ការកាប់ដើមឈើណា ដែលសហគមន៍មូលដ្ឋានបានចេញ្ចាះយកជ័រទឹករួចហើយ សម្រាប់ប្រើប្រាស់តាមបែបប្រពៃណី (មាត្រា ២៩) របស់ពួកគេ។ ជាសំខាន់ ច្បាប់នោះបានដាក់បញ្ចូលនូវបញ្ញត្តិមួយចំនួនទៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសហគមន៍ដែលបានអនុម័តកាលពីឆ្នាំ ២០០៣។[៤១] អនុក្រឹត្យនេះនាំឲ្យមានការ*ផ្ទេរសិទ្ធិគ្រប់គ្រង*ទៅលើធនធានព្រៃឈើមកឲ្យសហគមន៍មូលដ្ឋានតាមរយៈយន្តការមួយដែលមានឈ្មោះថា កិច្ចព្រមព្រៀងព្រៃឈើសហគមន៍ដែលសហគមន៍មូលដ្ឋានអាចចុះកិច្ចព្រមព្រៀងបានជាមួយនឹងរដ្ឋបាលព្រៃឈើ ដែលជាទីភ្នាក់ងាររដ្ឋាភិបាលធ្វើប្រតិបត្តិការនៅក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - សម្រាប់រយៈពេលបន្តចំនួន១៥ឆ្នាំទៀត។ការផ្ទេរកិច្ច

៤០ OL KHM ៦/២០១៧.

៤១ អនុក្រឹត្យលេខ ៧៩ ស្តីពីការគ្រប់គ្រងព្រៃសហគមន៍ (២០០៣)

សន្យាជួលនេះ គឺផ្ទុយពីកិច្ចព្រមព្រៀងព្រៃសហគមន៍ ដែលសហគមន៍បានចុះជាមួយនឹងក្រសួងបរិស្ថាននៅក្នុងតំបន់ការពារ (គ្រប់គ្រងដោយច្បាប់ស្តីពី តំបន់ការពារធម្មជាតិ)។

ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (ឆ្នាំ ២០០៨) បានកំណត់នូវក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារនៅក្នុងប្រទេសកម្ពុជា។ ច្បាប់នេះទទួលស្គាល់នូវសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងបន្តរស់នៅលើដែនដីដែលត្រូវបានចាត់ចំណាត់ថ្នាក់ថា ជាតំបន់ការពារ[៤២]។ ការតាមដានពិនិត្យមើលការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិស្ថិតនៅលើក្រសួងបរិស្ថាន។ អ្វីដែលជាកង្វល់ពិតប្រាកដនោះ គឺការកំហិតរបស់ច្បាប់ស្តីពីតំបន់ការពារធម្មជាតិទៅលើសិទ្ធិដីធ្លីសម្រាប់ជនជាតិដើមភាគតិច។ ទោះបីជាច្បាប់ទទួលស្គាល់*សិទ្ធិប្រើប្រាស់*របស់សហគមន៍មូលដ្ឋានក៏ដោយ ក៏ជំហរបស់ច្បាប់នេះបញ្ជាក់យ៉ាងច្បាស់លាស់ថា សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចមិនអាចទទួលបាន ប័ណ្ណកម្មសិទ្ធិដីធ្លីចំពោះដីបង្កបង្កើនផល នៅក្នុងតំបន់ការពាររបស់សហគមន៍បានទេ[៤៣] – ជាបញ្ញត្តិមួយដែលទំនងជាផ្ទុយនឹងការទទួលស្គាល់ដោយច្បាប់ភូមិបាល ដែលចែងថាសាធារណៈរបស់រដ្ឋ អាចដាក់បញ្ចូលទៅក្នុងប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិចបាន។

ក្រមបរិស្ថាន និងធនធានធម្មជាតិនៃប្រទេសកម្ពុជា ដែលបច្ចុប្បន្ន ជាសេចក្តីព្រាងទំនងជាមានឥទ្ធិពលទូលំទូលាយទៅលើសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ នៅក្នុងតំបន់ព្រៃឈើ និងតំបន់ការពារធម្មជាតិ ជាពិសេសពាក់ព័ន្ធនឹងសេចក្តីស្នើរបស់ក្រមដែលលើកឡើងអំពីការបង្កើតរបៀង អភិរក្សជីវចម្រុះ (ពង្រីកឲ្យកាន់តែធំឡើងនូវវិសាលភាពភូមិសាស្ត្រនៃតំបន់ការពារធម្មជាតិបច្ចុប្បន្ន) និងការបង្កើត និងដាក់ឲ្យអនុវត្តនូវយន្តការសហគ្រប់គ្រងថ្មីមួយ។ សេចក្តីព្រាងបច្ចុប្បន្នបំផុត (ដែលបានផ្សព្វផ្សាយនៅដើមឆ្នាំ២០១៧) មិនបានលើកឡើងទាល់តែសោះ អំពីរបៀបដែលសិទ្ធិដីធ្លីប្រពៃណី ក្លាយជាកត្តាមួយនៅក្នុង

៤២ ជំពូកទី៦ មាត្រា២១-២៦

៤៣ Chapter ៦, Articles ២១-២៦

ការពិចារណាធ្វើសេចក្តីសម្រេចចិត្ត ទៅលើផែនការប្រើប្រាស់ដី ដែលបញ្ចូលទាំងដីតំបន់ព្រៃឈើផងដែរនោះ។[៤៤]

ថ្មីៗ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យថ្មីមួយលេខ ១៨៤ អនក្រ/បក ចេញថ្ងៃទី ០២ ធ្នូ ២០១៩ “ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក” ដែលមានផលដ៏សំខាន់មួយដល់នីតិវិធីចុះបញ្ជីដីសមូហភាពដែលមានស្រាប់។ អនុក្រឹត្យនេះក៏ត្រូវបានស្គាល់ផងដែរថាជា “អនុក្រឹត្យ វិមជ្ឈការ” ដោយមានគោលបំណង “លើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ស្រុក” (មាត្រា១) ដោយ “កំណត់មុខងារ រចនាសម្ព័ន្ធ តួនាទីភារកិច្ច ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលស្រុក” (មាត្រា២)។ ជាលទ្ធផលនៃអនុក្រឹត្យនេះ រាល់ការិយាល័យជំនាញរបស់មន្ទីរនឹងត្រូវបានផ្ទេរទៅ និងនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកចាប់ពីដើមឆ្នាំ២០២០តទៅ។ ទាំងអនុក្រឹត្យលេខ១៨៤ អនក្រ/បក និងឧបសម្ព័ន្ធទាំងប្រាំពុំមានចែងអំពីការលើកកម្ពស់ក៏ ដូចជាការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចក្នុងការចុះបញ្ជីដីសមូហភាពរបស់ពួកគេទេ។ ទោះជាយ៉ាងណា នៅក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យបានរាយនាមវិស័យដែលត្រូវផ្ទេរ រួមទាំងវិស័យរៀបចំដែនដី និងភូមិបាលផងដែរ។ ជាប្រពៃណី វិស័យទាំងពីរនេះ គឺមានតួនាទីយ៉ាងសកម្មក្នុង ការអនុវត្តនីតិវិធីចុះបញ្ជីដីសមូហភាព។

ក្នុងចំណោមចំណាត់ថ្នាក់ឋានានុក្រមនានារបស់រដ្ឋាភិបាល វិមជ្ឈការរដ្ឋបាលគឺដើម្បីចាត់ចែងមុខងារ ភារកិច្ច និងធនធានហិរញ្ញវត្ថុសម្រាប់ផ្តល់សេវាអោយកាន់តែប្រសើរ និងគ្រប់គ្រងធនធាន អោយកាន់តែមានប្រសិទ្ធភាព។ គុណសម្បត្តិចម្បងរបស់វិមជ្ឈការគឺដើម្បីសម្របសម្រួលការអនុវត្តដំណោះស្រាយបញ្ហាមូលដ្ឋានដល់ស្ថានភាពនៅមូលដ្ឋាន។នៅក្នុងករណីរបស់កម្ពុជា ដោយហេតុថាស្រុកនីមួយៗ នឹងត្រូវបានលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងការងាររបស់ខ្លួន ដូច្នេះពួកគាត់អាចអនុវត្តកម្មវិធី ឬដោះស្រាយបញ្ហាមូលដ្ឋានដើម្បីឆ្លុះបញ្ចាំងស្ថានភាពពិសេស ឬតាមតម្រូវការជាពិសេសនៅក្នុងមូលដ្ឋានរបស់ខ្លួន

៤៤ ឯកសារយោង គឺយោងទៅលើការដាក់ជូនមតិយោបល់របស់ការិយាល័យ OHCHR ចំពោះសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា លេខទីប្រាំមួយ (សេចក្តីព្រាងចុះថ្ងៃទី ២០.១១ ២០១៦ មតិយោបល់របស់ការិយាល័យ OHCHR ផ្ញើឡើងថ្ងៃទី ៥.១២. ២០១៦)

ផ្ទាល់។ ការប្រតិភូកម្មការងារដល់រដ្ឋបាលថ្នាក់ស្រុកអាចកាត់បន្ថយស្រទាប់រដ្ឋបាលពាក់ព័ន្ធនីតិវិធីចុះបញ្ជីដីសមូហភាព អាចសន្សំថ្ងៃចំណាយលើការធ្វើដំណើរ និងកាត់បន្ថយពេលវេលាការធ្វើដំណើររបស់មន្ត្រីពីថ្នាក់មជ្ឈិមព្រមទាំងអាចតាមដានរហ័សលើដំណើរការនោះ និងអាចនាំយកនីតិវិធីនោះទៅកាន់តែជិតអ្នកទទួលផល។ ទោះជាយ៉ាងណា វិមជ្ឈការដោយការកាត់បន្ថយការត្រួតពិនិត្យពីថ្នាក់ជាតិតាមព្រឹត្តិហេតុបង្កអោយមានសក្តានុពលនៃភាពប្រែប្រួលស្ថានភាពសេវាស៊ីវិល។ ដូច្នេះប្រសិន បើរដ្ឋបាលថ្នាក់ស្រុកទទួលបានការណែនាំតិចតួចស្តីពី ការអនុវត្តដំណើរការចុះបញ្ជីដីសមូហភាព នោះជនជាតិដើមភាគតិចដែលមកពីស្រុកខុសគ្នានឹងប្រឈមនីតិវិធីចុះបញ្ជីដីសមូហភាពផ្សេងគ្នាផងដែរ។

## ផ្នែកទីIII ៖

# ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅក្នុងប្រទេសកម្ពុជា៖ ការស្នើសុំសម្រួលដំណើរការចុះបញ្ជី

## ដំណាក់កាលទី១៖ ការទទួលស្គាល់សហគមន៍ជាជនជាតិដើមភាគតិច (ក្រសួងអភិវឌ្ឍន៍ជនបទ)

### ការអនុវត្តបច្ចុប្បន្ន

ក្នុងការអនុវត្តពេលបច្ចុប្បន្ននេះ មុនដំបូង សហគមន៍ត្រូវរៀបចំខ្លួនដើម្បីប្រកាសស្វ័យអត្តសញ្ញាណជាជនជាតិដើមភាគតិចជាមុនសិន។ ទោះជា ភូមិជនជាតិដើមភាគតិចជាច្រើន ដែលចាប់ផ្តើមអនុវត្តដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពអាចមានគ្រួសារជនជាតិដើមភាគតិច និងគ្រួសារជនជាតិខ្មែររស់នៅលាយគ្នា ក្នុងករណីនេះ មានតែគ្រួសារជនជាតិដើមភាគតិចប៉ុណ្ណោះ ដែលមានបំណងស្នើសុំ និងមានសិទ្ធិទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ហេតុដូច្នេះហើយ ការផ្សព្វផ្សាយការយល់ដឹង និងដំណើរការស្វ័យអត្តសញ្ញាណកម្មនឹងអាចបែងចែកបានរវាងគ្រួសារជាជនជាតិភាគតិច និងគ្រួសារមិនមែនជាជនជាតិដើមភាគតិច។ មានតែគ្រួសារជាជនជាតិដើមភាគតិចប៉ុណ្ណោះដែលត្រូវផ្តិតមេដៃជាចាំបាច់សម្រាប់ការដាក់ពាក្យស្នើសុំទៅក្រសួងអភិវឌ្ឍន៍ជនបទដើម្បីស្នើសុំចុះបញ្ជីនោះ។

ការប្រជុំនៅសហគមន៍ដើម្បីធ្វើស្វ័យអត្តសញ្ញាណកម្មជាជនជាតិដើមភាគតិច គឺជាកិច្ចប្រជុំមួយ ដែលសហគមន៍យល់ព្រមទៅលើឋានៈរបស់ខ្លួនជាជនជាតិដើមភាគតិចនិងជាសមាជិក សហគមន៍ ហើយបន្ទាប់ពីការតែងតាំងសមាជិកសហគមន៍រួច អ្នកចូលរួមប្រជុំ ក៏នឹងមានការជ្រើសរើសគណៈកម្មការគ្រប់គ្រង ដោយផ្អែកលើសំឡេងឆ្នោតភាគច្រើន ដែលគណៈកម្មការនេះនឹងតំណាងឲ្យសហគមន៍ពួកគេ និងត្រួតពិនិត្យថា បទបញ្ញត្តិផ្ទៃក្នុងស្តីពីការគ្រប់គ្រងដី និងការដោះស្រាយវិវាទ (ដែលនឹងត្រូវរៀបចំឡើងនៅពេលគួរ

ផែនទីដីបឋមនៅក្នុងការរៀបចំពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព) ត្រូវបានគោរព និងអនុវត្តដោយសមាជិកសហគមន៍ដែរ ឬយ៉ាងណា។

អាជ្ញាធរមូលដ្ឋានត្រូវចូលរួមនៅគ្រប់កិច្ចប្រជុំទាំងអស់ព្រោះថាពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការចុះហត្ថលេខាលើឯកសារនានាដែលត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំ ដើម្បីដាក់ជូនក្រសួងអភិវឌ្ឍន៍ជនបទ។

នៅពេលដែលសមាជិកសហគមន៍បានព្រមព្រៀងលើឋានៈជាជនជាតិដើមភាគតិចរបស់ពួកគេរួចហើយ នោះគណៈកម្មការគ្រប់គ្រងដែលជាប់ឆ្នោតនឹងរៀបចំដាក់សំណើមួយទៅកាន់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បី "បញ្ជាក់ភាពត្រឹមត្រូវអត្តសញ្ញាណជនជាតិភាគតិច"។ ឯកសារខាងក្រោមទាំងអស់នេះត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំ៖

- កំណត់ហេតុកិច្ចប្រជុំ ដែលសហគមន៍ធ្វើស្វ័យអត្តសញ្ញាណកម្មជាជនជាតិដើម[៤៥]
- បញ្ជីរាយនាមអ្នកចូលរួមនៅក្នុងការប្រជុំ[៤៦]
- សេចក្តីប្រកាសអំពីការធ្វើស្វ័យអត្តសញ្ញាណកម្ម និងបញ្ជីរាយនាមសមាជិកទាំងអស់របស់សហគមន៍ ដែលមានបំណងរក្សាអត្តសញ្ញាណ ខ្លួនជាជនជាតិដើមនៃសហគមន៍ជនជាតិដើមភាគតិច[៤៧]
- បែបបទពាក្យស្នើសុំដែលមានចុះហត្ថលេខាដោយសមាជិកគ្រួសារ/គ្រួសារ ដែលមានបំណងចាត់ទុកខ្លួនជាសមាជិកសហគមន៍[៤៨]
- ទម្រង់ពាក្យស្នើសុំរបស់សហគមន៍សម្រាប់ដាក់ជូនទៅក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីទទួលស្គាល់ និងបញ្ជាក់ភាពត្រឹមត្រូវនូវឋានៈ/អត្តសញ្ញាណរបស់ខ្លួនជាជនជាតិដើមភាគតិច[៤៩]

ស្ថិតនៅក្រោមការអនុវត្តដែលបានបង្កើតនេះ ពាក្យស្នើសុំរបស់សហគមន៍ត្រូវយល់

---

៤៥ ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ទម្រង់លិខិតសម្រាប់កំណត់ហេតុពិគ្រោះយោបល់ (ស្តីពីអត្តសញ្ញាណជនជាតិភាគតិច និងគុណប្រយោជន៍ពីការផ្តល់ ប័ណ្ណកម្មសិទ្ធិដីសមូហភាព)

៤៦ ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ទម្រង់លិខិតសម្រាប់បញ្ជីឈ្មោះអ្នកចូលរួមនៅក្នុងការប្រជុំដែលប្រកាសអំពីអត្តសញ្ញាណជនជាតិភាគតិចរបស់សហគមន៍

៤៧ ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ទម្រង់លិខិតសម្រាប់ប្រកាស/លិខិតស្វ័យអត្តសញ្ញាណកម្ម និងបញ្ជីឈ្មោះសមាជិក

៤៨ ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ទម្រង់លិខិតសម្រាប់សមាជិកគ្រួសារ/ទម្រង់ពាក្យស្នើសុំសម្រាប់គ្រួសារដើម្បីចូលជាសមាជិកនៃអ្នកកាន់កាប់សិទ្ធិរបស់សហគមន៍

៤៩ ក្រសួងអភិវឌ្ឍន៍ជនបទ ៖ ទម្រង់លិខិតសម្រាប់ទម្រង់ពាក្យស្នើសុំរបស់សហគមន៍ដាក់ជូនទៅក្រសួងអភិវឌ្ឍន៍ជនបទដើម្បីទទួលស្គាល់ និងផ្តល់សុពលភាពអត្តសញ្ញាណជាជនជាតិភាគតិច

ព្រមនិងចុះហត្ថលេខាដោយមេឃុំ អភិបាលស្រុក ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ និង អភិបាលខេត្ត។

នៅពេលដែលក្រសួងអភិវឌ្ឍន៍ជនបទបានទទួលកញ្ចប់ពាក្យស្នើសុំរួចហើយ នោះអ្នកតំណាងពីក្រសួងនៅក្នុងរាជធានីភ្នំពេញ នឹងចុះពិនិត្យនិងបញ្ជាក់ភាពត្រឹមត្រូវអត្តសញ្ញាណជាជនជាតិដើមភាគតិចរបស់សហគមន៍។ ការបញ្ជាក់ភាពត្រឹមត្រូវនេះ គឺផ្អែកទៅលើការវាយតម្លៃរបស់ក្រសួងទៅលើរបៀបរបបសង្គម វប្បធម៌ និងសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ រួមមានការគ្រប់គ្រងដីសមូហភាព ការសម្ភាសន៍ជាមួយនឹងសមាជិកសហគមន៍ និងសហគមន៍ជិតខាង និងការផ្ទៀងផ្ទាត់សុឆន្ទៈរបស់សមាជិកសហគមន៍ដែលចង់រក្សាអត្តសញ្ញាណជាជនជាតិដើមភាគតិច។

លក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ជាក់ "ភាពជាជនជាតិដើមភាគតិច" ដូចដែលមានចែងនៅក្នុងមាត្រា២៣ នៃច្បាប់ភូមិបាល ចែងថា សហគមន៍ជនជាតិដើមភាគតិច គឺជា *"ក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមបែបប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។"* ក្រៅពីនិយមន័យនេះ មិនមានលក្ខណៈវិនិច្ឆ័យផ្សេង ឬការណែនាំណាមួយមានចែងនៅក្នុងច្បាប់ភូមិបាល ឬអនុក្រឹត្យដែលកំពុងចូលជាធរមាននេះទេ។ នៅត្រឹមដំណាច់ឆ្នាំ២០១១ ក្រសួងអភិវឌ្ឍន៍ជនបទបានចេញសេចក្តីណែនាំបន្ថែមមួយសម្រាប់ "ផ្ទៀងផ្ទាត់" អត្តសញ្ញាណជនជាតិភាគតិចរបស់សហគមន៍នានាតាមរយៈសារាចរលេខ ៩៧៤/០៩កអជដែលផ្អែកលើនិយមន័យនៅក្នុងមាត្រា២៣ នៃច្បាប់ភូមិបាល។ ទោះជាយ៉ាងនេះក្តី សារាចរលេខ៩៧៤ នេះ មិនមានចែងអំពីព័ត៌មានលម្អិតផ្អែកបច្ចេកទេសណាមួយសម្រាប់ដំណើរការផ្ទៀងផ្ទាត់ជនជាតិដើមភាគតិចនោះទេ ផ្ទុយមកវិញព័ត៌មានលម្អិតទាំងនេះ អាចស្វែងរកបាននៅក្នុងទម្រង់លិខិតនានាដែលក្រសួងបានរៀបចំ តាំងពីឆ្នាំ២០១០[៥០] ដូចជាទម្រង់លិខិតប្រកាសស្វ័យអត្តសញ្ញាណកម្ម និងបញ្ជីរាយនាមសមាជិកនៅក្នុងសហគមន៍ ដែលបញ្ជាក់លម្អិតថា

៥០ សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណនៃជនជាតិដើមភាគតិច ការតាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការគូរផែនទីបឋម ការវិនិច្ឆ័យដី និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (Kirsten Ewers Andersen និង Loeung Kesaro, គាំទ្រដោយអង្គការ GIZ),ទំព័រ ៨ ។ សូមមើល។

សហគមន៍ប្រើប្រាស់ និងគ្រប់គ្រងដីជាដីសមូហភាព មិនមែនជាទ្រព្យសម្បត្តិបុគ្គលណាម្នាក់ឡើយ និងថាសមាជិករបស់ខ្លួនធ្វើស្រែ និងដាំដំណាំកសិកម្មនៅក្នុងបរិវេណដីសមូហភាពរបស់សហគមន៍[៥១]។ អាជ្ញាធរមូលដ្ឋានតម្រូវឲ្យចូលរួមនៅក្នុងការបញ្ជាក់ភាពត្រឹមត្រូវនេះ។

## បញ្ហា

### ❖ ភាពជាម្ចាស់នៅមានកម្រិតរបស់រដ្ឋាភិបាល

ជាទ្រឹស្តី ដំណាក់កាលទី១ គួរចាប់ផ្តើមឡើង និងគាំទ្រឲ្យបានខ្លាំងក្លាដោយក្រសួងអភិវឌ្ឍន៍ជនបទនៅកម្រិតថ្នាក់ខេត្ត ដែលត្រូវរៀបចំ នូវការប្រជុំផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច ដែលមានចែងនៅក្នុងច្បាប់ជាតិសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលកំពុងតែពិភាក្សានេះ និងសម្រាប់អាជ្ញាធរមូលដ្ឋាន ក៏ដូចជាដើម្បីសម្រួលដល់ការប្រជុំដែលនឹងធ្វើឡើងនាពេលក្រោយៗទៀត។

តាមការជាក់ស្តែង គិតត្រឹមឆ្នាំ ២០១៩ មានតែអង្គការមិនមែនរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ប៉ុណ្ណោះដែលបានទទួលយកនូវការទទួលខុសត្រូវរបស់ខ្លួនមួយនេះ ពីព្រោះមន្ទីរជំនាញនៅថ្នាក់ខេត្ត មិនមានកញ្ចប់ថវិកាបែងចែកឲ្យសម្រាប់រ៉ាប់រងចំណាយទៅលើការចូលរួមរបស់អ្នកតំណាងរបស់ខ្លួននៅក្នុងការប្រជុំនេះទេ។ នៅក្នុងករណីដែលអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការគាំទ្រជនជាតិដើមភាគតិច និងដៃគូអភិវឌ្ឍន៍អាចផ្តល់ថវិកាជាប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយធ្វើដំណើរបាន នោះអ្នកតំណាងរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ទៅចូលរួមនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយការយល់ដឹងជាមួយសហគមន៍។

តាំងពីឆ្នាំ២០១៩ មន្ទីរអភិវឌ្ឍន៍ជនបទនៅតាមខេត្តបានទទួលកញ្ចប់ថវិកាប្រចាំឆ្នាំចំនួនដប់ប្រាំលានរៀល (ប្រហាក់ប្រហែល ៣,៧០០$) ជាពិសេសសម្រាប់គាំទ្រដំណើរការកំណត់ អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណា ក្នុងការអនុវត្ត ជាទូទៅ កញ្ចប់ថវិកាទាំងនេះត្រូវបានប្រើប្រាស់សម្រាប់សកម្មភាព ផ្សព្វផ្សាយទូទៅ (ដែលមិនចាំបាច់ទាល់តែពាក់ព័ន្ធសហគមន៍ជនជាតិដើមភាគតិចនោះទេ)និងការប្រារព្ធទិវាជនជាតិ ដើមភាគតិចពិភពលោក។

---

៥១ ទម្រង់ពាក្យស្នើសុំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ/លិខិតស្ម័យអត្តសញ្ញាណកម្ម និងបញ្ជីឈ្មោះសមាជិក។

### ❖ ភាពវែងអន្លាយ

ក្នុងស្ថានភាពបច្ចុប្បន្ន ដាទ្រីស្តី ដំណាក់កាលទី១ អាចធ្វើទៅបានតាមរយៈការប្រជុំត្រឹមតែប៉ុន្មានលើកប៉ុណ្ណោះ៖ ជាដំបូង គឺមន្ទីរថ្នាក់ខេត្តរបស់ក្រសួងអភិវឌ្ឍន៍ជនបទ (ប៉ុន្តែជាក់ស្តែង គឺអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលធ្វើការគាំទ្រជនជាតិដើមភាគតិច និង/ឬដៃគូអភិវឌ្ឍន៍ (DPs) ធ្វើការផ្សព្វផ្សាយការយល់ដឹងដល់សហគមន៍ អំពីសិទ្ធិរបស់ពួកគេជាជនជាតិដើមភាគតិចយោងតាមច្បាប់ប្រទេសទីពីរ គឺនៅពេលដែលសហគមន៍ជួបប្រជុំគ្នាដើម្បីប្រកាសអំពីបំណងរបស់ខ្លួន ក្នុងការធ្វើស្វ័យអត្តសញ្ញាណកម្មជាជនជាតិដើម ហើយដំណាក់កាលទីបី និងជាដំណាក់កាលចុងក្រោយ ដែលមានការងារបន្ទាប់នោះគឺបេសកកម្មបញ្ជាក់ភាពត្រឹមត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទពីថ្នាក់រាជធានីក្នុងគោលបំណងធានាថាក្រុម (ជនជាតិដើមភាគតិច) ពិតជាអាចរក្សាអត្តសញ្ញាណរបស់ខ្លួនជាជនជាតិដើមនិងដើម្បីធានាថាសមាជិករបស់សហគមន៍ជនជាតិដើមភាគតិច បានយល់ព្រមជាសមាជិកម្នាក់ នៃសហគមន៍ជនជាតិដើមភាគតិច។ បុគ្គលិកក្រសួងនៅថ្នាក់ជាតិបានសង្កេតឃើញថា ប្រសិនបើមិនមានបញ្ហាប្រឈមច្រើន ក្នុងការអនុវត្តដំណើរការនេះទេ នោះដំណាក់កាលទីមួយអាចត្រូវបានដោះស្រាយរួចរាល់ និងឯកភាពនៅក្នុងរយៈពេលតិចជាងពីរខែប៉ុណ្ណោះ។[៥២]

ទោះជាយ៉ាងនេះក្តី នៅក្នុងការអនុវត្តជាក់ស្តែង ដំណើរកានេះអាចមានសភាពស្មុគស្មាញច្រើន ហើយអាចតម្រូវឲ្យមានការប្រជុំជាច្រើន ដងជាមួយអាជ្ញាធរមូលដ្ឋានដែលជារឿយៗ ពួកគាត់មិនសូវស្ទាត់អំពីបញ្ញត្តិនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១និងបញ្ហាទូទៅរបស់ជនជាតិដើមភាគតិច ការប្រជុំផ្ទៃក្នុងច្រើនដងនៅក្នុងសហគមន៍ ជនជាតិដើមភាគតិច និងការចុះបេសកកម្មច្រើនដងពីមន្ទីរអភិវឌ្ឍន៍ជនបទថ្នាក់ខេត្ត និងពីមន្ត្រីក្រសួងថ្នាក់ជាតិ។

អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងដៃគូអភិវឌ្ឍន៍ (DPs) ដែលធ្វើការគាំទ្រការស្នើសុំ ប័ណ្ណកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច គឺមានភាពស្មុគស្មាញនៅនៅពេលអនុវត្ត ពោលគឺ ជារឿយៗវាបានកើតឡើងដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយមិនគោរពតាមច្បាប់និងសមត្ថភាពមានកម្រិតរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងការដោះស្រាយ

៥២ កិច្ចប្រជុំជាមួយនឹងប្រធាននាយកដ្ឋានកិច្ចការជនជាតិភាគតិចនៅក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៧។

វិវាទទាំងពីរនេះរួមបញ្ចូលគ្នា។ ក្នុងពេលខ្លះ ដំណាក់កាលទីមួយអាចប្រើប្រាស់ពេលវេលារហូតដល់២ឆ្នាំដើម្បីឲ្យចប់សព្វគ្រប់ហើយត្រូវចុះបេសកកម្មច្រើនដងដើម្បី "ដោះស្រាយ" ស្ថានការណ៍ដែលសហគមន៍កំពុងជាប់គាំង ជាពិសេសនៅ ពេលជម្លោះដីធ្លីកំពុងរីករាលដាលរវាងសហគមន៍ខ្លួនឯង ប៉ុន្តែជារឿយៗវិវាទកើតឡើងជាមួយ នឹងសម្បទានិកនៃដីសេដ្ឋកិច្ច និងជនចំណាកស្រុកដែលមិនមែនជាជនជាតិដើមភាគតិច និងជាមួយនឹងអាជ្ញាធរមូលដ្ឋានឯណោះទេ។

## ❖ ការចំណាយ

ដូចដែលបានថែងខាងលើ ភាពវែងអន្លាយ របស់ដំណើរការតម្រូវអោយមានបេសកកម្មច្រើនដងការចំណាយប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (DSA) និងសោហ៊ុយធ្វើដំណើរដល់អ្នកចូលរួម រួមទាំងអាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងក្រសួងធ្វើអោយប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ។ បទពិសោធន៍របស់ការិយាល័យ OHCHR ក្នុងការគាំទ្រដំណាក់កាលទីមួយ សម្រាប់សហគមន៍ជនជាតិដើមភាគតិចចំនួន៣នៅក្នុងតំបន់ជ្រលងភ្នំអារ៉ែង នៅចន្លោះឆ្នាំ២០១៦ និង២០១៩ គឺប្រើប្រាស់ថវិកាសរុបរហូត ដល់ចំនួនប្រមាណជា ៨០.០០០ ដុល្លារអាមេរិក។

ការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាទីភ្នាក់ងារដ៏សំខាន់ ក្នុងការត្រួតពិនិត្យដំណាក់កាលទី១នៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏ប្រឈមជាមួយនឹងកង្វះថវិកាសម្រាប់អនុវត្តសកម្មភាព របស់ខ្លួនដែរ។ ដូចដែលលើកឡើងរួចហើយ នៅក្នុងឆ្នាំ២០១៧ នាយកដ្ឋានដែលមានបុគ្គលិកចំនួន ២៣ នាក់នៅថ្នាក់ជាតិ ទទួលបានថវិកាប្រចាំឆ្នាំរបស់ខ្លួនក្នុងទឹកប្រាក់ចំនួន ៣០០លានរៀល (ប្រហាក់ប្រហែល ៨០.០០០ ដុល្លារអាមេរិក) ដែលទឹកប្រាក់នេះត្រូវបានប្រើប្រាស់មិនសម្រាប់តែការចុះបេសកកម្ម (រួមទាំងមធ្យោបាយ)បញ្ជាក់ភាពត្រឹមត្រូវប៉ុណ្ណោះទេ ក៏ប៉ុន្តែ ថែមទាំងការចំណាយទៅលើសម្ភារការិយាល័យ និងការរៀបចំប្រារព្ធពិធីនានាប្រចាំឆ្នាំ ដូចជាទិវាជនជាតិដើមភាគតិច នៅថ្ងៃទី៩ ខែសីហាជាដើម។ល។ ដែលត្រូវបានចាត់ទុកថាជាព្រឹត្តិការណ៍ដ៏សំខាន់ ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា និងសិទ្ធិរបស់ពួកគេដែលមានចែងនៅក្នុងវិធាន និងបទដ្ឋានសិទ្ធិមនុស្សរបស់ប្រទេស និងអន្តរជាតិ។ មានតែកញ្ចប់ថវិកាប្រម៉ាណជា ៣០,០០០ ដុល្លាអាមេរិកប៉ុណ្ណោះដែលបានប្រើប្រាស់សម្រាប់

ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច នេះបើតាមការប៉ាន់ប្រម៉ាណរបស់ក្រសួង[៩៣] ដែលទឹកប្រាក់នេះអាចគ្រប់គ្រាន់សម្រាប់តែការចុះបញ្ជីបានបីសហគមន៍តែប៉ុណ្ណោះ។ ដោយមកដល់ពេលនេះចុះបញ្ជីបានត្រឹម ១៥៤ សហគមន៍ក្នុងចំណោម ៤៥៥ សហគមន៍ប៉ុណ្ណោះ។ ដូច្នេះវានឹងត្រូវប្រើពេល១០០ ឆ្នាំដើម្បីចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចទាំងអស់នេះ។

កញ្ចប់ថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋានគឺត្រូវបានបែងចែកជាត្រីមាស មានន័យថានាយកដ្ឋាននឹងត្រូវបានទទួលកញ្ចប់ថវិកាមួយផ្នែករៀងរាល់ត្រីមាស ជាជាងបានទទួលម្តងទាំងអស់។ នេះបង្កអោយមានការលំបាកសម្រាប់មន្ត្រីនាយកដ្ឋានក្នុងការចុះ បេសកកម្មពេលចាំបាច់ ដោយសារថវិកាត្រូវបានចំណាយតាមត្រីមាសនីមួយៗ។ ជាសរុបមកមន្ត្រីរាជការទាំងនៅថ្នាក់ក្រសួង និងថ្នាក់ខេត្ត (ដែលត្រូវធ្វើការងារក្នុងដំណាក់កាលទីមួយ) និងមន្ត្រីមជ្ឈឹម (ដែលត្រូវបញ្ជាក់វាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច) មិនអាចចូលរួមកិច្ចប្រជុំសំខាន់ៗ នៅថ្នាក់មូលដ្ឋានបាន។

ដោយសារកង្វះខាតថវិកានៅឆ្នាំ២០១៦, ២០១៧, ២០១៨ និង ២០១៩ ក្រសួងអាចវាយតម្លៃបានត្រឹម ១០, ១១, ១៣ និង ៧ សហគមន៍តែប៉ុណ្ណោះ។ ហើយនៅឆ្នាំ២០២០ គឺបានត្រឹមតែ៣សហគមន៍តែប៉ុណ្ណោះ។

ថវិកាសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទនៅថ្នាក់ខេត្តក៏ជាមូលហេតុនៃក្តីកង្វល់ផងដែរ។ ដូចដែលបានកត់សម្គាល់ពីខាងដើម មន្ត្រីមន្ទីរតម្រូវឲ្យមានតួនាទីសំខាន់ នៅក្នុងការផ្សព្វផ្សាយការយល់ដឹងទៅ ដល់សហគមន៍ជនជាតិដើមភាគតិចនិងដល់អាជ្ញាធរមូលដ្ឋានអំពីសិទ្ធិរបស់ជនជាតិដើមភាគតិចដែលមានចែងនៅក្នុងច្បាប់ជាតិ (ជាពិសេស ច្បាប់ភូមិបាល និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច) និងគាំទ្រសហគមន៍ ក្នុងការរៀបចំខ្លួនដើម្បីធ្វើស្វ័យអត្តសញ្ញាណកម្មជាជនជាតិដើមភាគតិច។ ទោះជាយ៉ាងនេះក្តីទើបតែឆ្នាំ២០១៩រដ្ឋាភិបាលបានចាប់ផ្តើមវិភាជកញ្ចប់ថវិកាចំនួន១៥លាន

៩៣ ប្រភព៖ កិច្ចប្រជុំរវាងការិយាល័យOHCHR និងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទនៅថ្ងៃទី ០៨ កញ្ញា ២០២០

រៀល (ប្រហាក់ប្រហែល USD ៣,៧០០) ក្នុងមួយឆ្នាំដល់ការិយាល័យជនជាតិដើមភាគតិចរបស់មន្ទីរអភិវឌ្ឍន៍ជនបទតាមខេត្តដែលមានជនជាតិដើមភាគតិចរស់នៅ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមួយចំនួនមិនទាន់បានប្រើប្រាស់កញ្ចប់ថវិកានេះសម្រាប់ គាំទ្រការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចនៅឡើយទេ។

តាមការអនុវត្តជាក់ស្តែង មានតែអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលបានចាប់យកការទទួលខុសត្រូវចំពោះដំណាក់កាលទីមួយ និងតួនាទីរបស់ក្រសួងត្រូវបានបន្ថយមកត្រឹមការងារវាយតម្លៃដែលតម្រូវអោយធ្វើដោយមន្ត្រីមកពីថ្នាក់ជាតិ។ អវត្តមានមន្ត្រីមកពីក្រសួងក្នុងអំឡុងពេលដំណើរការ គឺជាផ្នែកមួយនៃការពន្យាពេលសម្រាប់ដំណាក់ទីមួយដោយហេតុថា ជារឿយៗវាកើតចេញពីភាពស្ទាក់ស្ទើរបស់មន្ត្រីថ្នាក់ក្រោមជាតិក្នុងការចុះហត្ថលេខាលើលិខិតស្នាមដែលត្រូវដាក់ជូនក្រសួងនៅភ្នំពេញ។

### ❖ វិសាលភាពនៃក្រុមដែលមានសិទ្ធិស្នើសុំចុះបញ្ជីដីសមូហភាព

ស្តែងចេញពីទស្សនៈនៃការប្រៀបធៀបនៅប្រទេសមួយចំនួនដែលមានការទទួលស្គាល់និងការពារសិទ្ធិកាន់កាប់ដីប្រពៃណី សិទ្ធិកាន់កាប់ដីសមូហភាពត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅតាមសហគមន៍ជនបទ។ នៅប្រទេសផ្សេងទៀត រួមទាំងកម្ពុជា សិទ្ធិកាន់កាប់ទាំងនោះត្រូវបាន រចនាឡើងដើម្បីឆ្លើយតបតម្រូវការ របស់ជនជាតិដើមភាគតិចតែប៉ុណ្ណោះ។ យន្តការនេះ តម្រូវអោយមានសេចក្តីត្រូវការដើម្បីជានាអត្តសញ្ញាណជនជាតិដើមភាគតិចរបស់ក្រុម និងលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ ស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។

ខណៈដែលមានការតស៊ូមតិជាច្រើនត្រូវបានធ្វើឡើងនៅកម្រិតអន្តរជាតិអំពីថាតើក្រុមអ្វីខ្លះដែលអាចចាត់ទុកថាជនជាតិដើមភាគតិចនោះ មកដល់ពេលនេះនៅមិនទាន់មាននិយមន័យជាក់លាក់ណាមួយត្រូវបានកំណត់ដោយស្ថាប័នប្រព័ន្ធសហប្រជាជាតិ ឬស្ថាប័នជំនាញនៅឡើយទេ។ ដោយឆ្លុះបញ្ចាំងពីវិសភាគភាពរបស់ជនជាតិដើមភាគតិច ទាំងរដ្ឋសមាជិកអង្គការសហប្រជាជាតិ និងជនជាតិដើមភាគតិចបានឯកភាពគ្នាថានិយមន័យ គឺមិនចាំបាច់ទេ ហើយជំនួសវិញដោយវិធីសាស្ត្រទូលំទូលាយផ្អែកលើការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចដោយជនជាតិ

ដើមភាគតិចខ្លួនឯង។[៥៤] ជាមួយគ្នានេះ អនុសញ្ញា ILO លេខ ១៦៩ ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យ មិនបានកំណត់និយមន័យជាក់លាក់ថាអ្នកណាជាជនជាតិដើមភាគតិច និងកុលសម្ព័ន្ធទេ ប៉ុន្តែបានពណ៌នាជាទូទៅថា ក្នុងគោលបំណងការពារប្រជាជន កត់សម្គាល់ថា ស្វ័យអត្តសញ្ញាណជាជនជាតិដើមភាគតិច ឬកុលសម្ព័ន្ធត្រូវបានចាត់ទុកថា ជាលក្ខខណ្ឌពីកំណើតសម្រាប់កំណត់ក្រុមប្រជាជននោះតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ត្រូវបានអនុវត្ត (មាត្រា ១.២)។

គណៈដែលរដ្ឋាភិបាលមានភាពស្របច្បាប់ដើរតួនាទីក្នុងការធានា ឬទទួលស្គាល់ការពិតរបស់ជនជាតិដើមភាគតិចដោយផ្អែកលើស្វ័យអត្តសញ្ញាណរបស់ពួកគេនោះ ដោយហេតុថា រាជរដ្ឋាភិបាលកម្ពុជាចេញប័ណ្ណកម្មសិទ្ធិសមូហភាព វាពិតជាមានលំហសម្រាប់កែសម្រួលដំណើរការ បច្ចុប្បន្នដោយកាត់បន្ថយចំនួនអាជ្ញាធរត្រូវ ចុះហត្ថលេខាជាដើម។ ស្របគ្នាជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធសិទ្ធិជនជាតិដើមភាគតិច នីតិវិធីរបស់រដ្ឋាភិបាលក្នុងការ "ទទួលស្គាល់" សហគមន៍ជនជាតិដើមភាគតិចគួរត្រូវបានកាត់បន្ថយអោយនៅតិចបំផុតនិងផ្អែកលើទស្សនៈរបស់សហគមន៍ចំពោះឋានៈជាជនជាតិដើមភាគតិចរបស់ពួកគេ ជាជាងការវាយតម្លៃរបស់ក្រសួងទៅលើការរស់នៅនិងប្រពៃណីរបស់ពួកគេ។ គួរមានការយកចិត្តទុកដាក់លើការកសាងសមត្ថភាពរបស់សហគមន៍ រួមទាំងការបង្កើតសហគមន៍អោយក្លាយជានីតិបុគ្គល និងតាមរយៈការបញ្ចូលគ្នារវាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង។

លទ្ធភាពមួយទៀតដែលអាចពិចារណាពង្រីកវិសាលភាពក្រុមមនុស្សដែលមានសិទ្ធិទទួលបានការទទួលស្គាល់។ គេឃើញការ

---

៥៤ ពន្យល់ពាក្យ "ជនជាតិដើមភាគតិច" ត្រូវបានចាត់ទុកថាជាភាពសម្បូរណ៍បែបនៃជនជាតិដើមភាគតិច និយមន័យផ្លូវការនៃពាក្យ "ជនជាតិដើមភាគតិច" នៅមិនទាន់មាននិយមន័យជាក់លាក់ណាមួយត្រូវបានកំណត់ដោយស្ថាប័នប្រព័ន្ធសហប្រជាជាតិនៅឡើយទេ។ ជំនួសទៅវិញ ប្រព័ន្ធសហប្រជាជាតិបានបង្កើតអោយមានការយល់ឃើញទាន់សម័យមួយស្តីពីពាក្យនេះដោយយោងទៅលើកត្តាតទៅនេះ៖ ស្វ័យអត្តសញ្ញាណថាជាជនជាតិដើមភាគតិចនៅថ្នាក់បុគ្គល និងទទួលស្គាល់ដោយសហគមន៍ថាជាសមាជិករបស់ពួកគេ។ មានវត្តមានជាបន្តបន្ទាប់តាំងពីមុនអាណានិគម និង/ឬតាំងទីលំនៅតាំងពីមុន។ មានទំនាក់ទំនងជិតដិតជាមួយដែនដី និងធនធានធម្មជាតិនៅជុំវិញ។ សង្គម សេដ្ឋកិច្ច ឬប្រព័ន្ធនយោបាយដាច់ដោយឡែក។ មានភាសារវប្បធម៌ និងជំនឿដាច់ដោយឡែក។ បង្កើតជាក្រុមសង្គមដែលមិនមានអំណាច។ ដោះស្រាយដើម្បីពង្រឹង និងស្តាឡើងវិញបរិស្ថាន និងប្រព័ន្ធរបស់ពួកគេថាជា ប្រជាជន និងសហគមន៍ដាច់ដោយឡែករបស់បុព្វបុរសរបស់ពួកគេ។ (ឯកសារ UNPFII factsheet "នរណាជាជនជាតិដើមភាគតិច?", អាននៅ: https://www.un.org/esa/socdev/unpfii/documents/៥session_factsheet១.pdf )

ទទួលស្គាល់សិទ្ធិប្រពៃណីរបស់សហគមន៍ដែលមិនមែនជនជាតិដើមភាគតិចមានការគាំទ្រកើនឡើង។ ការគាំទ្រនេះបង្ហាញឲ្យឃើញតាមរយៈការជ្រើសរើស និងដាក់ឲ្យអនុវត្តនូវគោលការណ៍ណែនាំដោយស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្ម (FAO) ស្តីពីអភិបាលកិច្ចដោយទទួលខុសត្រូវទៅលើសិទ្ធិអាស្រ័យផលពីដីជលផល(ផលនេសាទ) និងរុក្ខាប្រមាញ់(ព្រៃឈើ) នៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិឆ្នាំ២០១២ នៅក្នុងចំណោមគំនិតផ្តួចផ្តើមដទៃទៀត។ គោលការណ៍ណែនាំរបស់អង្គការ FAO បានបញ្ជាក់អំពីសារសំខាន់នៃការទទួលស្គាល់ និងការគោរពចំពោះអ្នកកាន់កាប់ សិទ្ធិកាន់កាប់ស្របច្បាប់ទាំងអស់ និងសិទ្ធិផ្សេងៗទៀតរបស់ពួកគេ ទោះបីជាសិទ្ធិនេះ ត្រូវបានទទួលស្គាល់ជាផ្លូវការ ឬយ៉ាងណា និងត្រូវអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានផ្សេងៗ ទៀតដែលមានប្រព័ន្ធសិទ្ធិតាមបែបប្រពៃណីរបស់ខ្លួន ដែលអនុវត្តស្វ័យអភិបាលកិច្ចទៅលើដីធ្លីជលផល និងរុក្ខាប្រមាញ់របស់ខ្លួនក៏ដោយ។ មានប្រទេសជាច្រើនបានជ្រើសរើសយកមកប្រើនិយមន័យទូលំទូលាយនៃពាក្យ "អ្នកកាន់កាប់សិទ្ធិដីធ្លីសហគមន៍" ជានិយមន័យដែលពង្រីកវិសាលភាពអត្ថន័យរបស់វាលើសពី "ក្រុមជនជាតិដើមភាគតិចដែលធ្វើស្វ័យអត្តសញ្ញាណកម្ម" ទៅជា"សហគមន៍ជនបទ ដែលមានមុខរបរ និងការប្រើប្រាស់ដី របស់ពួកគេជាយូរមកហើយ"។

តាមទស្សនៈរបស់ការិយាល័យ OHCHR វិសាលភាពរបស់ក្រុម (ជនជាតិដើមភាគតិច) ដែលមានសិទ្ធិទទួលបាន ប័ណ្ណកម្មសិទ្ធិដីសមូហភាពអាចពង្រីកបានដើម្បីដាក់បញ្ចូលរាល់សហគមន៍ទាំងអស់ដែលមានរបៀបរបបសិទ្ធិដីធ្លីប្រពៃណី។ វិធីសាស្ត្រនេះមិនត្រឹមតែស្របគ្នាជាមួយនឹងការវិវឌ្ឍជាអន្តរជាតិថ្មីៗដែលបានលើកឡើងអំពីការតម្រូវឲ្យទទួលស្គាល់ និងគោរពអ្នកកាន់សិទ្ធិកាន់កាប់ស្របច្បាប់ទាំងអស់-ទាំងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានឯទៀត (ពោល គឺការការពារ និងគាំពារសិទ្ធិដីធ្លីប្រពៃណីស្របច្បាប់ មិនមែនផ្តោតទៅលើតែជនជាតិដើមភាគតិចនោះទេ) និងចង់ឃើញដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពត្រូវបានកាត់បន្ថយមកត្រឹមតែពីរដំណាក់កាលប៉ុណ្ណោះ៖ ការចុះបញ្ជីជានីតិបុគ្គល និងការដាក់ពាក្យស្នើសុំ ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ បន្ថែមពីលើនេះ យន្តការនេះក៏អាចកាត់បន្ថយនូវភាពស្ទាក់ស្ទើរចិត្ត(ភាពគ្មានសុឆន្ទៈ)ដែល

ការិយាល័យ OHCHR ជារឿយៗបានដឹងនៅថ្នាក់មូលដ្ឋាន ដែលអាជ្ញាធរមូលដ្ឋានតែងតែស្ទាក់ស្ទើរក្នុងការជ្រើសរើសសហគមន៍មួយចំនួនជាជនជាតិដើមភាគតិច។

ការពង្រីកវិសាលភាព (និយមន័យ) ទៅដល់អ្នកកាន់កាប់សិទ្ធិដីសមូហភាពស្របច្បាប់ទាំងអស់នឹងតម្រូវឲ្យធ្វើវិសោធនកម្មច្បាប់ភូមិបាល និងអនុក្រឹត្យលេខ៨៣ដើម្បីដាក់បញ្ចូលសហគមន៍ជនបទផ្សេងៗទៀតដែលមានសិទ្ធិលើដីព្រៃពណី និងធនធានរបស់ខ្លួន។

## ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលកម្ពុជាដូចតទៅ៖

- បង្កើនការវិភាជកញ្ចប់ថវិកាដល់ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងអាជ្ញាធរមូលដ្ឋាន ដែលមានភារកិច្ចអនុវត្តន៍ដំណើរការចុះ បញ្ជីអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងធានាថាកញ្ចប់ថវិកានឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណងនេះ តែប៉ុណ្ណោះ។
- កាត់បន្ថយដំណាក់កាលទី១ អោយនៅតិចបំផុត អនុលោមតាមវិធាន និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។
- នៅពេលមានការកែសម្រួលនីតិវិធីនៃការចុះបញ្ជីដីសមូហភាពនេះ ស្នើឲ្យមានការផ្តល់ព័ត៌មាន ដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធប្រកបដោយការយកចិត្តទុកដាក់។ ឧទាហរណ៍៖ ចេញសេចក្តីណែនាំដល់គ្រប់រដ្ឋបាលស្រុកលម្អិតអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីដែលធ្វើការពាក់ព័ន្ធដំណើរការចុះបញ្ជីដីសមូហភាព (ជំហានទី១) អនុលោមតាមអនុក្រឹត្យលេខ១៨៤ អនក្រ/បក "ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក" ចុះថ្ងៃទី ០២ ធ្នូ ២០១៩ ។
- ដោយមានការគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ដៃគូអភិវឌ្ឍន៍ (DPs) ប្រសិនបើចាំបាច់ ត្រូវរៀបចំនូវការបណ្តុះបណ្តាលជាប្រព័ន្ធដល់អាជ្ញាធរមូលដ្ឋានគ្រប់កម្រិតតាមខេត្តដែលជនជាតិដើមភាគតិចកំពុងរស់នៅ អំពីដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) និងកាតព្វកិច្ចនីមួយៗរបស់ពួកគេនៅក្នុងដំណើរការនេះ។
- ពិចារណារកលទ្ធភាព ដោះស្រាយស្ថានភាពសហគមន៍មូលដ្ឋានដទៃទៀតដែលអនុវត្តសិទ្ធិប្រើប្រាស់ដីធ្លី បែបសមូហភាពដូចគ្នា។

## ដំណាក់កាលទី២ ៖ ការចុះបញ្ជីជានីតិបុគ្គល (ក្រសួងមហាផ្ទៃ)

### ការអនុវត្តបច្ចុប្បន្ន

ច្បាប់ភូមិបាលចែងថា ដីដែលម្ចាស់កម្មសិទ្ធិអាចកាន់កាប់ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ (ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា ៨)។[៥៥] ដោយផ្អែកលើកថាខណ្ឌនៅក្នុងច្បាប់ភូមិបាល – "រូបវន្តបុគ្គល ឬនីតិបុគ្គល"–អនុក្រឹត្យលេខ៨៣ចែងថាសហគមន៍ជនជាតិដើមភាគតិច ដែលមានបំណងកាន់កាប់ប័ណ្ណកម្មសិទ្ធិដីសមូហភាពត្រូវទទួលបានការទទួលស្គាល់ជានីតិបុគ្គលសិន (អនុក្រឹត្យលេខ៨៣៖ មាត្រា ៣[៥៦] និង មាត្រា ៥[៥៧])។

មាត្រា ៥ នៃអនុក្រឹត្យលេខ ៨៣ បានចែងលម្អិតថា សហគមន៍ជនជាតិដើមភាគតិចត្រូវមានលក្ខន្តិកៈដើម្បីស្នើសុំការ ចុះបញ្ជីជានីតិបុគ្គលជាមួយក្រសួងមហាផ្ទៃ។ ដោយមានគោលបំណង ចុះបញ្ជីដីសមូហភាព ថែរក្សាវប្បធម៌ប្រពៃណី ទំនៀមទម្លាប់ អត្តសញ្ញាណ ពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់សហគមន៍ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍របស់ខ្លួន។[៥៨] លក្ខន្តិកៈ នេះត្រូវដាក់ជូនក្រសួងមហាផ្ទៃដើម្បីបញ្ជាក់ភាពត្រឹមត្រូវ និងប្រើប្រាស់ជាផ្លូវការ ហើយនៅពេលអនុម័តហើយ នោះវានឹងផ្តល់ឲ្យជនជាតិដើមភាគតិចនូវឋានៈ ជានីតិបុគ្គលដែលត្រូវបានទទួលស្គាល់ស្របច្បាប់ ដោយអនុញ្ញាតឲ្យពួកគេអាចធ្វើជាម្ចាស់កម្មសិទ្ធិដីសមូហភាពបាន។ ក្រសួងមហាផ្ទៃ បានបង្កើតឡើងនូវ

៥៥ ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៨ ៖ "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមកម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជាដែលបានទទួលស្គាល់ដោយច្បាប់ថាជា នីតិបុគ្គល។" ចំណុចនេះត្រូវបានពង្រឹងដោយរដ្ឋធម្មនុញ្ញកម្ពុជា (១៩៩៣) ដែលនៅក្នុង មាត្រា ៤៤ បានចែងថា "មានតែរូបវន្តបុគ្គល រឺនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី"។

៥៦ អនុក្រឹត្យលេខ ៨៣ (២០០៩), មាត្រា ៣ ៖ "អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិចដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ លើដែនដីនៃព្រះជាណាចក្រកម្ពុជា។

៥៧ អនុក្រឹត្យលេខ ៨៣ (២០០៩), មាត្រា ៥ ៖ "គោលការណ៍ទូទៅ ដែលត្រូវអនុវត្តក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច មានដូចតទៅ ៖ ... សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ មានលក្ខន្តិកៈដែលបានចុះបញ្ជី និងមានការទទួលស្គាល់ជាផ្លូវការ អាចដាក់ពាក្យសុំចុះបញ្ជីដី កម្មសិទ្ធិសមូហភាពបាន។

៥៨ អនុក្រឹត្យលេខ ៨៣ (២០០៩), មាត្រា ៥ ៖ "គោលការណ៍ទូទៅ ដែលត្រូវអនុវត្តក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច មានដូចតទៅ ៖ ... សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ មានលក្ខន្តិកៈដែលបានចុះបញ្ជី និងមានការទទួលស្គាល់ជាផ្លូវការ អាចដាក់ពាក្យសុំចុះបញ្ជីដី កម្មសិទ្ធិសមូហភាពបាន។

ទម្រង់លិខិតគំរូ នៃបទដ្ឋានលក្ខន្តិកៈរបស់សហគមន៍។[៥៩]

ដំណើរការ ដើម្បីរៀបចំសេចក្តីព្រាងលក្ខន្តិកៈត្រូវបានធ្វើឡើងដោយយោងទៅតាមដំណាក់កាលដូចខាងក្រោម៖

១. កិច្ចប្រជុំដំបូងសម្រាប់សហគមន៍ជាមួយអ្នកតំណាងមកពីសាលាខេត្តរបស់ក្រសួងមហាផ្ទៃដើម្បីផ្សព្វផ្សាយលក្ខន្តិកៈ និងទម្រង់លិខិតនានា។

២. សិក្ខាសាលាពិគ្រោះយោបល់មួយចំនួនជាមួយសហគមន៍ដែលបានរៀបចំដោយសាលាខេត្តនិងអង្គការមិនមែនរដ្ឋាភិបាល (NGO)/ដៃគូអភិវឌ្ឍន៍ (DP) ដែលគាំទ្រសហគមន៍ជនជាតិដើមភាគតិចក្នុងការព្រាងលក្ខន្តិកៈសហគមន៍។[៦០]

៣. នៅពេលសម្រេចព្រមព្រៀងទៅលើខ្លឹមសារសេចក្តីព្រាងនៃលក្ខន្តិកៈ រួចហើយនោះត្រូវផ្ញើជូនអង្គភាពអន្តរវិស័យរបស់សាលាខេត្ត បន្ទាប់មកអង្គភាពនេះនឹងបញ្ជូនឯកសារទាំងនោះទៅនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ នៃអគ្គនាយកដ្ឋានរដ្ឋបាលរបស់ក្រសួងមហាផ្ទៃដើម្បីស្នើសុំមន្ត្រីក្រសួងចុះមកពិនិត្យខ្លឹមសារ។

៤. សហគមន៍ស្នើសុំការអនុញ្ញាតដើម្បីបើកមហាសន្និបាតមួយពីអភិបាលនៃគណៈអភិបាលខេត្ត។ បន្ទាប់ពីសំណើនេះ អភិបាល នឹងចេញលិខិតអញ្ជើញទៅគ្រប់ភាគីពាក់ព័ន្ធនានានៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិមិនឲ្យហួសពីរយៈពេល ១៥ ថ្ងៃមុនកាលបរិច្ឆេទកំណត់បើកមហាសន្និបាតឡើយ។ នាមហាសន្និបាតសហគមន៍ នោះនឹងធ្វើការពិនិត្យ និងពិភាក្សាដើម្បីសំរេចអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈព្រមទាំងជ្រើសតាំងគណៈកម្មាធិការសហគមន៍។

៥. បន្ទាប់ពីសហគមន៍បានប្រជុំអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងជ្រើសតាំងគណៈកម្មាធិការសហគមន៍រួចរាល់មកប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវបញ្ជូនលិខិតស្នើសុំការចុះបញ្ជីជានីតិ

---

៥៩ សៀវភៅណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃស្តីពីដំណើរការសម្រាប់បង្កើតសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល ឆ្នាំ ២០១០ ឧបសម្ព័ន្ធ ៖ ទម្រង់លិខិតលេខ ៦។

៦០ សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណនៃជនជាតិដើមភាគតិច ការតាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការគូរផែនទីបឋម ការវិនិច្ឆ័យដី និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (Kirsten Ewers Andersen និង Loeung Kesaro, គាំទ្រដោយអង្គការ GIZ),ទំព័រ ១១។

បុគ្គល និងឯកសារភ្ជាប់ (ចំនួនប្រាំច្បាប់) ទៅកាន់ក្រសួងមហាផ្ទៃនៅ រាជធានីភ្នំពេញ។ លិខិតនេះត្រូវចុះហត្ថលេខាដោយអាជ្ញាធរថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត ហើយត្រូវភ្ជាប់ជាមួយនូវឯកសារភ្ជាប់ដូចខាងក្រោម ៖

- បញ្ជីសមាជិករួម ចំនួន ២(ពីរ)ច្បាប់ (ដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់)
- លិខិតទទួល ស្គាល់អត្តសញ្ញាណសហគមន៍ដោយក្រសួងអភិវឌ្ឍន៍ជនបទ
- លក្ខន្តិកៈសហគមន៍ ចំនួន ២(ពីរ) ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់គណៈកម្មាធិការសហគមន៍ ក្នុងម្នាក់ៗ ចំនួន ២(ពីរ) ច្បាប់ដោយភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬឯកសារពាក់ព័ន្ធនានា (ច្បាប់ថតចម្លង)
- សេចក្តីសម្រេចរបស់ឃុំស្តីពីការទទួលស្គាល់លក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ ចំនួន ២(ពីរ)ច្បាប់
- សំណើសុំ ចុះឈ្មោះសហគមន៍ទៅក្រសួងមហាផ្ទៃ ចំនួន២(ពីរ)ច្បាប់។

នៅពេលក្រសួងមហាផ្ទៃបានឯកភាពទៅលើលក្ខន្តិកៈនិងទៅលើគណៈកម្មការគ្រប់គ្រងសហគមន៍រួចហើយ ក្រសួងនឹងចេញលិខិតមួយទទួលស្គាល់សហគមន៍ជានីតិបុគ្គល ហើយអ្នកតំណាងក្រសួងមហាផ្ទៃនឹងចូលរួម ជាមួយនឹងសហគមន៍រួមជាមួយនឹងអ្នកតំណាងរបស់ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងដៃគូអភិវឌ្ឍន៍ (DPs) នៅក្នុងពិធី ដែលសហគមន៍ទទួលបានលិខិតទទួលស្គាល់ជានីតិបុគ្គលមកកាន់នៅក្នុងដៃរបស់ខ្លួន។ទោះបីជាក្រសួងអភិវឌ្ឍន៍ជនបទមិនតម្រូវឲ្យចូលរួមនៅក្នុងការប្រជុំពីខាងលើនេះក៏ដោយ ក៏អ្នកតំណាងរបស់ក្រសួងអាចនឹងចូលរួមបានដែរ ប្រសិនបើមានការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងពីដៃគូអភិវឌ្ឍន៍ (DPs)។

## បញ្ហា

### ❖ កង្វះខាតមូលដ្ឋានច្បាប់

ការវិភាគទៅលើបទពិសោធន៍ល្អៗរបស់ប្រទេសផ្សេងៗ ដែលមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនឹងជួយផ្តល់នូវការណែនាំខាងគោលនយោបាយប្រកបដោយ សារប្រយោជន៍មួយ។ ដូចដែលបានកត់សម្គាល់ពីខាងដើម ដំណើរការដែលបានបង្កើតឡើង

ដើម្បីទទួលស្គាល់ជាផ្លូវការនូវសិទ្ធិរបស់ក្រុម (ជនជាតិដើមភាគតិច) ក្នុងការទទួលបានដីប្រពៃណី និងធនធានរបស់ខ្លួន គឺមានភាពខុសៗគ្នាយ៉ាងខ្លាំងនៅគ្រប់ប្រទេសទាំងអស់។ យ៉ាងនេះក្តី លក្ខខណ្ឌតម្រូវ ដែលឲ្យក្រុម (ជនជាតិដើម) ត្រូវបានទទួលស្គាល់ និងបានចុះបញ្ជីជានីតិបុគ្គលសិន គឺមានជាទូទៅ។ ឧទាហរណ៍ ប្រទេសដូចជាអាហ្វ្រិកខាងត្បូង[៦១] ប៉ាពូញូវហ្គីណេ[៦២] ឥណ្ឌូណេស៊ី[៦៣] ហ្កាណា[៦៤] បុស្វាណា[៦៥] លីបេរីយ៉ា[៦៦] និងម៉ូហ្សំប៊ិក[៦៧] ដែលប្រទេសទាំងអស់នេះតម្រូវឲ្យសហគមន៍ និងក្រុម (ជនជាតិដើមភាគ

---

៦១ ច្បាប់ស្តីពីសមាគមគ្រប់គ្រងទ្រព្យសម្បត្តិសហគមន៍របស់ប្រទេសអាហ្វ្រិកខាងត្បូង ឆ្នាំ ១៩៩៦ ៖ ច្បាប់នេះក៏អនុញ្ញាតឲ្យក្រុម (ជនជាតិដើម) តាមប្រពៃណីធ្វើការចុះបញ្ជីផងដែរដើម្បីទទួលបានកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិអនុលោមតាមលក្ខន្តិកៈជាលាយលក្ខណ៍អក្សរដែលបានព្រមព្រៀង។ សូមមើល Fitzpatrick, D:'បណ្តាជម្រើសអនុវត្តប្រសើរបំផុតសម្រាប់ទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិកាន់កាប់ដីតាម ប្រពៃណី ២០០៥, ៤៦១។

៦២ ច្បាប់ស្តីពីការចុះបញ្ជីដីធ្លីរបស់ក្រុមជនជាតិដើមភាគតិចប្រទេសប៉ាពូ ញូវ ហ្គីណេ ឆ្នាំ ១៩៧៤ បានអនុញ្ញាតឲ្យក្រុមជនជាតិដើមតាមប្រពៃណីធ្វើការចុះបញ្ជីជានីតិបុគ្គលផ្លូវការដោយមានសមត្ថភាពកាន់កាប់ គ្រប់គ្រង និងចាត់វិធានការចំពោះដី អនុលោមតាមសិទ្ធិផ្ទាល់របស់ខ្លួន។ ដើម្បីចុះបញ្ជី នោះក្រុមជនជាតិដើម ត្រូវរៀបចំនូវលក្ខន្តិកៈជាលាយលក្ខណ៍អក្សរ ដែលចែងអំពីលក្ខណៈសម្បត្តិសម្រាប់សមាជិកភាព ប្រភេទនៃស្ថាប័នគ្រប់គ្រងរបស់សហគមន៍ ប្រភេទនៃស្ថាប័នមានសិទ្ធិអំណាចដោះស្រាយវិវាទ របៀបដែលនីតិបុគ្គលធ្វើសកម្មភាព និងទម្រង់ដែលសកម្មភាពទាំងនោះបង្ហាញចេញមក។ សូមមើលឯកសាររបស់លោក Fitzpatrick, D ៖ 'បណ្តាជម្រើសអនុវត្តប្រសើរបំផុតសម្រាប់ទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិកាន់កាប់ដីតាមប្រពៃណី ២០០៥, ៤៦០-៦១។

៦៣ យោងតាមច្បាប់កិច្ចការព្រៃឈើ ឆ្នាំ ១៩៩៩ ដើម្បីទទួលបានសិទ្ធិក្នុងការកាន់កាប់ដីព្រៃឈើ នោះសហគមន៍ត្រូវបានទទួលស្គាល់ដោយច្បាប់សិនតាមរយៈការប្រកាសឲ្យប្រើនូវបទប្បញ្ញត្តមួយដែលមានចែងអំពីសិទ្ធិតាមប្រពៃណីរបស់ពួកគេ (មាត្រា ៦៧.២) ក្នុងចំណោមបណ្តាលក្ខខណ្ឌផ្សេងៗទៀត។ សូមមើលឯកសាររបស់អង្គការ USAID ៖ ការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លី និងធនធានសហគមន៍ ៖ ការពិនិត្យមើលបទពិសោធន៍ប្រទេស ២០១៦, ១៥។

៦៤ ច្បាប់ចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីរបស់ប្រទេសហ្កាណា ឆ្នាំ ១៩៨៦ តម្រូវថាដីដែលនៅក្រោមកម្មសិទ្ធិតាមប្រពៃណីត្រូវចុះបញ្ជីនៅក្រោមលក្ខខណ្ឌជានីតិបុគ្គល ប៉ុន្តែច្បាប់នេះមិនទាន់បានអនុវត្តនៅឡើយទេ នៅក្នុងតំបន់ជនបទ។ សូមមើលឯកសាររបស់អង្គការ USAID ៖ ការទទួលស្គាល់ដីសហគមន៍ និងសិទ្ធិកាន់កាប់ធនធាន ៖ កាពិនិត្យមើលបទពិសោធន៍ប្រទេស ២០១៦, ៣១។

៦៥ ប្រទេសបុស្វាណាគឺជាប្រទេសទីមួយនៅក្នុងចំណោមបណ្តាប្រទេសនៅក្នុងទ្វីបអាហ្វ្រិក ដែលទទួលស្គាល់ ធ្វើទំនើបកម្ម និងបញ្ចូល គ្នាជាប្រព័ន្ធនូវសិទ្ធិកាន់កាប់ដីតាមប្រពៃណី។ ដីដែលបានកាន់កាប់តាមប្រពៃណីត្រូវបានបម្លែងទៅជាប័ណ្ណកម្មសិទ្ធិផ្លូវការ ទទួលស្គាល់តាមផ្លូវច្បាប់ និងសុវត្ថិភាព ហើយនិងត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាដីធ្លីដែលបានចុះបញ្ជីស្របច្បាប់ ដែលមានសមភាពដូចជា ប្រធាន (ជនជាតិដើមភាគតិច) តាមប្រពៃណី សមាជិកតែងតាំងដោយរដ្ឋាភិបាល និងអ្នកតំណាងដែលបានបោះឆ្នោតដោយសហគមន៍។ សូមមើលឯកសាររបស់អង្គការ USAID ៖ ការទទួលស្គាល់សិទ្ធិកាន់កាប់ដីនិងធនធានសហគមន៍ ៖ ការពិនិត្យមើលបទពិសោធន៍ប្រទេស ឆ្នាំ ២០១៦, ៣២។

៦៦ គោលនយោបាយស្តីពីសិទ្ធិដីធ្លីរបស់ប្រទេសលីបេរីយ៉ា ឆ្នាំ ២០១៣ បានស្នើថារដ្ឋាភិបាលត្រូវជួយសហគមន៍ក្នុងការធ្វើស្វ័យអត្តសញ្ញាណកម្ម ទទួលនូវប័ណ្ណកម្មសិទ្ធិដីធ្លី និងបង្កើតសហគមន៍ជានីតិបុគ្គល នៅក្នុងចំណោមបណ្តាកិច្ចការផ្សេងៗទៀត។ សូមមើលឯកសាររបស់អង្គការ USAID ៖ ការទទួលស្គាល់សិទ្ធិកាន់កាប់ដី និងធនធានសហគមន៍ ៖ ការពិនិត្យមើលបទពិសោធន៍ប្រទេស ឆ្នាំ ២០១៦, ៣៦។

៦៧ អង្គការ USAID ៖ ការទទួលស្គាល់សិទ្ធិកាន់កាប់ដី និងធនធានសហគមន៍ ៖ ការពិនិត្យមើលបទពិសោធន៍ប្រទេស ឆ្នាំ ២០១៦, ៣៨។

តិច) ចុះបញ្ជីជានីតិបុគ្គលដែរដើម្បីកាន់កាប់ជាម្ចាស់កម្មសិទ្ធិដីសមូហភាព និង/ឬសិទ្ធិគ្រប់គ្រង។

ការចុះបញ្ជីសហគមន៍ជានីតិបុគ្គល ក្នុងគោលបំណងចុះបញ្ជីដីធ្លីត្រូវបានយល់ជាទូទៅថាធ្វើឡើងដើម្បីលើកកម្ពស់ភាពច្បាស់លាស់សម្រាប់សហគមន៍ខណៈដែលអាចកាត់បន្ថយលទ្ធភាពពីការកេងប្រវ័ញ្ចបាន ផងដែរ។[៦៨] រចនាសម្ព័ន្ធជានីតិបុគ្គលនេះ ផ្តល់ឲ្យក្រុម (ជនជាតិដើមភាគតិច) នូវអត្តសញ្ញាណស្របច្បាប់ផ្លូវការរបស់ខ្លួន និងអនុញ្ញាតឲ្យក្រុម (ជនជាតិដើមភាគតិច)-ប្រសិនបើក្រុមមានបំណងធ្វើដូច្នេះ-អាចចុះកិច្ចព្រមព្រៀងប្រតិបត្តិការដែលមានការធានាស្របច្បាប់ជាមួយវិនិយោគិនមកពីខាងក្រៅ។ ផ្ទុយមកវិញ រចនាសម្ព័ន្ធនីតិបុគ្គលនេះ ក៏ធ្វើឲ្យមានការកំណត់បញ្ញត្តិជាក់លាក់មួយចំនួននៅក្នុងរដ្ឋធម្មនុញ្ញ ជាពិសេសពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្ត និងការបែងចែកអត្ថប្រយោជន៍ និងធានាថាការធ្វើសេចក្តីសម្រេចចិត្ត និងការចែករំលែកផលប្រយោជន៍ត្រូវបានធ្វើឡើងដោយត្រឹមត្រូវ និងសមធម៌ យោងតាមទ្រឹស្តី។[៦៩]

នៅក្នុងប្រទេសកម្ពុជា ទោះបីជាមាត្រា ២៣ នៃច្បាប់ភូមិបាលចែងថា ការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះសហគមន៍ជនជាតិដើមភាគតិច អាចធ្វើទៅបាន "នៅក្រោមការកំណត់នៃច្បាប់ទៅលើលក្ខន្តិកៈសហគមន៍" ក៏ដោយ ក៏កន្លងផុតទៅរាប់សិបឆ្នាំ បន្ទាប់ពីច្បាប់ភូមិបាល និងអនុក្រឹត្យលេខ ៨៣ ត្រូវបានអនុម័ត (នៅក្នុងឆ្នាំ ២០០១ និងឆ្នាំ ២០០៩ រៀងៗនីមួយៗ) មិនមានច្បាប់ណាមួយដែលបញ្ញត្តិឲ្យមានការបង្កើតជាសមាគម ឬជាសហគមន៍ជនជាតិដើមភាគតិច ជានីតិបុគ្គលឡើយ។[៧០] សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច នោះការអនុវត្តបច្ចុប្បន្នដោយតម្រូវឲ្យរៀបចំបង្កើតជាលក្ខន្តិកៈ កើតមានឡើងនៅក្នុងបរិបទនៃគម្រោងសាកល្បងរបស់ក្រុម

---

៦៨ Fitzpatrick, D ៖ 'បណ្តាជម្រើសអនុវត្តប្រសើរបំផុតសម្រាប់ទទួលស្គាល់តាមផ្លូវច្បាប់ នូវសិទ្ធិកាន់កាប់ដីតាមប្រពៃណី ២០០៥, ៤៦០

៦៩ Fitzpatrick, D: 'បណ្តាជម្រើសអនុវត្តប្រសើរបំផុតសម្រាប់ទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិកាន់កាប់ដីតាមប្រពៃណី ២០០៥, ៤៦០។

៧០ អនុក្រឹត្យ ឆ្នាំ ២០០១ ស្តីពីការទទួលស្គាល់ជនជាតិដើមភាគតិចជានីតិបុគ្គលត្រូវបានព្រាងដោយលោក Janet King ជាទីប្រឹក្សាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យ៉ាងនេះក្តី អនុក្រឹត្យនេះមិនត្រូវបានអនុម័តដោយក្រសួងទេ ហេតុដូច្នេះហើយមិនត្រូវបានបញ្ជូនឲ្យក្រុមប្រឹក្សាគោលនយោបាយដីធ្លីអនុម័តទេ។ សូមមើលឯកសាររបស់អង្គការ GTZ-Cambodia ៖ គម្រោងគ្រប់គ្រងដីធ្លី ៖ បញ្ហាច្បាប់ពាក់ព័ន្ធនឹងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ដែលរៀបចំឡើងដោយលោក Susie Brown លោក Katrin Seidel និងលោក Todd Sigaty ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៥។

ប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីត្រួតពិនិត្យរបៀបអនុវត្តបញ្ញត្តិដែលចែងនៅក្នុងច្បាប់ភូមិបាល ទាក់ទងជាមួយនឹងប័ណ្ណកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច។[៧១]

មុនការ ប្រើប្រាស់ច្បាប់ថ្មីស្តីពីការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាទូទៅ ត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃតាមរយៈលិខិតរបស់ក្រសួង។បន្ទាប់មក ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០១៥។[៧២] វាមិនច្បាស់លាស់ទេថាតើច្បាប់នេះអាចអនុវត្ត ឬគួរអនុវត្តទៅលើសហគមន៍ជនជាតិដើមភាគតិចដែលមានបំណងចុះបញ្ជីជានីតិបុគ្គលក្នុងកម្រិតណា។[៧៣] ឧទាហរណ៍ ទោះបីជាការតម្រូវរបស់ច្បាប់ទៅលើឯកសារ ដែលត្រូវដាក់ជូនដោយសមាគមក្នុងស្រុក វាចាំបាច់ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជី[៧៤] ហើយជាទូទៅ ឯកសារទាំងនោះ ដូចគ្នាជាមួយនឹងសំណុំឯកសារសម្រាប់សហគមន៍ ជនជាតិដើមភាគតិចក៏ដោយ[៧៥] ក៏ការកំណត់ក្របខ័ណ្ឌពេលវេលាសម្រាប់ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យពាក្យស្នើសុំដែលដាក់ជូនដោយសមាគមក្នុងស្រុក គឺមានរយៈពេល ៤៥ ថ្ងៃជាអតិបរមា[៧៦] ខណៈដែលមិនមានការកំណត់ក្របខ័ណ្ឌពេលវេលានេះសម្រាប់ពិនិត្យពាក្យស្នើសុំរបស់សហគមន៍ជនជាតិដើមភាគតិចនោះឡើយ។

### ❖ ភាពវែងអន្លាយ

ក្នុងពេលបច្ចុប្បន្នការប៉ាន់ប្រមាណដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលគាំទ្រសហគមន៍ជនជាតិដើមភាគតិច និងក្រសួងមហាផ្ទៃបានលើកឡើងថា រយៈពេលសម្រាប់ដំណាក់កាលនេះ គឺមានចំនួន ១.៥–២ ឆ្នាំ ភាគច្រើនដោយសារតែការជួបប្រទះ

៧១ ការគាំទ្ររបស់អង្គការ ILO ដល់គម្រោងជនជាតិដើមភាគតិចនៅកម្ពុជា – ការតាក់តែងលក្ខន្តិកៈរបស់ជនជាតិដើមភាគតិច ៦។

៧២ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥។

៧៣ យ៉ាងនេះក្តី ក្រសួងមហាផ្ទៃ នៅក្នុងការប្រជុំជាមួយនឹងការិយាល័យ OHCHR នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១៧ បានថ្លែងថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) មិនអនុវត្តចំពោះការចុះបញ្ជីរបស់ជនជាតិដើមភាគតិចឡើយ។

៧៤ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មាត្រា ៦-៧។

៧៥ ឧទាហរណ៍ ៖ ប្រូហ្វាល (ប្រវត្តិរូបសង្ខេប) របស់សមាជិកស្ថាបនិក - ឬសម្រាប់ករណីជាសហគមន៍ជនជាតិដើមភាគតិច ៖ សមាជិកគណៈកម្មការគ្រប់គ្រង- ប្រភពនៃធនធាន និងទ្រព្យសម្បត្តិ និងបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងរបស់ពួកគេ។

៧៦ ប្រសិនបើក្រសួងមហាផ្ទៃមិនអាចឆ្លើយតបទៅនឹងការកម្រិតពេលវេលានេះទេ នោះសមាគមក្នុងស្រុកនឹងត្រូវចាត់ទុកថាបានចុះបញ្ជីតាមច្បាប់ ពាក់ព័ន្ធជាមួយនឹងមាត្រា ៨។

បញ្ហាមួយចំនួននៅក្នុងដំណើរការនីតិវិធី[៧៧]។ តាមការគណនាចំណាយនៅក្នុងដំណាក់កាលនេះដោយអង្គការមិនមែនរដ្ឋាភិបាលឃើញថា ការចំណាយសរុប គឺក្នុងចន្លោះពី៧០០០ទៅ ១០.០០០ ដុល្លារអាមេរិក។[៧៨]

### ❖ ដំណាក់កាលមិនចាំបាច់ ឬមិនត្រូវកន្លែង?

ការតម្រូវឲ្យសហគមន៍ត្រូវចុះបញ្ជីជានីតិបុគ្គលជាមុនសិន គឺផ្ទុយពីច្បាប់ភូមិបាលកម្ពុជា ដែលគ្រាន់តែតម្រូវថាសហគមន៍ត្រូវចុះបញ្ជីជានីតិបុគ្គលប៉ុណ្ណោះ "មុនកាន់កាប់ប័ណ្ណកម្មសិទ្ធិរបស់ខ្លួនមិនមែនមុនដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិរបស់ខ្លួន"[៧៩] ទេ។ ទោះបីជាកត់សម្គាល់ឃើញថា មានប្រទេសមួយចំនួនតម្រូវឲ្យសហគមន៍ ចុះបញ្ជីជានីតិបុគ្គលដើម្បីកាន់កាប់ដីសហគមន៍ក៏ដោយ ក៏មានប្រទេសជាច្រើនទៀត ការទទួលស្គាល់សហគមន៍ជានីតិបុគ្គល មិនមែនជាបុរេលក្ខខណ្ឌចាំបាច់ឡើយ ប៉ុន្តែការទទួលស្គាល់អាចធ្វើឡើងបានដោយសារមានការឯកភាពទៅលើការស្នើសុំដីរួចហើយ ឬសូម្បីតែនៅក្រោយពេលប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានផ្តល់ជូនសហគមន៍រួចហើយក៏ដោយ។

**ករណីសិក្សា៖ ឧទាហរណ៍មកពីប្រទេសម៉ូស្សាំប៊ិក**

ករណីនៃប្រទេសម៉ូហ្សំប៊ិកបានផ្តល់នូវការប្រៀបធៀបដ៏ល្អមួយ។ ទម្រង់នៃការទទួលស្គាល់តាមផ្លូវច្បាប់របស់ប្រទេសម៉ូហ្សំប៊ិកទៅលើសិទ្ធិកាន់កាប់ដី ត្រូវបានហៅថា *'direito de uso e aproveitamento da terra'* (*ហៅកាត់ថា DUAT*) និងដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ១៩៩៧ (*Lei de Terra*) របស់ប្រទេស។ បញ្ញត្តិដ៏សំខាន់មួយនៅក្នុងចំណោមបញ្ញត្តិសំខាន់ៗបំផុតរបស់ច្បាប់ភូមិបាលគឺនិយមន័យនិងការទទួលស្គាល់តាម

---

៧៧ យោងតាមកិច្ចសម្ភាសរបស់ការិយាល័យOHCHR ជាមួយអង្គការក្រៅរដ្ឋាភិបាលបង្ហាញថា ភាពយឺតយ៉ាវរបស់ដំណើរការចុះបញ្ជីគឺកើតចេញពីការទន្ទ្រានដីខុសច្បាប់ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច ហើយនិងសមត្ថភាពមានកម្រិតរបស់អាជ្ញាធរមូលដ្ឋាន ឬភាពគ្មានសុឆន្ទៈរបស់ពួកគេក្នុងការដោះស្រាយស្ថានការណ៍ ដែលអនុគ្រោះដល់ជនជាតិដើមភាគតិច។

៧៨ ការព្យាករណ៍ចំណាយ ផ្តល់ដោយអង្គការ ICSO។

៧៩ A/HRC/១២/៣៤/Add.១, paragraph ២០, បានបញ្ជាក់បន្ថែម។

ផ្លូវច្បាប់របស់ច្បាប់នេះទៅលើពាក្យ "សហគមន៍មូលដ្ឋាន" ជានីតិបុគ្គលផ្លូវការ។[៨០] តាមរយៈការទទួលស្គាល់នេះ សហគមន៍មូលដ្ឋានដែលជ្រើសរើសកំណត់ព្រំប្រទល់របស់ខ្លួន ហើយដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្រសម្គាល់ព្រំដី (ប័ណ្ណកម្មសិទ្ធិដីធ្លី) *នឹងត្រូវបានចាត់ទុកជានីតិបុគ្គលដោយស្វ័យប្រវត្តិសម្រាប់គោលបំណងនៃការកាន់កាប់ដី*។ ក្នុងឋានៈជាអ្នកកាន់កាប់វិញ្ញាបនប័ត្រសម្គាល់ព្រំប្រទល់ សហគមន៍ទទួលបាននីតិសម្បទាស្របច្បាប់ ដូច្នេះហើយអាចចុះកិច្ចសន្យាជាមួយនឹងវិនិយោគិន បើកគណនីធនាគារ និងចាត់វិធានការតាមផ្លូវច្បាប់ផ្សេងៗនៅក្នុងប្រទេសបាន។[៨១] ឧទាហរណ៍នៃប្រទេសម៉ូហ្សំប៊ិកបានបង្ហាញឲ្យឃើញថា ការទទួលស្គាល់សហគមន៍មួយ ជានីតិបុគ្គលមិនចាំបាច់ជាដំណាក់កាលមួយដាច់តែឯងនោះទេ ប៉ុន្តែអាចអនុវត្តវារួមគ្នាជាមួយនឹងដំណាក់កាលផ្សេងៗទៀតនៅក្នុងដំណើរការចុះបញ្ជីដីសមូហភាពបាន (រួមមានដូចជាការទទួលស្គាល់ដោយស្វ័យប្រវត្តិបន្ទាប់ពីពាក្យស្នើសុំត្រូវបានដាក់ជូន និងឯកភាពរួចរាល់)។

សម្រាប់ប្រទេសកម្ពុជា ការបញ្ចូលគ្នានូវការតាក់តែងលក្ខន្តិកៈសហគមន៍ជាមួយនឹងដំណាក់កាលណាមួយទៀតនៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ នឹងអាចកាត់បន្ថយចំនួនទីភ្នាក់ងាររបស់រដ្ឋាភិបាលដែលចូលរួមពាក់ព័ន្ធ ហើយតាមរយៈការធ្វើដូច្នេះ វាកាត់បន្ថយយ៉ាងច្រើននូវរយៈពេលដែលត្រូវចំណាយចុះទៅមូលដ្ឋាន។

### ❖ តម្រូវការញែកលក្ខន្តិកៈសហគមន៍ពីការចុះបញ្ជីជានីតិបុគ្គល

បញ្ហាទីបីមួយទៀតសម្រាប់ពិចារណា គឺពាក់ព័ន្ធជាមួយនឹងអ្វីដែលក្រសួងត្រូវទទួល

៨០ អង្គការ FAO ៖ ការទទួលស្គាល់តាមលក្ខន្តិកៈទៅលើសិទ្ធិដីប្រពៃណីនៅក្នុងទ្វីបអាហ្វ្រិក IV ម៉ូហ្សំប៊ិក , ១២ អាចស្វែងរកបាននៅតំណ http://www.fao.org/docrep/០១៣/i១៩៤៥e/i១៩៤៥e០២.pdf. ច្បាប់បានកំណត់និយមន័យនៃពាក្យសហគមន៍មូលដ្ឋានថាជា "ការប្រមូលផ្តុំគ្នាជាក្រុម នូវគ្រួសារ និងបុគ្គលម្នាក់ ដែលរស់នៅលើដែនដីក្នុងកម្រិតតំបន់ ឬតូចជាង ដែលស្វែងរកការការពារនូវផលប្រយោជន៍រួមរបស់ពួកគេ" និយមន័យនេះគឺផ្អែកទៅលើមុខរបរចិញ្ចឹមជីវិត និងការប្រើប្រាស់ដីតាមបែបប្រពៃណីរបស់សហគមន៍ (ដោយផ្អែកលើការប្រើប្រាស់ដីជាទូទៅ ញាតិសណ្តាន និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់សហគមន៍នីមួយៗ) និងត្រូវបានកំណត់ដើម្បីឲ្យអាចប្រើប្រាស់បាននៅក្នុងបរិបទវប្បធម៌ខុសៗគ្នា។

៨១ អង្គការ FAO ៖ ការទទួលស្គាល់តាមលក្ខន្តិកៈទៅលើសិទ្ធិដីប្រពៃណីនៅក្នុងទ្វីបអាហ្វ្រិក IV ម៉ូហ្សំប៊ិក , ១២ អាចស្វែងរកបាននៅតំណភ្ជាប់ http://www.fao.org/docrep/០១៣/i១៩៤៥e/i១៩៤៥e០២.pdf.

ខុសត្រូវក្នុងការគាំទ្រសហគមន៍ក្នុងការតាក់តែងលក្ខន្តិកៈរបស់ពួកគេ[៨២] និងចេញនូវលិខិតឯកភាពជាផ្លូវការទទួលស្គាល់សហគមន៍ជានីតិបុគ្គល។ តាមទស្សនៈរបស់ការិយាល័យ OHCHR ការតាក់តែងលក្ខន្តិកៈសហគមន៍គួរជាការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទដែលតាំងពីដើមមកជាក្រសួងពាក់ព័ន្ធសំខាន់ទៅលើបញ្ហាជនជាតិដើមភាគតិច ឬទៅលើបញ្ហាគ្រប់គ្រងដីធ្លីនោះ។[៨៣] ការងាររបស់ក្រសួងមហាផ្ទៃត្រូវបានកម្រិត ដោយសារតែថវិកាមិនគ្រប់គ្រាន់ ដើម្បីរ៉ាប់រងទៅលើសោហ៊ុយធ្វើដំណើររបស់មន្ត្រីក្រសួង និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសម្រាប់ការតាក់តែង និងអនុម័តលក្ខន្តិកៈ។ ក្រសួងមិនមានថវិកា

៨២ ការបង្កើតលក្ខន្តិកៈសហគមន៍ គឺជាទិដ្ឋភាពដ៏សំខាន់មួយរបស់ដំណើរការចុះបញ្ជីដីសមូហភាព និងមានតួនាទីជាឯកសារសំខាន់សម្រាប់សហគមន៍ និងអ្នកជិតខាងរបស់ពួកគេ។ ជាពិសេស លក្ខន្តិកៈសហគមន៍បង្កើតអោយមានវិធានសម្រាប់គ្រប់គ្រង និងដំណើរការប្រើប្រាស និងគ្រប់គ្រងដីធ្លី ដោះស្រាយវិវាទ និងប្រហែលសំខាន់បំផុតនោះ គឺក្រមប្រតិបត្តិសម្រាប់ទំនាក់ទំនងជាមួយអ្នកខាងក្រៅ រួមទាំងសមាជិកភូមិ (ជនជាតិដើមភាគតិច និងអ្នកមិនមែនជនជាតិដើមភាគតិច) ដែលមិនបានចូលរួមក្នុងពាក្យស្នើសុំឋានៈជាសហគមន៍ "នីតិបុគ្គល"។ តាមដែលអាចទៅរួច ការបង្កើតលក្ខន្តិកៈសហគមន៍ត្រូវគោរពសិទ្ធិសហគមន៍ជនជាតិដើមភាគតិចក្នុងការកំណត់យុទ្ធសាស្ត្រ និងអទិភាពរបស់ពួកគេ ពាក់ព័ន្ធការគ្រប់គ្រងដីធ្លីពួកគេ ជាជាងបំពេញតាមតម្រូវការលក្ខន្តិកៈប្រើប្រាសដីធ្លីដែលបង្កើតដោយអ្នកក្រៅ។ ចំពោះតម្រូវការវិញ លក្ខន្តិកៈគួរដោះស្រាយស្ថានភាពស្ត្រីជនជាតិដើមភាគតិច ដែលងាយទទួលរងការបដិសេធក្នុងរចនាសម្ព័ន្ធការធ្វើសេចក្តីសំរេចតាមប្រពៃណី និងពុះពារដើម្បីការសិទ្ធិរបស់ពួកគេចំពោះដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗ។ សម្រាប់ទទួលបានការណែនាំបន្ថែមចំពោះកិច្ចពិគ្រោះយោបល់ និងបរិយាប័ន្នស្ត្រីជនជាតិដើមភាគតិច សូមចូលទៅកាន់ Gender and Indigenous Peoples, របាយការណ៍សង្ខេបរបស់អង្គការសហប្រជាជាតិ ការិយាល័យក្រុមប្រឹក្សាពិសេសស្តីពីបញ្ហាយេនឌ័រ និងលើកកម្ពស់ស្ត្រី និងលេខាធិការដ្ឋានវេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីពីជនជាតិដើមភាគតិច ឆ្នាំ ២០១០។

៨៣ ពាក់ព័ន្ធនឹងចំណុចនេះ ការិយាល័យ OHCHR កត់សម្គាល់ឃើញថា ការពិភាក្សានានារវាងក្រសួងសំខាន់ៗបន្ទាប់ពីការអនុម័តច្បាប់ភូមិបាលបានសំណូមពរថាក្រសួងមហាផ្ទៃ កាលពីដំបូង គាំទ្រសហគមន៍ក្នុងការតាក់តែងលក្ខន្តិកៈ និងឯកភាពលើលក្ខន្តិកៈនោះ (ដើម្បីចុះបញ្ជីជានីតិបុគ្គល) គួរជាការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់វិញ (ការគាំទ្ររបស់អង្គការ ILO ចំពោះគម្រោងជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា-ការតាក់តែងលក្ខន្តិកៈជនជាតិដើមភាគតិចលេខ ២២)។ ការកំណត់នេះទំនងជាជាប់ទាក់ទងនឹងដំណើរដែលថាយោងតាមអនុក្រឹត្យលេខ ៨៣ នោះវិធានសម្រាប់ការកាន់កាប់ជាម្ចាស់កម្មសិទ្ធិដី និងគ្រប់គ្រងដី និងការដោះស្រាយជម្លោះត្រូវបានគិតទុកថា ជាមូលហេតុចម្បងដែលនាំឲ្យមានការតាក់តែងលក្ខន្តិកៈសហគមន៍ និងជាសមាសធាតុស្នូលនៃវិធាននោះ។ អនុក្រឹត្យលេខ ៨៣ មាត្រា ៥ ចែងថា "សហគមន៍ជានីតិបុគ្គលស្របច្បាប់ ដែលមានបទបញ្ញត្តិក្នុងសហគមន៍ចែងអំពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព ព្រមទាំងការកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួន មានជាអាទិ៍ ការចាត់ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទលើការប្រើប្រាស់ដីតាមបែបប្រពៃណី"។ តួនាទីនាំមុខរបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក៏ត្រូវបានកំណត់ឲ្យដែរ ពាក់ព័ន្ធជាមួយនឹងគម្រោងដែលឧបត្ថម្ភថវិកាដោយម្ចាស់ជំនួយ ទៅលើការរៀបចំផែនការប្រើប្រាស់ដីមានលក្ខណៈចូលរួម (ពីប្រជាជន) ដែលត្រូវបានដាក់ឲ្យដំណើរការនៅក្នុងឆ្នាំ ២០០៤ ជាមួយនឹងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ រួចហើយរៀបចំនូវដំណើរការមួយសម្រាប់កំណត់អត្តសញ្ញាណដី និងតំបន់ប្រើប្រាស់ដី និងឆ្ពោះទៅរកការផលិតផែនទីអំពីធនធាននៅថ្នាក់ភូមិតាមឪដីថលសម្រាប់សហគមន៍នានា រួមទាំងសហគមន៍ជនជាតិដើមភាគតិចផង។វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់គម្រោងធ្វើផែនការប្រើប្រាស់ដីមានលក្ខណៈចូលរួមនេះ (ឥឡូវនេះមិនដំណើរទេ) បានត្រួសត្រាយផ្លូវដល់ការតាក់តែងលក្ខន្តិកៈសម្រាប់ជនជាតិដើមភាគតិចស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ (ការគាំទ្ររបស់អង្គការ ILO ដល់គម្រោងជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា--ការតាក់តែងលក្ខន្តិកៈជនជាតិដើមភាគតិច)

រដ្ឋណាមួយដែលបែងចែកសម្រាប់ដំណើរការនេះឡើយ ហើយវាក៏រងផលប៉ះពាល់ដោយសារសមត្ថភាព មានកម្រិតរបស់មន្ត្រីមន្ទីរដែលពាក់ព័ន្ធនៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុកផងដែរ។[៨៤] ដោយពិចារណាលើបញ្ហាប្រឈមនៅក្នុងដំណើរការ ដែលដឹកនាំដោយក្រសួងមហាផ្ទៃដើម្បីរៀបចំលក្ខន្តិកៈ នោះការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់បណ្តាសហគមន៍ដែលលើកយកមកពិភាក្សា បានក្លាយទៅជាការទទួលខុសត្រូវដ៏ធំរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs)/ដៃគូអភិវឌ្ឍន៍ (DPs) ដែលគាំទ្រជនជាតិដើមភាគតិច[៨៥]។

វិធីសាស្រ្តមួយដែលធ្វើឲ្យដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិកាន់តែឆាប់រហ័ស និងរលូន គឺការប្រចាប់បញ្ចូលគ្នានូវការតាក់តែងលក្ខន្តិកៈជាមួយនឹងដំណាក់កាលទីមួយនៃដំណើរការផ្តល់ ប័ណ្ណកម្មសិទ្ធិដីសមូហភាព (ពាក្យស្នើសុំការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច) ដែលដំណើរការ និងត្រួតពិនិត្យដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ហេតុដូច្នេះ អាណត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទនឹងត្រូវបន្ថែម ដើម្បីបញ្ចូលនូវការទទួលខុសត្រូវគាំទ្រសហគមន៍ក្នុងការតាក់តែងលក្ខន្តិកៈពួកគេ។ បើមើលលើទិដ្ឋភាពសមត្ថភាព វិធីសាស្រ្តនេះសមស្របខ្លាំងណាស់ ពីព្រោះក្រសួងអភិវឌ្ឍន៍ជនបទ គឺជាក្រសួងដែលមានមន្ត្រីជំនាញលើបញ្ហាជនជាតិដើមភាគតិចតាំងពីដើមរៀងមក និងនៅតែមានមន្ត្រីទាំងនោះធ្វើការជាមួយនឹងក្រសួងជាដដែល ព្រមទាំងមាននាយកដ្ឋានមួយដែលស្ថិតនៅក្នុងក្រសួងស្រាប់ ដែលមានជំនាញទៅលើបញ្ហានេះតែម្តង។ ការណ៍នេះ ក៏អាចកាត់បន្ថយនូវចំនួនបេសកកម្មក្នុងចំនួនសមស្របពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទដែរ ព្រោះថាការតាក់តែងលក្ខន្តិកៈអាចធ្វើឡើងស្របពេលគ្នាជាមួយនឹងដំណាក់កាលផ្សេងៗទៀតនៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិនេះ (ប្រសើរបំផុត ដំណាក់កាលទី១)។ ទោះជាយ៉ាងណា ក្រសួងអភិវឌ្ឍន៍ជនបទអាចតម្រូវអោយមានកំណើនធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដើម្បីអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព។

---

៨៤ យោងតាមក្រសួងពាក់ព័ន្ធ មន្ត្រីមួយចំនួយមកពីខេត្តរតនគីរី និងមណ្ឌលគីរីគឺមានបទពិសោធន៍ច្រើនក្នុងការងារនេះ ប៉ុន្តែមន្ត្រីមកពីខេត្តផ្សេងៗក្នុងតំបន់ដទៃទៀតពុំដែលបានទទួលការបណ្តុះបណ្តាល និងដូច្នេះពួកគាត់មានចំណេះដឹងតិចតួចណាស់។

៨៥ ការគាំទ្ររបស់អង្គការ ILO ចំពោះគម្រោងជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា – ការតាក់តែងលក្ខន្តិកៈសម្រាប់ជនជាតិដើមភាគតិច ២៣។

តាមទស្សនៈរបស់ការិយាល័យOHCHR តួនាទីរបស់ក្រសួងមហាផ្ទៃ និង/ឬអាជ្ញាធរមូលដ្ឋាន (អនុលោមតាមអនុក្រឹតវិមជ្ឈការ ខែធ្នូ ឆ្នាំ ២០១៩) អាចផ្តោតតែទៅលើការឯកភាពពាក្យស្នើសុំ ដោយឈរលើមូលដ្ឋានគ្មានការជំទាស់ប៉ុណ្ណោះ មានន័យថាក្រសួងអភិវឌ្ឍន៍ជនបទនឹងទទួលបន្ទុក ហើយគ្រាន់តែដាក់ជូនឯកសារលិខិតស្នាមទៅក្រសួងមហាផ្ទៃដើម្បីឯកភាពប៉ុណ្ណោះ។ វិធីសាស្ត្រនេះនឹងមិនតម្រូវឲ្យមានការកែប្រែច្បាប់ភូមិបាល ឬអនុក្រឹត្យឡើយ ខណៈដែលក៏មិនចាំបាច់កំណត់នូវតួនាទីរបស់ក្រសួងមហាផ្ទៃនៅក្នុងដំណើរការ (ផ្តល់ប័ណ្ណកម្មសិទ្ធិ) នេះដែរ ប៉ុន្តែ (ក្រសួងមហាផ្ទៃ) គ្រាន់តែមានតួនាទីនៅដំណាក់កាលឯកភាពជាការស្រេច។

### អនុសាសន៍របស់ការិយាល័យ OHCHR ទៅកាន់រដ្ឋាភិបាលកម្ពុជា៖

- ស្រាយបំភ្លឺទំនាក់ទំនងរវាង ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល LANGO-- ជាពិសេសក្របខ័ណ្ឌពេលវេលាដែលមានរយៈពេលអតិបរមា៤៥ ថ្ងៃក្នុងការពិនិត្យពាក្យស្នើសុំលក្ខខណ្ឌតម្រូវនានាសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដែលមាននៅក្នុងពាក្យស្នើសុំរបស់ពួកគេក្នុងការចុះបញ្ជីជានីតិបុគ្គលដើម្បីធានាឲ្យមានការពិចារណាទាន់ពេលវេលាទៅលើពាក្យស្នើសុំរបស់ពួកគេ។ ស្នើសុំអោយមានការពិចារណាចេញប្រកាសស្តីពីការបញ្ជាក់ថា "នីតិបុគ្គល"របស់សហគមន៍ជនជាតិដើមភាគតិច គឺមិនត្រូវបានគ្របដណ្តប់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទេ។
- ពិចារណាអនុញ្ញាតឲ្យក្រសួងមហាផ្ទៃអនុម័តពាក្យសុំ ចុះបញ្ជីជានីតិបុគ្គលរបស់សហគមន៍ជនជាតិដើមភាគតិចដោយពុំមានការបដិសេធ។
- ស្នើឲ្យចេញសារាចរណែនាំដល់រដ្ឋបាលស្រុកទាំងអស់ស្តីពីតួនាទី និងភារកិច្ចថ្មីរបស់ពួកគាត់ ជាពិសេសតួនាទីភារកិច្ចពាក់ព័ន្ធនីតិវិធី ការចុះបញ្ជីដីសមូហភាព (ដំណាក់កាលទី២) ដូចដែលបានចែងក្នុងអនុក្រឹត្យលេខ១៨៤ អនក្រ/បក "ស្តីពីតួនាទី និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក" ចុះថ្ងៃទី០២ ធ្នូឆ្នាំ២០១៩។និង/ឬស្នើក្រសួងមហាផ្ទៃពិចារណាលទ្ធភាពប្រតិភូកម្មតួនាទីចុះបញ្ជីនីតិបុគ្គលរបស់សហគមន៍ជនជាតិដើមភាគតិចទៅ ឲ្យរដ្ឋបាលថ្នាក់ខេត្ត។

- បញ្ចូលការតាក់តែងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចទៅក្នុងដំណាក់កាលណាមួយ(ចង់បានដំណាក់កាលទី១) នៃដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិដោយប្រតិភូកម្មអំណាច/តួនាទីទៅឲ្យទីចាត់ការផែនការណ៍វិនិយោគរបស់សាលាខេត្ត (ដែលជាសេនាធិការស្រប ច្បាប់របស់ក្រសួងមហាផ្ទៃ) ដោយមានការសម្របសម្រួលបច្ចេកទេសពីសំណាក់មន្ត្រីមន្ទីរអភិវឌ្ឍន៍ ជនបទ (ក្រសួងអភិវឌ្ឍន៍ជនបទ)។

## ដំណាក់កាលទី២.៥ ៖ ការធ្វើផែនទីបឋម និងការតាក់តែងបទបញ្ជាផ្ទៃក្នុង (បច្ចុប្បន្ននេះគ្មានក្រសួងណាមួយត្រូវបានដាក់ឲ្យទទួលខុសត្រូវការងារនេះឡើយ)[៨៦]

### ការអនុវត្តបច្ចុប្បន្ន

ស្រដៀងគ្នានឹងដំណាក់កាលទី១ ទី២ និងទី៣ ដែរ -- ទម្រង់ពាក្យស្នើសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លី សមូហភាព--តម្រូវឲ្យមានឯកសារគាំទ្រមួយចំនួន។ ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៨៣ គឺជាទម្រង់លិខិតដែលត្រូវប្រើប្រាស់នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ទម្រង់លិខិតនេះតម្រូវឲ្យមានការភ្ជាប់ឯកសារមួយចំនួនជាមួយនឹងពាក្យស្នើសុំ ដែលហៅថា "ឯកសារបឋម"។[៨៧] ឯកសារទាំងនេះត្រូវរៀបចំឲ្យហើយ បន្ទាប់ពីដំណាក់កាលទី២ និងត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិ ដែលត្រូវផ្ញើទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដំណាក់កាលទី៣)។ពីព្រោះតែមានដំណាក់កាលនេះ ការរៀបចំឯកសារទាំងនេះនៅក្នុងដំណាក់កាលនេះត្រូវបានកំណត់ជាដំណាក់កាលទី២.៥។

ទោះបីជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៨៣ មិនបានចែងលម្អិតអំពីដំណើរការបច្ចេកទេសសម្រាប់វាស់វែងដីសហគមន៍ និងគូរផែនទីបឋមក៏ដោយ ក៏ឧបសម្ព័ន្ធនេះបានគូសបញ្ជាក់ថាផែនទីបឋម ត្រូវកំណត់ឲ្យច្បាស់លាស់អំពីទីតាំង ទំហំ និងព្រំប្រទល់នៃក្បាលដីនីមួយៗ នៅក្នុងពាក្យស្នើសុំផងដែរ។[៨៨] ឆ្លើយតបនឹងគោលបំណងនេះ កូអ័រដោណេ

---

៨៦ ផ្អែកនេះផ្អែកលើការបោះពុម្ពផ្សាយខាងក្រោម ៖ អង្គការ អីឈ ៖ ឯកសារបច្ចេកទេសស្ដីពីការចុះបញ្ជីដីជាសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ជាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ឆ្នាំ ២០១៦។

៨៧ សៀវភៅមេរៀនបណ្ដុះបណ្ដាលស្ដីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងឆ្នាំ ២០១២ (៩)

៨៨ អនុក្រឹត្យលេខ ៨៣ មាត្រា ៥

GPS យ៉ាងហោចណាស់ក៏ត្រូវកំណត់នៅតាមជ្រុងកែងនៃក្បាលដីនីមួយៗដែរ។[៨៩]

នៅក្នុងការអនុវត្តបច្ចុប្បន្ន[៩០] សម្រាប់ការគូរផែនទីបឋម អ្នកសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍ (NGO/DP) និងសមាជិកគណៈកម្មាធិការសហគមន៍ត្រូវរៀបចំ ជាក្រុមការងារសហគមន៍។[៩១] ក្រុមការងារនេះ នឹងស្នើសុំផែនទីដែលបង្ហាញព្រំប្រទល់រដ្ឋបាលពីក្រុមប្រឹក្សាឃុំ និងពីមន្ទីរសុរិយោដីថ្នាក់ខេត្ត បន្ថែមទៅលើរូបថតពីលើអាកាស និងផែនទីឋានលេខា ដែលបង្ហាញអំពីភូមិសាស្ត្រ និងទីតាំងដាក់លាក់របស់សហគមន៍ដែលត្រូវបានរក្សាទុកនៅក្នុងសំណុំឯកសាររបស់ក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សាឃុំក៏នឹងអញ្ជើញភូមិដែលស្ថិតនៅជាប់គ្នា និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតដើម្បីប្រជុំគ្នាជាលើកដំបូងពិភាក្សាអំពីព្រំដីភូមិ និងដំណើរការគូរផែនទី[៩២]។

ជាដំបូង សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល (NGO)/ ដៃគូអភិវឌ្ឍន៍ (DP) ដែលគាំទ្រជនជាតិដើមភាគតិច ត្រូវផលិតផែនទីគូរដោយដៃ--ដែលជាទូទៅហៅថា*ផែនទីគំនូសព្រាង*បឋម--ដែលបង្ហាញអំពីព្រំប្រទល់ភូមិ និងប្រភេទនៃការប្រើប្រាស់ដីនៅក្នុងផែនទីនោះ ប៉ុន្តែមិនបានបញ្ជាក់លម្អិតអំពីទំហំផ្ទៃដី (ក្រឡាផ្ទៃ) ដែលបានស្នើសុំ ឬទីតាំងពិតប្រាកដឡើយ។ ប្រធានភូមិ អ្នកចាស់ទុំក្នុងភូមិ សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ អ្នកតំណាងមកពីភូមិជិតខាង និងសមាជិកក្រុមប្រឹក្សាឃុំ រួមទាំងមេឃុំផង ក៏គួរចូលរួមនៅក្នុងសកម្មភាពនេះដែរ។[៩៣] របាយការណ៍កិច្ចប្រជុំនឹងត្រូវរៀបចំឡើង ហើយបញ្ជីរាយនាមអ្នកចូលរួមទាំងអស់នៅក្នុងកិច្ចប្រជុំនឹងត្រូវដាក់ជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងរបាយការណ៍កិច្ចប្រជុំ។

---

៨៩ សៀវភៅបណ្តុះបណ្តាលស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅក្នុងឆ្នាំ ២០១២ (៩)

៩០ ផ្អែកខាងក្រោមផ្អែកលើឯកសាររបស់អង្គការ GIZ ៖ ឯកសារបច្ចេកទេសស្តីពីការចុះបញ្ជីដីសហគមន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ជាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព, ២០១៦, ៤-១០.

៩១ ឯកសារបច្ចេកទេសស្តីពីការចុះបញ្ជីដីសហគមន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ជាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ២០១៦, ៦

៩២ នៅក្នុងករណីដែលក្រុមប្រឹក្សាឃុំមិនមានសមត្ថភាពគាំទ្របញ្ហានេះ នោះក្រុមការងារត្រូវស្នើសុំអភិបាលស្រុកឲ្យធ្វើលិខិតអញ្ជើញជាផ្លូវការ។

៩៣ អង្គការ GIZ ៖ ឯកសារបច្ចេកទេសស្តីពីការចុះបញ្ជីដីជាសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ជាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ឆ្នាំ ២០១៦, ៦។

បន្ទាប់មកទៀត កិច្ចប្រជុំត្រូវរៀបចំឡើងនៅថ្នាក់ឃុំ ជាមួយនឹងអ្នកតំណាងមកពីភូមិជិតខាង និងក្រុមប្រឹក្សាឃុំដើម្បីយល់ព្រមទៅលើផែនទីគំនូសព្រាង។ អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងមកពីក្រុមការងារជីវជ្ជ (ជាទីភ្នាក់ងារថ្នាក់ក្រោមជាតិ ដែលមានភារកិច្ចកំណត់អត្តសញ្ញាណ គូរផែនទី និងបែងចែកដីវជ្ជ) គួរចូលរួមដែរ ក្រៅពីសមាជិកគណៈកម្មាធិការសហគមន៍ អ្នកចាស់ទុំក្នុងភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ (រួមទាំងមេឃុំផងដែរ) ហើយសោហ៊ុយធ្វើដំណើរ និងប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ នឹងត្រូវរ៉ាប់រងដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) និង/ឬដៃគូអភិវឌ្ឍន៍។ កិច្ចប្រជុំគួរស្ថិតនៅក្រោមអធិបតីភាពអាជ្ញាធរស្រុក (អភិបាលស្រុក) និងដឹកនាំ (ប្រជុំ) ឲ្យមានការព្រមព្រៀងទៅលើចំណុចសម្គាល់ព្រំប្រទល់ភូមិទាំងអស់នៅក្នុងផែនទីគំនូសព្រាង។ ការផ្តិតមេដៃលើផែនទីរបស់អ្នកចូលរួមទាំងអស់ក្នុងកិច្ចប្រជុំ គឺជាការបង្ហាញនូវការយល់ព្រមរបស់ពួកគេទៅលើផែនទី និងព្រំប្រទល់ ព្រមទាំងត្រូវបញ្ជាក់ប្រាប់អំពីប្រភេទនៃការប្រើប្រាស់ដីផងដែរ។ របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីកិច្ចប្រជុំក៏ត្រូវរៀបចំដោយមេឃុំដែរ។

ជាចុងក្រោយ ផែនទីគំនូសព្រាងបឋមនឹងត្រូវបំប្លែងឲ្យទៅជាផែនទីឌីជីថល។សម្រាប់ការបំប្លែងនេះ ក្រុមផ្សេងៗគ្នាដែលក្រុមនីមួយៗមានសមាជិកចំនួនប្រាំ ឬប្រាំមួយនាក់ដែលមានដូចជាសមាជិកសហគមន៍ អ្នកតំណាងនៃសហគមន៍ជិតខាង ហើយ និងអាជ្ញាធរមូលដ្ឋាន–ចាប់ផ្តើមវាស់វែងដីរួចហើយកត់ត្រាទិន្នន័យតាម GPS។ យ៉ាងនេះក្តីមុនចាប់ផ្តើមធ្វើការវាស់វែងតាម GPS ក្រុមការងារខាងលើត្រូវទទួលនូវការបណ្តុះបណ្តាលជាមុនសិន ដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) ដែលធ្វើការគាំទ្រជនជាតិដើមភាគតិច ទៅលើការប្រមូលទិន្នន័យ ការប្រើប្រាស់ GPS និងរបៀបសរសេររបាយការណ៍ពាក់ព័ន្ធព្រមទាំងរបៀបបំពេញទម្រង់ប្រមូលទិន្នន័យផងដែរ។

អាជ្ញាធរមូលដ្ឋាននានា ក្រុមការងារជីវជ្ជថ្នាក់ស្រុក អ្នកចាស់ទុំក្នុងភូមិ សមាជិកគណៈកម្មាធិការសហគមន៍ ប្រធានភូមិមកពីសហគមន៍ជិតខាង និងសមាជិកក្រុមប្រឹក្សាឃុំដែលតំណាងឲ្យភូមិជិតខាង ក៏ត្រូវចូលរួមទាំងអស់គ្នានៅក្នុងការអនុវត្តនេះ ដើម្បីផលិតឲ្យបាននូវផែនទីឌីជីថលមួយដែលមានកំណត់ព្រំប្រទល់ភូមិច្បាស់លាស់។

បន្ទាប់ពីការគូរផែនទីតាម GPS រួចរាល់ នោះផែនទីឌីជីថលមួយនឹងត្រូវបានបង្កើតឡើង ដោយបង្ហាញនូវព័ត៌មានដែលបានព្រមព្រៀងគ្នារវាងភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស អំពីបញ្ហាព្រំប្រទល់រដ្ឋបាល ទីតាំង និងទំហំដីសហគមន៍ដែលត្រូវប្រើប្រាស់។

នៅពេល ដែលផែនទីឌីជីថលត្រូវបានផលិតរួចរាល់ជាស្ថាពរ នោះកិច្ចប្រជុំមួយទៀតនឹងត្រូវធ្វើឡើងដើម្បីបញ្ជាក់ភាពត្រឹមត្រូវដល់ផែនទីនោះ។ ការប្រជុំនេះមានការចូលរួមពីចាស់ទុំក្នុងភូមិ សមាជិកគណៈកម្មាធិការសហគមន៍ ប្រធានភូមិ និងសមាជិកក្រុមប្រឹក្សាឃុំ។ នៅក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា នោះត្រូវប្រមូលទិន្នន័យជាថ្មីដើម្បីកែសម្រួលផែនទីឌីជីថល ហើយក៏ត្រូវរៀបចំនូវកិច្ចប្រជុំមួយចំនួនទៀតឡើងវិញដែរ។ ផែនទីបឋមមិនគួរដាក់បញ្ចូលនូវតំបន់ណាមួយដែលមានជម្លោះ ជាមួយនឹងសហគមន៍ជិតខាង ឬអ្នកកាន់កាប់សម្បទានដី ឬដែលស្នើសុំជាន់គ្នាឡើយ ពីព្រោះថាការដាក់បញ្ចូលតំបន់ដែលមានវិវាទនេះនឹងមិនធ្វើឲ្យមានការទទួលយកមកពិនិត្យនូវពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីឡើយ។ ដំណាលគ្នា នឹងការគូរផែនទីបឋមដែរ សហគមន៍ត្រូវតាក់តែងបទបញ្ជាផ្ទៃក្នុងមួយ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ដីហើយ និងការដោះស្រាយវិវាទក្នុងករណីដែលមានជម្លោះដីធ្លី។ ការតម្រូវនេះផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យលេខ ៨៣ ដែលបានចែងថា សហគមន៍ជនជាតិដើមភាគតិច "ត្រូវបង្កើតជាផ្លូវការជានីតិបុគ្គលដែលមានបទបញ្ជាផ្ទៃក្នុងចែងអំពីការគ្រប់គ្រង និងប្រើប្រាស់ដីសមូហភាព ក៏ដូចជាការកំណត់នូវលក្ខខណ្ឌមួយចំនួន ដូចជាការគ្រប់គ្រងដី សមូហភាព និងការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលនៅក្នុងកម្រិតថ្នាក់ សហគមន៍ ប្រសិនបើមានវិវាទ។"[៩៤] បទបញ្ជាផ្ទៃក្នុងនេះមានសារសំខាន់ខ្លាំងណាស់ ពីព្រោះ វាធ្វើការគ្រប់គ្រងទៅលើទំនាក់ទំនងរបស់សហគមន៍ជាមួយ "អ្នកខាងក្រៅ" ដែលមានដូចជាសមាជិកភូមិដែលមិនបានសម្រេចចិត្តចូលរួមនៅក្នុងការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ឬ ប្រជាជនខ្មែរដែលមិនអាចចូលរួមបាន។

បទបញ្ជា ផ្ទៃក្នុងគួររួមបញ្ចូលប្រភេទដីសាធារណៈរបស់រដ្ឋផ្សេងៗទៀតចូលទៅក្នុងក្បាលដី ដែលសហគមន៍ជនជាតិដើមភាគ

៩៤ អនុក្រឹត្យលេខ ៨៣ មាត្រា ៥

តិចស្នើសុំចុះបញ្ជីដីសមូហភាព។ ហេតុដូច្នេះហើយ ការតាក់តែងបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដី ត្រូវធ្វើឡើងរួមគ្នាជាមួយនឹងការគូរផែនទីបឋមដែរ (ដើម្បីកំណត់ប្រភេទដីរដ្ឋផ្សេងៗគ្នា ដែលបានដាក់បញ្ចូលនៅក្នុងតំបន់ដែលកំពុងស្នើសុំ ក្នុងចំណោមការងារនានា)។ អង្គការមិនមែនរដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍ដែលគាំទ្រសហគមន៍នៅក្នុងការរៀបចំ លក្ខន្តិកៈក៏ត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់អំពីការបែងចែកប្រភេទដីរដ្ឋខុសគ្នានេះដែរ។[៩៥] ទោះបីជាមិនមានក្រសួងណាមួយ ត្រូវបានភ្ជាប់ឲ្យបានច្បាស់លាស់ទៅនឹងដំណើរការនេះ ក៏ដោយ ក៏ដំណើរការនេះភាគច្រើនត្រូវបានតម្រង់ទិសដោយក្រសួងអភិវឌ្ឍន៍ជនបទដែរ។

ការតាក់តែងបទបញ្ជាផ្ទៃក្នុងនឹងតម្រូវឲ្យមានការជួបប្រជុំរវាងសមាជិកសហគមន៍ និងចាស់ទុំក្នុងភូមិ ដើម្បីរៀបចំជាសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងលើកដំបូង។ គួរកត់សម្គាល់ផងដែរថា លក្ខន្តិកៈសហគមន៍ដែលត្រូវបានរៀបចំឡើង ជាផ្នែកមួយនៃការចុះបញ្ជីសហគមន៍ជានីតិបុគ្គល និងមួយទៀត គឺបទបញ្ជាផ្ទៃក្នុង មើលទៅស្រដៀងគ្នា សម្រាប់សហគមន៍ដែលបានបំពេញចប់សព្វគ្រប់នូវដំណាក់កាលទី២ និងដំណាក់កាលទី២.៥។[៩៦] នៅពេលសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងត្រូវបានរៀបចំរួចរាល់ នោះជាទូទៅនឹងមានការប្រជុំមួយចំនួនទៀតជាមួយនឹងសមាជិកសហគមន៍ដើម្បីពិនិត្យមើល និងកែសម្រួលសេចក្តីព្រាងនោះ។ ការប្រជុំទាំងនេះនឹងត្រូវសម្របសម្រួលដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត។ បទបញ្ជាផ្ទៃក្នុង គួរព្រមព្រៀងដោយសមាជិកសហគមន៍ទាំងអស់នៅក្នុងមហាសន្និបាត ហើយក៏ត្រូវឯកភាពដោយក្រុមប្រឹក្សាឃុំផងដែរ[៩៧] មុននឹងបញ្ជូនពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពនេះទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## បញ្ហា

### ❖ កង្វះខាតភាពជាម្ចាស់របស់រដ្ឋាភិបាល

ទោះបី ជាដំណាក់កាលផ្សេងទៀត (ដំណាក់កាលទី១,២, និងទី៣) នៅក្នុងដំណើរការស្នើសុំ ប័ណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ត្រូវ

៩៥ សៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណនៃជនជាតិដើមភាគតិច ការតាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការគូរផែនទីបឋម ការវិនិច្ឆ័យដី និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (Kirsten Ewers Andersen និង Loeung Kesaro, គាំទ្រដោយអង្គការ GIZ), ១៦។

៩៦ ការវាយតម្លៃរបស់អង្គការ GIZ ទៅលើបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ចំនួនប្រាំពីរបង្ហាញថាបទបញ្ជាផ្ទៃក្នុងនេះគឺដូចតែគ្នាតាមពាក្យនីមួយៗ (ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន Poch ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៧)។

៩៧ បន្ទាប់ពីមហាសន្និបាត នោះកំណត់ហេតុនៃមហាសន្និបាតនឹងទទួលបាននូវការអនុម័តជាផ្លូវការដោយក្រុមប្រឹក្សាឃុំ។

បានកំណត់ភ្ជាប់ យ៉ាងច្បាស់លាស់ទៅកាន់ក្រសួងជាក់លាក់ណាមួយក៏ដោយ ក៏ដំណាក់កាលទី២.៥ មិនត្រូវបានកំណត់ភ្ជាប់ទៅក្រសួងណាមួយឡើយ។ហេតុដូច្នេះហើយសហគមន៍ជនជាតិដើមភាគតិច ត្រូវទុកចោលនៅក្នុងករណីអវត្តមានអន្តរការី ដោយសារតែផ្នែកមួយនៅក្នុងចំណោមផ្នែកដែលស្មុគស្មាំបំផុតនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដី សមូហភាព។[៩៨] នេះគឺជាកង្វល់ជាក់លាក់មួយខណៈដែលអង្គការមិនមែនរដ្ឋាភិបាល (NGOs)/ដៃគូអភិវឌ្ឍន៍ (DPs) ជារឿយៗ ខ្វះខាតធនធានហិរញ្ញវត្ថុ និងសមត្ថភាពផ្នែកបច្ចេកទេសក្នុងការផលិតផែនទី ដែលមានកម្រិតលម្អិតដល់ថ្នាក់នេះ។

ការគូរផែនទីបឋមគឺជាភារកិច្ចដ៏ស្មុគស្មាញពីព្រោះវាតម្រូវឲ្យមានជំនាញខ្ពស់ដើម្បីផលិតផែនទីឲ្យដល់កម្រិតដែលតម្រូវឲ្យលម្អិតសម្រាប់ពាក្យស្នើសុំចុះបញ្ជីដី។ អង្គការមិនមែនរដ្ឋាភិបាល (NGOs)/ដៃគូអភិវឌ្ឍន៍ (DPs) ជាច្រើនខ្វះសមត្ថភាពប្រើប្រាស់ការថតតាម GPS និងបំប្លែងពីផែនទីគំនូសព្រាងបឋមទៅជាឯកសារបច្ចេកទេសដែលមានកូអ័រដោណេ GPS។ ផែនទីបឋមដែលមិនត្រឹមត្រូវ ត្រូវបានកត់សម្គាល់ថា ជាមូលហេតុចម្បងដែលនាំឲ្យមន្ទីររៀបចំដែនដីខេត្តស្នើឲ្យ សហគមន៍ធ្វើការពិនិត្យឡើងវិញ ឬដាក់ពាក្យជាថ្មីនូវពាក្យស្នើសុំចុះបញ្ជីដីសមូហភាព។[៩៩] ស្នើឲ្យមានការបណ្តុះបណ្តាលដើម្បីយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍កុំព្យូទ័រ ក៏ដូចជាការផលិតវីដេអូ ការកែសម្រួលរូបថត និងសូហ្វវែរគ្រប់គ្រងហ្វាល។ តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលពាក់ព័ន្ធនឹង បច្ចេកទេសខ្ពស់មានរហូតដល់មានការកំណត់តាម GPS ជាដើមនោះ ធ្វើឲ្យមានការយកចិត្តទុកដាក់ខ្លាំងតែទៅលើបច្ចេកវិទ្យា ហើយធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តដំណាក់កាលគូរផែនទីដោយមានការចូលរួមពីសហគមន៍ទៅវិញ។[១០០] នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដាច់

៩៨ គួរកត់សម្គាល់ថា "ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនអាចចាត់វិធានការណាមួយដើម្បីពន្លឿនដំណើរការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចបានទេ រហូតដល់ខ្លួនបានទទួលនូវពាក្យស្នើសុំភ្ជាប់ជាមួយនូវឯកសារគាំទ្រគ្រប់ចំនួន។" សូមមើលសៀវភៅណែនាំស្តីពីការកំណត់អត្តសញ្ញាណនៃជនជាតិដើមភាគតិច ការតាក់តែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការគូរផែនទីបឋម ការវិនិច្ឆ័យដី និងការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា (Kirsten Ewers Andersen និង Loeung Kesaro, គាំទ្រដោយអង្គការ GIZ)

៩៩ មេរៀនរបស់អង្គការ GIZ ដែលបានរៀនពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍របស់ជនជាតិដើមភាគតិច ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៦។

១០០ ការអនុវត្តល្អនៅក្នុងការគូរផែនទីដោយមានការចូលរួម – ការពិនិត្យដែលបានរៀបចំសម្រាប់មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម ឆ្នាំ ២០០៩, ១៨។

ស្រយ៉ាលជាច្រើន ការមានអគ្គិសនីប្រើប្រាស់សម្រាប់ដំណើរការឧបករណ៍ (កុំព្យូទ័រ) គឺមិនស្ថិតស្ថេរឡើយ ជួនមាន ជួន អត់ ឬពេលខ្លះអត់តែម្តង។

ទោះ ជាគ្មានវត្តមានគោលនយោបាយជាក់លាក់ ឬការផ្តល់សេចក្តីណែនាំសម្រាប់ការចូលរួមរបស់ការិយាល័យភូមិបាល វាចាំបាច់ឲ្យមានការចូលរួមរបស់ពួកគេ។ តាមការអនុវត្តបច្ចុប្បន្នបានបង្ហាញថា ការកំណត់ព្រំប្រទល់នឹងមានភាពងាយស្រួលជាង នៅពេលដែលផែនទីបឋមត្រូវបានរៀបចំធ្វើឡើងដោយមន្ត្រីភូមិបាលដោយមាន ការគាំទ្រពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក។ ទោះជាយ៉ាងណា ការងារនេះទាមទារឲ្យមានការវិភាជកញ្ចប់ថវិកាបន្ថែមដើម្បីគាំទ្រដល់មន្ត្រីភូមិបាល។

### ❖ ភាពស្មុគស្មាញ ការចំណាយ និងភាពវែងអន្លាយ

ដំណាក់កាលទី២.៥ ត្រូវបានចាត់ទុកថាជាដំណាក់កាលដ៏ស្មុគស្មាញ និងវែងបំផុតនៅក្នុងចំណោមដំណាក់កាលទាំងបីនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងតម្រូវឲ្យមានចំណេះបច្ចេកទេសសំខាន់ៗដើម្បីអនុវត្ត។[១០១] ការធ្វើផែនទីបឋមគឺមានសភាពស្មុគស្មាញ។ ក្រសួងនានាបានកត់សម្គាល់អំពីតម្រូវការចាំបាច់អោយមាន ចំណេះដឹងផ្នែកបច្ចេកទេសច្បាស់លាស់ និងមានជំនាញក្នុងការធ្វើផែនទី ប៉ុន្តែការដែលត្រូវដោះស្រាយវិវាទព្រំប្រទល់ គឺកាន់តែចំណាយពេលវេលាច្រើនជាងធ្វើផែនទីទៅទៀត។ ផែនទីនេះត្រូវបានចាត់ទុកថាជាប្លង់សុរិយោដី (ប្លង់ក្បាលដី)[១០២] ពេញលេញ ប៉ុន្តែវាអាចធ្វើទៅបាននៅ

១០១ ផ្អែកខាងក្រោមនេះផ្អែកលើរបាយការណ៍របស់អង្គការ GIZ ៖ ឯកសារបច្ចេកទេសស្តីពីការចុះបញ្ជីដីសហគមន៍សម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ញាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ឆ្នាំ ២០១៦, ៤-១០។

១០២ ផែនទីនឹងបង្ហាញនូវក្បាលដីដែលមានប្រភេទដីផ្សេងៗគ្នា ដែលក្បាលដីទាំងអស់នេះបង្កើតបានជាទ្រព្យសម្បត្តិមួយ ដែលសហគមន៍ ក្នុងឋានៈជាក្រុមមួយ ជាអ្នកកាន់កាប់សិទ្ធិ មានសិទ្ធិជាម្ចាស់កម្មសិទ្ធិសមូហភាព។ ក្បាលដីនេះមានទាំងដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ។ ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាការចុះបញ្ជីនូវរាល់ក្បាលដីទាំងអស់របស់សហគមន៍នៅលើប្លង់សុរិយោដីតែមួយ។ ប្លង់នេះមានលេខយោងសម្រាប់ទីតាំង ទំហំ និងព្រំប្រទល់ និងកូអ័រដោណេរបស់ក្បាលដីនីមួយៗដែលកាន់កាប់ជាសមូហភាព និងទីតាំងដែលក្បាលដីស្ថិតនៅក្នុងភូមិ និងក្នុងឃុំ។ សូមមើលឯកសាររបស់អង្គការ GIZ ៖ ឯកសារបច្ចេកទេស្តីពីការចុះបញ្ជីដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច– ការគូរផែនទីបឋម ការតាក់តែងបទបញ្ញាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណ កម្មសិទ្ធិដីសមូហភាព ខែ ៤ ឆ្នាំ ២០១៦។

ក្រោយពេលដែលពាក្យស្នើសុំត្រូវបានទទួល និងឯកភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ប៉ុណ្ណោះ។ នាពេលបច្ចុប្បន្ននេះ ក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និងសំណង់កំពុងតែព្យាយាមស្វែងរកវិធីដែលអាចធ្វើឲ្យដំណើរការផលិតផែនទីបឋម និងការបង្កើតបទបញ្ញាផ្ទៃក្នុងនេះបានកាន់តែឆាប់រហ័ស (ដាទូទៅគឺដំណាក់កាលទី២.៥)។

ចំណាយហិរញ្ញវត្ថុមានចំនួនច្រើនបង្គួរសម្រាប់ការគូរផែនទីដែរ – ជាពិសេសដោយសារការកត់ត្រាទិន្នន័យ GPS អាចត្រូវការរយៈពេលជាច្រើនខែ ហើយតម្រូវឲ្យមានការចំណាយប្រាក់ច្រើនបង្គួរទៅលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយធ្វើដំណើរសម្រាប់អ្នកចូលរួមទាំងអស់។[១០៣] តាមការប៉ាន់ប្រម៉ាណដោយអង្គការមិនមែនរដ្ឋាភិបាល[១០៤] ដែលគាំទ្រសហគមន៍ជនជាតិដើមភាគតិច បានលើកឡើងថាតម្រូវការ រយៈពេលសម្រាប់ដំណាក់កាលទី៣ គឺចន្លោះចាប់ពី ៣ ទៅ ៤ ឆ្នាំដែលក្នុងនោះការគូរផែនទីបឋមប្រើប្រាស់រយៈពេលច្រើនបង្គួរនៃ រយៈពេលនោះ ព្រមទាំងតម្រូវការធនធានសំខាន់ៗជាច្រើនទៀត – បទពិសោធន៍ពីមុនរបស់ការិយាល័យ OHCHR នៅក្នុងការគាំទ្រការគូរផែនទីបឋមបានបង្ហាញឲ្យដឹងថាទឹកប្រាក់ប្រមាណជា ៣០.០០០ ដុល្លារសហរដ្ឋអាមេរិកត្រូវបានចំណាយទៅលើការអនុវត្តនោះ។

## ករណីសិក្សា៖ ឧទាហរណ៍ពីប្រទេសម៉ូស្សាំប៊ិក

យន្តការរបស់ប្រទេសម៉ូហ្សំប៊ិកក្នុងការឆ្លើយតប និងផ្តល់ភាពផ្លូវការ (ផ្តល់ភាពស្របច្បាប់) ដល់សិទ្ធិជាម្ចាស់ដីប្រពៃណី (ដែលតម្រូវជាកាតព្វកិច្ចយ៉ាងសំខាន់នៅក្នុងដំណើរការតាមផ្លូវច្បាប់ ដែលហៅថា "ការកំណត់ព្រំប្រទល់សហគមន៍"[១០៥]) អាចផ្តល់ជាគំរូដ៏មានប្រយោជន៍មួយសម្រាប់យកមកពិចារណា។ ចំណុចភាគច្រើនខ្លះ វាស្រដៀងគ្នាទៅនឹងការអនុវត្តដែលបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាដែរ ៖ ជាដំបូង ក្រុមពិគ្រោះយោបល់

១០៣ មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ និងការិយាល័យភូមិបាលស្រុក នឹងចូលរួមប្រជុំឲ្យបានច្រើនបំផុត។ ការចូលរួមប្រជុំនេះតម្រូវឲ្យមានការគាំទ្រជាហិរញ្ញវត្ថុ (ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ) ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងដៃគូអភិវឌ្ឍន៍។

១០៤ តាមព័ត៌មានដែលទទួលបានពីអង្គការនានាក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយការិយាល័យOHCHR។

១០៥ ឧបសម្ព័ន្ធបច្ចេកទេស (ចំពោះច្បាប់ភូមិបាលឆ្នាំ១៩៩៧) បានកម្រិតថា "ការកំណត់ព្រំប្រទល់តំបន់កាន់កាប់ដោយសហគមន៍មូលដ្ឋាន រួមទាំងការបញ្ចូលព័ត៌មានចូលទៅក្នុងទិន្នន័យភូមិបាលថ្នាក់ជាតិ"

ដែលមានមូលដ្ឋាននៅតាមសហគមន៍ត្រូវបានបង្កើតឡើង។ អ្វីដែលមានតម្លៃគួរឲ្យកត់សម្គាល់នោះគឺថាមន្ត្រីសុរិយោដីថ្នាក់ស្រុកត្រូវរៀបចំខ្លួនជាស្រេចដើម្បីចូលរួមជាមួយនឹងក្រុមការងារ[១០៦]។ នៅពេលនោះការប្រជុំជាច្រើនលើកទៀតនឹងត្រូវបានរៀបចំនៅថ្នាក់សហគមន៍ ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីដំណើរការកំណត់ព្រំប្រទល់និងការបោះឆ្នោតជ្រើសរើសអ្នកតំណាងសហគមន៍ដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការងារកំណត់ព្រំប្រទល់។ ការវាយតម្លៃដោយអ្នកចូលរួមនិងការគូរផែនទីនៅពេលនោះ នឹងត្រូវធ្វើឡើងនៅក្នុងករណីដែលសហគមន៍ និងប្រធានសហគមន៍ជិតខាង យល់ព្រមទៅលើផែនទីគំនូសព្រាង ដែលព្រំប្រទល់ត្រូវបានបោះគោលសម្គាល់[១០៧] និងកំណត់ជាក់ស្តែងនៅលើដី។ នៅពេលសហគមន៍ និងភូមិជិតខាង បានឯកភាពទៅលើផែនទីគំនូសព្រាងរួចហើយនោះផែនទីនេះនឹងត្រូវបំប្លែងទៅជាផែនទីឌីជីថលដោយភ្ជាប់ជាមួយរបាយការណ៍បូកសរុបលទ្ធផលការងារ។ ការបញ្ជាក់ភាពត្រឹមត្រូវនេះត្រូវធ្វើឡើងដោយមន្ត្រីបច្ចេកទេសរបស់រដ្ឋ។ នៅពេលបញ្ជាក់ភាពត្រឹមត្រូវដោយសហគមន៍និងភូមិជិតខាងដែលមានព្រំប្រទល់ជាប់រួចហើយ នោះផែនទីគំនូសព្រាង និងរបាយការណ៍លទ្ធផលការងារនេះ នឹងត្រូវបញ្ចូលទៅក្នុងស្ថាប័នសុរិយោដីថ្នាក់ជាតិ[១០៨]។

ដើម្បីកាត់បន្ថយពេលវេលា ដែលត្រូវចំណាយ និងពេលវេលាយើងផ្តល់អនុសាសន៍ថា ការគូរផែនទីបឋមគួរធ្វើឡើងរួមគ្នារវាងសហគមន៍ជនជាតិដើមភាគតិច ជាមួយនឹងមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ក្រោមជាតិជាការអនុវត្តរួម។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ក្រោមជាតិ (ពោល គឺតាមរយៈក្រុមការងារដីរដ្ឋថ្នាក់ស្រុក) និងភាគីពាក់ព័ន្ធផ្សេងៗទៀត ក៏គួរធ្វើការរួមគ្នាតាំងពីពេលដំបូង ដើម្បីផលិតផែនទីឌីជីថលដែលមាន ព័ត៌មានលម្អិតតាមការតម្រូវ ដើម្បីទទួលបានការឯកភាពជាស្រេច ពីសំណាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង

១០៦ Rachael S. Knight សម្រាប់សេវាព្រាងច្បាប់ - FAO Legal Office: ការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិដីធ្លីប្រពៃណីនៅអាហ្វ្រិក - ការសិក្សាស្រាវជ្រាវចំពោះករណីជោគជ័យក្នុងការបង្កើតច្បាប់ និងការអនុវត្ត (២០១០), ច្បាប់ភូមិបាលរបស់Mozambiqueផ្នែកទីIV, អាចចូលអានបាននៅ៖http://www.fao.org/docrep/០១៣/i១៩៤៥e/i១៩៤៥e០២.pdf, ១១៤

១០៧ Ibid. ១១៥-១១៦

១០៨ Ibid. ១១៧

សំណង់។ វិធីសាស្ត្រនេះមានប្រសិទ្ធភាពលើការចំណាយណាស់ (ចំណាយតិច) ទាក់ទងនឹងពេលវេលា ដែលត្រូវទៅមូលដ្ឋានរបស់សហគមន៍ជនជាតិដើមភាគតិច និងពាក់ព័ន្ធជាមួយភាគីជាប់ទាក់ទងផ្សេងៗទៀត (រួមមានអាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងរបស់សហគមន៍ជិតខាង) ដែលតម្រូវឲ្យចូលរួមនៅក្នុងការគូរផែនទីបឋម។ទោះបីជាវិធីសាស្ត្រនេះមិនតម្រូវឲ្យមានវិសោធនកម្មណាមួយទៅលើច្បាប់ភូមិបាល ឬ អនុក្រឹត្យលេខ ៨៣ ក៏ដោយ ក៏វិធីសាស្ត្រនេះបានលើកឡើងផងដែរថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរចេញនូវសេចក្ដីណែនាំមួយដល់សមភាគីថ្នាក់ក្រោមជាតិ (ពោលគឺមន្ត្រីភូមិបាលស្រុក និងក្រុមការងារថ្នាក់ស្រុកទទួលបន្ទុកដីធ្លី) ដើម្បីគាំទ្រការគូរផែនទីបឋម រួចហើយបែងចែកថវិកាឲ្យបានគ្រប់គ្រាន់ដើម្បីសម្របសម្រួលការចូលរួមរបស់មន្ត្រីទាំងនោះ។

### ❖ វិវាទដីសម្ហហភាពរុំរ៉ែដែលពុំមានដំណោះស្រាយ

នៅក្នុងករណីមួយចំនួន ដំណើរការចុះបញ្ជីដីសមូហភាពត្រូវបាន ទុកមិនចាត់ការដោយសារហេតុផលមានវិវាទដែលមិនទាន់បានដោះស្រាយចំពោះដីធ្លីប្រពៃណីជនជាតិដើមភាគតិច រួមទាំងដីធ្លីដែលបានបញ្ចូលក្នុងពាក្យស្នើសុំចុះបញ្ជីដីសមូហភាព។ គណៈកម្មការសុរិយោដី[១០៩] ធ្វើការដោះស្រាយករណីដីធ្លីទាំងអស់ដែលមិនទាន់បានចុះបញ្ជី[១១០]និងមានតំណាងនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត[១១១] ដែលជាយន្តការបណ្ដឹងសមស្របបំផុតសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលប្រឈមមុខជាមួយនឹងការទន្ទ្រានយកដី ឬវិវាទដីធ្លីសំដៅលើដីប្រពៃណីដែលពួកគេមានបំណងចុះបញ្ជីជាដីសមូហភាព។

ទោះជាយ៉ាងណា យោងតាមឯកសារស្រាវជ្រាវសង្ខេបដោយវិទ្យាស្ថានសភាកម្ពុជា

១០៩ សម្រាប់ព័ត៌មានស្ដីពីការបង្កើតគណៈកម្មាធិការសុរិយោដី សូមមើល៖ World Bank. ២០០២. Cambodia - Land Management and Administration Project (English). Washington, DC: World Bank. http://documents.worldbank.org/curated/en/៦៤៣៨១១៤៦៨៧៧០៣៤៦៨៤២/Cambodia-Land-Management-and-Administration-Project

១១០ លើកលែងករណីទាក់ទងកេរ្តិ៍មរតក (រវាងអ្នកទទួលមរតក) ឬកិច្ចសន្យា (រវាងភាគីនៃកិច្ចសន្យា) ដែលនៅក្រោមយុត្តាធិការរបស់តុលាការ។

១១១ ការិយាល័យថ្នាក់ស្រុក និងថ្នាក់ខេត្តទទួលខុសត្រូវចំពោះកិច្ចការសម្របសម្រួលវិវាទបឋម។ សម្រាប់ករណីនានាដែលមិនអាចសម្រុះសម្រួលដោយជោគជ័យនៅថ្នាក់ស្រុក និងខេត្តនោះនឹងត្រូវបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិដើម្បីធ្វើការសំរេច។ នៅថ្នាក់ស្រុក និងថ្នាក់ខេត្តគឺអភិបាលស្រុក/ខេត្តជាប្រធានគណៈកម្មការសុរិយោដី គណៈដែលប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិគឺជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាន កង្វះខាតភាពច្បាស់លាស់ទៅលើយុត្តាធិការនៃយន្តការដោះស្រាយវិវាទនីមួយៗ បូករួមទាំងគណៈកម្មការសុរិយោដី"ដែលនាំអោយមានការយល់ច្រឡំសម្រាប់អ្នកប្តឹង"[112]។យោងតាមរបាយការណ៍ដដែលនេះ ពួកគេក៏មានបញ្ហាប្រឈមផ្សេងៗដើម្បីទទួលបានយន្តការនេះរួមមាន "យន្តការដោះស្រាយវិវាទខ្សោយដោយសារផលប៉ះពាល់ទៅលើបុគ្គល និងសហគមន៍ ការងាររដ្ឋបាលដែលស៊ីពេល និងបន្ទុកនីតិវិធី និងការចំណាយហិរញ្ញវត្ថុក្នុងការដាក់ពាក្យបណ្តឹង។[113] (...)បន្ថែមពីលើនេះដើមចោទបានរាយការណ៍ថា សេចក្តីសំរេចចេញដោយយន្តការដោះស្រាយវិវាទ គឺមិនស៊ីសង្វាក់ និងជាកម្មវត្ថុនៃសម្ពាធពីខាងក្រៅ"។ ជាងនេះទៅទៀត យោងតាមមជ្ឈមណ្ឌលសម្រាប់ឧត្តមសិក្សារបស់ធនាគារពិភពលោក និង GTZ ទោះគណៈកម្មការសុរិយោដីមានកំណត់ត្រាល្អប្រសើរក្នុងការ ដោះស្រាយទំនាស់ដីតូចៗ ពួកគេក៏តែងតែព្យាយាមពុះពារដោះស្រាយករណីស្មុគស្មាញនានាដែលពាក់ព័ន្ធពហុភាគី និងភាគីដែលមានទំនាក់ទំនងជាមួយអ្នកខាងក្រៅ។[114] របាយការណ៍ដដែលនេះបានសអោយឃើញថា "ខណៈករណីដែលអាចធ្លាក់ នៅក្រោមយុត្តាធិការរបស់គណៈកម្មការសុរិយោដី នោះភាគីដែលខ្សោយជាងអាចនឹងមិនដាក់ពាក្យបណ្តឹងទេដោយសារពុំមានទំនុកចិត្តចំពោះដំណើរការ និងលទ្ធផល"។ ជាងនេះទៅទៀត នៅក្នុងការសិក្សាដទៃរបស់ធនាគារពិភពលោក[115] អ្នកដែលពាក់ព័ន្ធវិវាទដីធ្លីជៀសវាងការដាក់ពាក្យបណ្តឹងពីព្រោះ "ស្ថាប័នយុត្តិធម៌ផ្លូវការដូចជាគណៈកម្មការសុរិយោដី ឬតុលាការត្រូវបានចាត់ទុកថាចំណាយច្រើនស៊ីពេល និងលម្អៀងទៅរកអ្នកមាន"។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយជនជាតិដើមភាគតិច ធ្វើការសម្ភាសជាមួយការិយាល័យ OHCHR បង្ហាញថា ជនជាតិដើមភាគតិចមានចំណេះដឹងតិចតួចស្តីពីវត្តមាន អាណត្តិ និងតួនាទីរបស់គណៈកម្មការសុរិយោដី។ ជាលទ្ធផល មានករណីវិវាទដីធ្លីជាច្រើនមិនត្រូវ

១១២ យន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា, PIC, កុម្ភៈ ២០១៦, អាចរកអានបាននៅ: https://www.pic.org.kh/images/២០១៦Research/២០១៦០៨០៥%២០Land%២០Dispute%២០Resolution%២០Mechanism_Eng.pdf

១១៣ ខណៈដែលពុំមានការដាក់តម្លៃសេវាផ្លូវការដូចការដាក់ពាក្យនៅតុលាការ ក៏នៅមានការចំណាយទៅលើការធ្វើដំណើរ ការបាត់បង់ប្រាក់ចំណូល និងជំនួយផ្នែកច្បាប់ ដែលជារឿយៗរាំងស្ទះបុគ្គលពាក់ព័ន្ធពីការទាមទារសំណងនៅចំពោះមុខយន្តការដោះស្រាយ។

១១៤ ធនាគារពិភពលោក, មជ្ឈមណ្ឌលសម្រាប់ឧត្តមសិក្សា និង GTZ, "ផ្លូវឆ្ពោះទៅកាន់ស្ថាប័នយុត្តិធម៌?" ការពិនិត្យឡើងវិញស្តីពីការងាររបស់គណៈកម្មាធិការភូមិបាល ពាក់ព័ន្ធការដោះស្រាយវិវាទដីធ្លី។ ទំព័រ xii,តុលា ២០០៦។

១១៥ ធនាគារពិភពលោក និងមជ្ឈមណ្ឌលសម្រាប់ឧត្តមសិស្សា "យុត្តិធម៌សម្រាប់អ្នកក្រ? ការសិក្សាស្រាវជ្រាវដើម្បីប្រមូលពាក្យបណ្តឹងពាក់ព័ន្ធការគ្រប់គ្រងដីធ្លីមូលដ្ឋាននៅកម្ពុជា"។ ទំព័រ៖ ៣៧, តុលា ២០០៦។

បានដោះស្រាយ និងពាក្យស្នើសុំចុះបញ្ជីដីសមូហភាពមួយចំនួនត្រូវបានទុកចោល។

### ❖ ការកម្រិតប្រភេទដីសម្រាប់ការចុះបញ្ជី

ដូចដែលបានកត់សម្គាល់ មាត្រា៦ នៃអនុក្រឹត្យ៨៣ ស្តីពី "នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច" អនុញ្ញាតអោយសហគមន៍ជនជាតិដើមភាគតិចចុះបញ្ជីប្រាំប្រភេទជាដីសមូហភាពរបស់ពួកគេ៖ ដីលំនៅឋាន និងដីចំការដាក់ស្តែង (ដែលជាដីឯកជនរបស់រដ្ឋ) និងដីបំរុង (ដីចំការវិលជុំ) ដីកប់សពនិងដីព្រៃអារក្ស(ដែលជាដីសាធារណៈរបស់រដ្ឋ)។[១១៦] សហគមន៍ជនជាតិដើមភាគតិចបានទទូចថា មានយ៉ាងហោចណាស់ដីពីរប្រភេទដែលមិនត្រូវបានរាប់បញ្ចូលក្នុងការចុះបញ្ជីដីសហគមន៍ ដូចជាដីសម្រាប់ចិញ្ចឹមសត្វពាហនៈ និងដីសម្រាប់សាងសង់សាលសហគមន៍។[១១៧]

### ❖ បទបញ្ញាផ្ទៃក្នុងដូចលក្ខន្តិកៈ

មាត្រា ៥ នៃអនុក្រឹត្យលេខ ៨៣ បញ្ញត្តិថាសហគមន៍ជនជាតិដើមភាគតិច "ត្រូវបង្កើតឡើងជាផ្លូវការជានីតិបុគ្គលស្របច្បាប់ ដែលមានបទបញ្ញាផ្ទៃក្នុងចែងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ដីជាសមូហភាព ព្រមទាំងការកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួនមានជាអាទិ៍ ការចាត់ចែងដីជា សមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទ លើការប្រើប្រាស់ដីតាមបែបប្រពៃណី។" ផ្អែកលើការអានឲ្យល្អិតល្អន់លើពាក្យទាំងនោះ វាហាក់ដូចជាថា បទបញ្ញាផ្ទៃក្នុង ហើយនិងលក្ខន្តិកៈដាក់ស្តែងគឺតែមួយ។

---

១១៦ អនុក្រឹត្យលេខ៨៣ អនក្រ/បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា មាត្រា៦ "ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិ សមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចមាន៖
១- ដីឯកជនរបស់រដ្ឋ ដូចជា៖
ដីលំនៅឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះដាក់ស្តែង ដីស្រែចម្ការ និង
២- ដីសាធារណៈរបស់រដ្ឋ ដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ ដូចជា៖
ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង
ដីព្រៃអារក្ស ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយទំហំសរុបមិនលើសពី ០៧ (ប្រាំពីរ) ហិកតា
ដីកប់ខ្មោច ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយទំហំសរុបមិនលើសពី ០៧ (ប្រាំពីរ) ហិកតា

១១៧ ទោះជាមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ត្រីអង្គការសង្គមស៊ីវិលមួយចំនួនបានលើកឡើងក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយការិយាល័យOHCHR ថា បញ្ហានេះត្រូវបានលើកយកទៅជជែកនៅពេលព្រាងអនុក្រឹត្យលេខ៨៣ និងបានសន្និដ្ឋានថា ដីទាំងពីរប្រភេទនេះត្រូវបានបូកបញ្ចូលក្នុងដីទាំងប្រាំប្រភេទរួចហើយ។ ទោះជាយ៉ាងណា ពុំមានឯកសារលាយលក្ខណ៍អក្សរ ឬភស្តុតាងណាមួយបញ្ជាក់ពីបញ្ហានេះទេ។

ដំណោះស្រាយត្រង់តែម្តងក្នុងការធ្វើឲ្យសាមញ្ញនូវដំណើរការ ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺការត្រឡប់ទៅមើលខាងដើមវិញនូវមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៣ រួចហើយចាត់ទុកលក្ខន្តិកៈ សហគមន៍ជនជាតិដើមភាគតិចដែលបានអនុម័តនៅក្នុងដំណាក់កាលទី២ ថាជាបទបញ្ជាផ្ទៃក្នុងវិញ ឬយើងអាចធ្វើការព្រាងសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងក្នុងពេលដំណាលគ្នាជាមួយលក្ខន្តិកៈដើម្បីកាត់បន្ថយចំនួនកិច្ចប្រជុំ។

## អនុសាសន៍របស់ការិយាល័យ OHCHR ជូនរដ្ឋាភិបាលកម្ពុជាដោយស្នើ៖

- ស្នើចាត់តាំងក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកទទួលខុសត្រូវគោលលើការ ផលិតផែនទីបឋម។
- តាមរយៈក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ធ្វើការណែនាំដល់ដៃគូថ្នាក់ក្រោមជាតិ (ការិយាល័យភូមិបាលស្រុក/មន្ទីររៀបចំ ដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី) ជាអ្នកអនុវត្តការផលិតផែនទី បឋម ដោយសហការជាមួយសហគមន៍ជនជាតិដើមភាគតិច និងវិភាជកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ការងារនេះ។ បន្ទាប់មកក្រសួងរៀបចំដែនដី នឹងធ្វើការអនុម័តទៅលើផែនទីឌីជីថលដែលបានផលិតរួមគ្នា។
- តាមរយៈធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ បន្ថែមពីលើការងារស្នូលនានា ធ្វើការពង្រឹងគណៈកម្មការសុរិយោដីខេត្តក្នុង ការដោះស្រាយវិវាទដីធ្លីដែលបានស្នើសុំដោយ សហគមន៍ជនជាតិដើមភាគតិចនៅក្នុងផែនទីបឋម និងផ្សព្វផ្សាយព័ត៌មាន អំពីអាណត្តិរបស់គណៈកម្មការសុរិយោដីខេត្ត និងនីតិវិធីនានាដល់សហគមន៍ជនជាតិដើមភាគតិច។
- ស្នើអោយ ការចុះបញ្ជីដីសមូហភាពដោយបូករួមទាំងដីវាលសម្រាប់ចិញ្ចឹមសត្វពាហនៈ និងដីសម្រាប់សង់សាលសហគមន៍បន្ថែមពីលើដីដែលបានចុះកន្លងមកដែលមានប្រាំប្រភេទនោះ (ដីលំនៅឋាន ដីចំការដាក់ស្តែង ដីចំការវិលជុំ ដីព្រៃអារក្ស និងដីព្រៃកប់សព)។
- ជានាថាការរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងត្រូវបានរៀបចំឡើងក្នុងពេលដំណាលគ្នាជាមួយលក្ខន្តិកៈសហគមន៍នៅក្នុងដំណាក់កាលទី២។

## ដំណាក់កាលទី៣៖ ការស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)

### ការអនុវត្តបច្ចុប្បន្ន

នៅពេលដែលការគូរផែនទីបឋម និងការតាក់តែងបទបញ្ញាផ្ទៃក្នុង ពាក់ព័ន្ធនឹងការគ្រប់គ្រងដី និងការដោះស្រាយវិវាទ ត្រូវបានឯកភាពផ្ទៃក្នុង ក៏ដូចជា ជាមួយនឹងភាគីពាក់ព័ន្ធខាងក្រៅ (ក្រុមប្រឹក្សាឃុំ និងសហគមន៍ជិតខាង) នោះសហគមន៍ត្រូវដាក់ជូនពាក្យស្នើសុំរបស់ខ្លួនដើម្បីចុះបញ្ជី សុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយភ្ជាប់ជាមួយនូវឯកសារចាំបាច់នានា មកកាន់ការិយាល័យរបស់ទីភ្នាក់ងារក្រសួងមហាផ្ទៃដើម្បី អនុម័ត (ដែលមានដូចជាសាលាឃុំ សាលាស្រុក សាលាខេត្ត និងថ្នាក់ក្រសួង)។ សន្មតថាដំណាក់កាលទាំងនេះ ត្រូវបានអនុវត្តតាមនោះ ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដី ជាប័ណ្ណកម្មសិទ្ធិដីសមូហភាព នៅការិយាល័យភូមិបាលស្រុក ដែលបន្ទាប់មកនឹងបញ្ជូនពាក្យស្នើសុំនេះ មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅរាជធានី។

### ឯកសារភ្ជាប់ទាំងប្រាំពីរដែលអមជាមួយនឹងពាក្យស្នើសុំមានដូចជា៖

- លិខិតពីក្រសួងមហាផ្ទៃដែលទទួលស្គាល់សហគមន៍ជានីតិបុគ្គល
- លិខិតពីប្រធានគណៈកម្មាធិការសហគមន៍ ដែលអនុញ្ញាតឲ្យផ្ទេរតំណែងជាប្រធានរបស់គាត់ទៅឲ្យសមាជិកគណៈកម្មាធិការសហគមន៍ នៅក្នុងករណីដែលប្រធានមិនអាចបំពេញភារកិច្ចរបស់គាត់បាន។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំដែលឯកភាពទៅលើការតែងតាំងគណៈកម្មាធិការគ្រប់គ្រងសហគមន៍។
- លក្ខន្តិកៈសហគមន៍
- បញ្ជីរាយនាមសមាជិកសហគមន៍ទាំងអស់ ដោយផ្ទៀងផ្ទាត់ បញ្ជីរាយនាមនោះពីសំណាក់មេឃុំ
- បទបញ្ញាផ្ទៃក្នុងរបស់សហគមន៍ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដី និងយន្តការដោះស្រាយវិវាទ។
- ផែនទីបឋមដែលមានបង្ហាញទីតាំង ទំហំ និងព្រំប្រទល់នៃដែនដីសហគមន៍។

នៅពេលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានវាយតម្លៃពាក្យស្នើសុំរួចហើយ នោះក្រសួងនឹងស្នើអភិបាលខេត្ត ឲ្យ

ប្រកាសជាតំបន់វិនិច្ឆ័យសម្រាប់សហគមន៍។ ប្រសិនបើការគូរផែនទីបឋមបានបញ្ជាក់ថាព្រំដីនៃក្បាលដី ត្រូវបានយល់ព្រមដោយភូមិជិតខាង (ដោយរួមទាំងអ្នកទទួលភារៈគ្រប់គ្រងដីរដ្ឋផង) នោះលោកអភិបាលស្រុក លោកអភិបាលខេត្ត នឹងចេញលិខិតជូនដំណឹងសាធារណៈមួយមិនឲ្យលើសពីរយៈពេល ២០ ថ្ងៃ មុនកាលបរិច្ឆេទវាស់វែងដីជាផ្លូវការ។[១១៨] នៅក្នុងករណីមានពាក្យបណ្ដឹងទៅលើផែនទីនោះ ផែនទីត្រូវធ្វើការកែសម្រួលឡើងវិញរហូតដល់ពាក្យបណ្ដឹង និងជម្លោះទាំងអស់ត្រូវបានដោះស្រាយជាស្ថាពរ។

វារឹតតែសំខាន់នៅក្នុងការវាយតម្លៃពាក្យស្នើសុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការសម្របសម្រួលជាមួយនឹងក្រសួងបរិស្ថាន ដើម្បីបញ្ជាក់ថាការស្នើសុំនេះមិនត្រួតគ្នាជាមួយនឹងដីដែលបានប្រកាសថាជាតំបន់ការពារ។ រាល់តំបន់ការពារដែលបានដាក់បញ្ចូលទៅក្នុងការស្នើសុំត្រូវដកចេញពីប័ណ្ណកម្មសិទ្ធិដីធ្លី។[១១៩]

ប្រសិនបើមានព្រំប្រទល់ច្បាស់លាស់ និងមាការបញ្ជាក់ច្បាស់ប្រាកដ តាមរយៈការចូលរួមរបស់ភូមិជិតខាងនៅក្នុងដំណើរការគូរផែនទីបឋម ដូច្នេះនៅពេលដែលរយៈពេល ២០ ថ្ងៃកន្លងផុតទៅ នោះក្រុមការងារថ្នាក់ស្រុក នឹងចុះពិនិត្យរួមគ្នាដល់មូលដ្ឋានជាមួយនឹងអ្នកតំណាង សហគមន៍ សហគមន៍ជិតខាង និងអាជ្ញាធររដ្ឋពាក់ព័ន្ធ (ដូចជារដ្ឋបាលព្រៃឈើ) ដើម្បីកំណត់ទីតាំង ព្រំប្រទល់ និងទំហំដីដែលសហគមន៍បានកាន់កាប់ និងប្រើប្រាស់ប្រភេទផ្សេងៗគ្នានៃដីរដ្ឋនៅក្នុងតំបន់[១២០] ព្រមទាំងកំណត់ព្រំប្រទល់នៃក្បាលដីនីមួយៗដែលបង្កើតជាទ្រព្យរួម របស់សហគមន៍នោះ។ ប្រធានក្រុមប្រឹក្សាឃុំក៏ត្រូវមានវត្តមានផងដែរ។ ការងារបច្ចេកទេសនឹងត្រូវអនុវត្តដោយ មន្ត្រីបោះបង្គោលព្រំប្រទល់ ដែលនឹងគូរជាផែនទី និងបង្កើតខ្នាតដែលចាំបាច់ សម្រាប់រៀបចំប្លង់សុរិយោដីពេញលេញដែលមានបង្ហាញទាំងអស់នូវក្បាលដី ហើយដែលត្រូវផលិតដោយមន្ទីរ

១១៨ ប្រសិនបើការគូរផែនទីបឋមមិនបានធានានូវការចូលរួមពេញលេញរបស់អ្នកជិតខាង និងអ្នកទទួលភារៈគ្រប់គ្រងដីរដ្ឋ ហើយព្រំប្រទល់មិនច្បាស់លាស់ នោះអភិបាលខេត្តត្រូវស្នើសុំក្រុមការងារដីរដ្ឋថ្នាក់ស្រុកឲ្យកំណត់អត្តសញ្ញាណដីរដ្ឋ គូរផែនទី និងចាត់ថ្នាក់ដី ទៅតាមប្រកាសលេខ ២០០៦។ នឹងមានការជូនដំណឹងចំនួន ២០ ថ្ងៃជាមុន។ ការងារអាចតម្រូវឲ្យមានការឧបត្ថម្ភថវិកាពីដៃគូអភិវឌ្ឍន៍ដើម្បីរ៉ាប់រងទៅលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សម្រាប់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក និងថ្នាក់ខេត្ត។

១១៩ អង្គការ GIZ ៖ ឯកសារបច្ចេកទេសស្ដីពីការចុះបញ្ជីដីជាសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិច – ការគូរផែនទីបឋម ការតាក់តែងបទបញ្ជាផ្ទៃក្នុង ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ឆ្នាំ ២០១៦, ៣៤។

១២០ ការងារវាល – ដែលត្រូវធ្វើឡើងដោយមន្ត្រីបោះបង្គោលព្រំ - នឹងចាត់ចំណាត់ថ្នាក់ដីរដ្ឋ ទៅក្នុងប្រភេទប័ណ្ណកម្មសិទ្ធិដីសហគមន៍អនាគត ជាដីឯកជនរបស់រដ្ឋនិងជាដីសាធារណៈរបស់រដ្ឋរួចហើយនឹងកំណត់ព្រំប្រទល់នៅលើក្បាលដីនីមួយៗដែលបង្កើតបានជាទ្រព្យសម្បត្តិរួមរបស់សហគមន៍។

ដែនដី នគរូបនីយកម្ម និងសំណង់ខេត្តនោះ។ ជារួម ការអនុវត្តនេះ គឺជាការបញ្ជាក់ភាពត្រឹមត្រូវដល់ផែនទីបឋម (មានន័យថាមន្ត្រីបច្ចេកទេសក៏នឹងផលិតនូវផែនទីតាម GPS ដែរ ដែលបានអនុវត្តជាមួយតំណាងសហគមន៍ និងភាគីពាក់ព័ន្ធផ្សេងៗដូចមានចែងនូវខាងលើ) ដែលសមាជិកសហគមន៍ និងអ្នកផ្សេងៗបានធ្វើរួចហើយជាផ្នែកនៃដំណាក់កាល២.៥។

នៅពេលប្លង់សុរិយោដីដែលបង្ហាញក្បាលដីទាំងអស់ត្រូវបានរៀបចំរួចរាល់នោះអភិបាលខេត្តនឹងប្រកាសបិទផ្សាយជាសាធារណៈនូវផែនទីព្រាងសម្រាប់រយៈពេល ៣០ ថ្ងៃ នៅសាលាឃុំ និងការិយាល័យភូមិបាលស្រុក។ ប្រសិនបើមិនមានបណ្តឹងណាមួយទេ នោះផែនទីដែលបានចុះហត្ថលេខា និងឯកសារវិនិច្ឆ័យនឹងត្រូវដាក់ជូនរដ្ឋបាលសុរិយោដីនៅក្នុងរយៈពេល ១៥ ថ្ងៃ ដើម្បីចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិស្ថាពរ។ កិច្ចការនេះត្រូវដោះស្រាយដោយមន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ដែលទទួលបានអំណាចប្រតិភូដើម្បីដោះស្រាយកិច្ចការនេះ ហើយមន្ទីរត្រូវរៀបចំនូវរបាយការណ៍មួយស្តីពីដំណើរការវិនិច្ឆ័យ។

ដំណាក់កាលចុងក្រោយ មន្ត្រីរដ្ឋាភិបាលដែលបានតែងតាំង នឹងប្រគល់ប័ណ្ណកម្មសិទ្ធិដល់សហគមន៍នៅក្នុងពិធីប្រគល់មួយនៅក្នុងភូមិ។ ប័ណ្ណកម្មសិទ្ធិនឹងត្រូវចេញក្នុងនាមសហគមន៍ដែលតំណាងឲ្យនីតិបុគ្គល (ជាជាងក្នុងនាមគណៈកម្មាធិការគ្រប់គ្រងដែលស្ថិតនៅក្រោមនីតិបុគ្គលនោះ)។

## បញ្ហា

### ❖ ការចំណាយ និងភាពវែងអន្លាយ

អង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រសហគមន៍ជនជាតិដើមភាគតិចទៅលើដំណាក់កាលចុងក្រោយនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ដោយរួមទាំងការរៀបចំនូវផែនទីបឋម ដែលចំណាយពេលជាមធ្យមពី ៣-៤ ឆ្នាំ។ ភាពយឺតយ៉ាវនេះកើតឡើងអាស្រ័យទៅលើបញ្ហាជាច្រើន ដែលមានដូចជាសមត្ថភាពមានកម្រិត និងថវិកាមានកម្រិតរបស់សហគមន៍ជនជាតិដើមភាគតិច និងរបស់អង្គការមិនមែនរដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍ ការមិនព្រមព្រៀងគ្នាទៅលើព្រំប្រទល់ និងសុឆន្ទៈរបស់អាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយជម្លោះទាំងនេះ។ ចំណាយក៏នឹងប្រែប្រួលទៅតាមនោះដែរ។ ទោះជាដូច្នេះក៏ដោយ ការវាយតម្លៃមួយដែលធ្វើឡើងដោយអង្គការ GIZ

បានលើកឡើងពោល គឺដោយផ្អែកលើការចូលរួមពាក់ព័ន្ធរបស់ខ្លួនជាយូរមកហើយជាមួយនឹងការគាំទ្រសហគមន៍សម្រាប់ដំណាក់កាលពីរចុងក្រោយ (ដំណាក់កាលទី២.៥ និងដំណាក់កាលទី៣) – ថាការបោះបង្គោលព្រំប្រទល់នឹងមានចំនួនទឹកប្រាក់ត្រឹមតែ៣០,០០០ ដុល្លារអាមេរិកប៉ុណ្ណោះ។ ក៏គួរកត់សម្គាល់ដែរថាការព្យាករណ៍ចំណាយសម្រាប់ដំណាក់កាលទី២.៥ (ជាមធ្យមដែលមានទឹកប្រាក់ចំនួនយ៉ាងតិចណាស់៨,០០០ដុល្លារអាមេរិក/សហគមន៍) មិនត្រូវបានរាប់បញ្ចូលទេ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានប្រើប្រាស់នូវថវិកាប្រចាំឆ្នាំរបស់ខ្លួនចំនួន ៣០០,០០០ ដុល្លារអាមេរិក ដើម្បីបញ្ជូនថវិកានេះ ទៅការិយាល័យថ្នាក់ខេត្តរបស់ខ្លួនដើម្បីគាំទ្រការងាររបស់ការិយាល័យទាំងនោះនៅក្នុងការវាស់វែង និងចុះបញ្ជីដី។ នៅក្នុងចំណោមក្រសួង ពាក់ព័ន្ធសំខាន់ៗចំនួនបីដែលជាប់ទាក់ទងនឹងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាសមូហភាព មានតែក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មួយគត់ ដែលបានលៃទុកនូវថវិការបស់ខ្លួន សម្រាប់គាំទ្រមន្រ្តីថ្នាក់ក្រោមជាតិក្នុងការបំពេញនូវភារកិច្ចរបស់ពួកគេដើម្បីចុះបញ្ជីដីធ្លី។ មន្រ្តីក្រសួងនៅរាជធានីភ្នំពេញបានកត់សម្គាល់ថា ជាមួយនឹងទឹកប្រាក់ចំនួន ៣០០,០០០ ដុល្លារអាមេរិក នោះពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពប្រមាណចំនួនដប់អាចត្រូវបានត្រួតពិនិត្យជារៀងរាល់ឆ្នាំ។ យ៉ាងនេះក្តី នេះគឺជាព្យាករណ៍ក្នុងចំនួនប្រហាក់ប្រហែលតែប៉ុណ្ណោះ ពីព្រោះតួលេខពិតប្រាកដនឹងអាស្រ័យទៅលើទំហំដីដែលបានស្នើសុំ និងពេលវេលា ដែលត្រូវចំណាយទៅមូលដ្ឋានដើម្បីវាស់វែង។

យើងក៏កត់សម្គាល់ផងដែរថា ពាក្យស្នើសុំចុះបញ្ជីដីជាសមូហភាពមួយចំនួន ត្រូវបានបដិសេធពី ព្រោះតែការព្រមព្រៀងជាមួយនឹងសហគមន៍ជិតខាង ឬសម្បទានិកមិនអាចសម្រេចបានដោយសារអាជ្ញាធរមិនអនុម័តទៅលើទំហំដែលបានអះអាង[១២១] ទោះបីជាច្បាប់ភូមិបាលមិនបានដាក់កំណត់ណាមួយទៅលើទំហំដី ដែលអាចស្នើសុំបានក៏ដោយ ហើយអនុក្រឹត្យលេខ ៨៣ មានចែងអំពីការកំណត់ទំហំដូច្នេះមែន ប៉ុន្តែការកំណត់ទំហំនេះវាពាក់ព័ន្ធជាមួយនឹងតំបន់ព្រៃអារក្ស និងតំបន់កប់ខ្មោចតែប៉ុណ្ណោះ។

---

១២១ អង្គការ GIZ ៖ មេរៀនដែលបានរៀនពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៦។

## ❖ មិនអាចចុះបញ្ជីដីដែលនៅក្នុងតំបន់ការពារជាដីសម្ភូហភាពបានឡើយ

ដូចដែលបានគូសបញ្ជាក់ពីខាងដើម នៅក្នុងការវាយតម្លៃពាក្យស្នើសុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងទំនាក់ទំនងជាមួយនឹងក្រសួងបរិស្ថាន និង២មន្ទីរពាក់ព័ន្ធរបស់ខ្លួន ទាំងនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ដើម្បីបញ្ជាក់ថាការស្នើសុំដីនោះមិនជាន់គ្នាជាមួយនឹងតំបន់ការពារ។ រាល់តំបន់ការពារដែលបានបញ្ចូលក្នុងពាក្យស្នើសុំចុះបញ្ជីនោះត្រូវដកចេញពីប័ណ្ណកម្មសិទ្ធិ រហូតដល់សម្រេចបាននូវការព្រមព្រៀងជាមួយនឹងក្រសួងបរិស្ថានទៅលើរបៀបដាក់បញ្ចូលតំបន់ទាំងនោះទៅក្នុងប័ណ្ណកម្មសិទ្ធិស្ថាពរ។

នៅខែឧសភា ឆ្នាំ២០១៩ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើត "ក្រុមការងារបច្ចេកទេសដើម្បីអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច"(សេចក្ដីសំរេចលេខ១៤៨/១៩ចុះថ្ងៃទី០៦ឧសភា២០១៩)។ការបង្កើតនេះគួរធ្វើអោយប្រសើរឡើងនូវការសម្របសម្រួល និងទំនាក់ទំនងរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន ក្នុងន័យកាត់បន្ថយពេលវេលាដំណើរការពាក្យសុំចុះបញ្ជីដីសម្ភូហភាព។ តែគួរឲ្យស្ដាយ ក្រោយពេលវត្តមានក្នុងរយៈពេលតិចជាងមួយឆ្នាំ ក្រសួងអភិវឌ្ឍន៍ ជនបទបានសំរេចនិរាករណ៍ក្រុមការងារបច្ចេកទេសនេះ (សេចក្ដីសំរេចលេខ០៤១ចុះថ្ងៃទី០៤កុម្ភៈ២០២០)ដោយពុំមានផ្ដល់ហេតុផលផ្លូវការណាមួយឡើយ។

បច្ចុប្បន្ននេះ គឺការមិនមានដំណើរការដែលអនុញ្ញាតឲ្យសហគមន៍ អាចជំទាស់ទៅនឹងសេចក្ដីណែនាំ ចេញដោយក្រសួងបរិស្ថានបាន។ ជារឿយៗ សហគមន៍អញ្ជើញអាជ្ញាធរមកពីក្រសួងនានា ចូលរួមនៅក្នុងការគូរផែនទីបឋម ប៉ុន្តែទីភ្នាក់ងាររបស់រដ្ឋាភិបាលទាំងនេះកម្រចូលរួម។

នៅថ្ងៃទី០៣ កក្កដា ២០២០ នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីបានណែនាំរដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាត់ឆ្វៀលដី និងផ្ដល់កម្មសិទ្ធិដីជូនប្រជាពលរដ្ឋដែលបានកាន់កាប់ និងអាស្រ័យផលយូរឆ្នាំមកហើយ នៅលើទីតាំងដីដែលនៅក្នុងតំបន់ការពារ។ នាយករដ្ឋមន្ត្រីបន្ថែមថា ក្រៅពីដីដែលកំពុងកាន់កាប់ និងអាស្រ័យផលត្រូវបន្ថែមការត្រៀមបំរុងដី ១០% សម្រាប់ការប្រើប្រាស់របស់ សហគមន៍ "សម្រាប់រកឧស ឬសម្រាប់ចិញ្ចឹមសត្វពាហនៈ"។

ជាលទ្ធផល នៅថ្ងៃទី០៦ កក្កដា ២០២០ រដ្ឋមន្ត្រីក្រសួងបរិស្ថានបានចេញលិខិតទៅកាន់អភិបាលខេត្តនានាដើម្បីស្នើសុំឯកសារពាក់ព័ន្ធនឹងបញ្ហាដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ។ ក្រសួងកសិកម្មក៏បានបង្កើតក្រុមការងារចំនួន១៨ក្រុមដើម្បី ចុះស្រាវជ្រាវ និងផ្ទៀងផ្ទាត់ទិន្នន័យដីព្រៃដែលប្រជាពលរដ្ឋកាន់កាប់អាស្រ័យផលជាក់ស្តែងនៅទូទាំង២៤ខេត្តក្រុង"។ នៅមិនទាន់ច្បាស់នៅឡើយទេថា តើសារាចរណែនាំថ្មីនេះនឹងត្រូវអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិចដែលមានទីតាំងក្នុងតំបន់ការពារយ៉ាងណានោះទេ។

**ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជា ដូចតទៅ ៖**

- ចេញសារាចរណែនាំដល់រដ្ឋបាលស្រុកទាំងអស់ស្តីពីតួនាទីនិងភារកិច្ចថ្មីពិសេសពាក់ព័ន្ធនីតិវិធីចុះបញ្ជីដីសម្មូហភាព (ដំណាក់កាលទី៣) អនុលោមតាមអនុក្រឹត្យ១៨៤ អនក្រ/បក "ស្តីពីតួនាទីនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក" ចុះថ្ងៃទី ០២ ធ្នូ ២០១៩។
- បង្កើត យន្តការជាផ្លូវការដោះស្រាយពាក្យបណ្តឹង នៅកម្រិតថ្នាក់ក្រសួង (ទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន) ដើម្បីអនុញ្ញាតឲ្យសហគមន៍អាចជំទាស់បានទៅនឹងសេចក្តីសំរេចរបស់ក្រសួងពាក់ព័ន្ធនឹងប័ណ្ណកម្មសិទ្ធិដីសម្មូហភាពរបស់សហគមន៍។
- បកស្រាយ អំពីដំណើរការសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលស្នើសុំចុះបញ្ជីដីដែលមានទីតាំងក្នុងតំបន់ការពារ ដូចដែលបានណែនាំដោយសម្តេចនាយករដ្ឋមន្ត្រីកាលពីថ្ងៃទី ០៣ កក្កដា ២០២០។

# និន្នាការទូទៅនៃអនុសាសន៍សំខាន់ៗរបស់ការិយាល័យ OHCHR

| ដំណាក់កាល | ក្រសួង | ការអនុវត្តក្នុងពេលបច្ចុប្បន្ន | មូលដ្ឋានច្បាប់ | សំណូមពរការផ្លាស់ប្តូរ | វិសោធនកម្មច្បាប់/អនុក្រឹត្យដែលត្រូវធ្វើឡើងឆ្លើយតបតាមសំណូមពរឲ្យផ្លាស់ប្តូរ? |
|---|---|---|---|---|---|
| គ្រប់ដំណាក់កាល | ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | អនុក្រឹត្យលេខ ១៨៤ អនក្រ/បក "ស្តីពីតួនាទីនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក" ចុះថ្ងៃទី ០២ ធ្នូ ២០១៩ | ចេញសារាចរណែនាំដល់រដ្ឋបាលស្រុកទាំងអស់ស្តីពីតួនាទី និងភារកិច្ចថ្មី ពិសេសពាក់ព័ន្ធនីតិវិធីចុះបញ្ជីដីសម្ងហភាព។ | គ្មាន |
| ១ | ក្រសួងអភិវឌ្ឍន៍ជនបទ | បន្ទាប់ពីការធ្វើស្វ័យអត្តសញ្ញាណកម្មសហគមន៍ជាជនជាតិដើមភាគតិចរួចហើយ នោះក្រសួងអភិវឌ្ឍន៍ជនបទ នឹងវាយតម្លៃឋានៈជនជាតិដើមភាគតិចរបស់សហគមន៍ហើយ និងចេញលិខិតទទួលស្គាល់ ប្រសិនបើក្រុម (ជនជាតិដើមភាគតិច) ឆ្លើយតបនឹងល័ក្ខខ័ណ្ឌវាយតម្លៃរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ | ច្បាប់ភូមិបាលទទួលស្គាល់ច្បាស់លាស់ទៅលើសិទ្ធិដីធ្លីជាសម្ងហភាពសម្រាប់ជនជាតិដើមភាគតិច ក្រៅពីសិទ្ធិជាសម្ងហភាពសម្រាប់វត្តអារ៉ាម។ មាត្រា ២៣-២៨ ពាក់ព័ន្ធជាមួយនឹងសហគមន៍ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេក្នុងការគ្រប់គ្រងដីជាសម្ងហភាព។ | វិសាលភាពនៃក្រុម (ជនជាតិដើមភាគតិច) ដែលមានលក្ខណៈសម្បត្តិទទួលបានប័ណ្ណកម្មសិទ្ធិដីសម្ងហភាពគួរពង្រីកបន្ថែម ដើម្បីដាក់បញ្ចូលសហគមន៍ទាំងអស់ដែលមានរបៀបរបបសិទ្ធិកាន់កាប់ដីតាមបែបប្រពៃណីរបស់ខ្លួន។ | បាទ/ចាស (ត្រូវធ្វើឡើង) ទាំងទៅលើច្បាប់ភូមិបាល និង អនុក្រឹត្យលេខ ៨៣។ |

| | | | | | |
|---|---|---|---|---|---|
| | | | | ដំណើរការរបស់រដ្ឋាភិបាលក្នុងការ "ទទួលស្គាល់" សហគមន៍ជនជាតិដើមភាគតិចគួរកាត់បន្ថយឲ្យនៅតិចបំផុត និងត្រូវផ្អែកលើការយល់ឃើញផ្ទាល់របស់សហគមន៍ទៅលើឋានៈជាជនជាតិដើមភាគតិចរបស់ពួកគេ ("ស្វ័យកំណត់អត្តសញ្ញាណ") ជាជាងការវាយតម្លៃរបស់ក្រសួងទៅលើប្រពៃណី និងជីវភាពរបស់ពួកគេ។ | ទេ |
| ២ | ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃនៅថ្នាក់ខេត្ត (សាលាខេត្ត) យោងតាមទ្រឹស្តី គឺជាអ្នកគាំទ្រសហគមន៍ជនជាតិដើមភាគតិចក្នុងការតាក់តែងលក្ខន្តិកៈរបស់ពួកគេ។ ប៉ុន្តែការងារនេះត្រូវជួបឧបសគ្គដោយសារកង្វះថវិកា ដូច្នេះហើយអង្គការមិនមែនរដ្ឋាភិបាលហាក់ដូចជាទទួលខុសត្រូវទៅវិញ។ | ច្បាប់ភូមិបាល មាត្រា ៨ ចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។<br><br>អនុក្រឹត្យលេខ ៨៣, មាត្រា ៥ ចែងថា សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ មាន | ក្រសួងអភិវឌ្ឍន៍ជនបទទទួលខុសត្រូវក្នុងការគាំទ្រសហគមន៍នៅក្នុងការព្រាងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេ ដែលជាផ្នែកមួយនៅក្នុងដំណាក់កាលទី១ នៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព។ រាល់ឯកសារតម្រូវទាំងអស់នៅ | ហេតុដូច្នេះហើយ ការផ្ទេរការទទួលខុសត្រូវចម្បងៗក្នុងការតាក់តែងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចទៅឲ្យក្រសួងអភិវឌ្ឍន៍ជនបទនឹងមិនតម្រូវឲ្យធ្វើវិសោធនកម្មណាមួយឡើយ ឲ្យតែក្រសួង |

| | | | | | |
|---|---|---|---|---|---|
| | | នៅពេលដែលលក្ខន្តិកៈត្រូវបានតាក់តែងរួច ហើយឯកសារគាំទ្រត្រូវបានដាក់ជូនក្រសួងនៅថ្នាក់ជាតិ នោះសហគមន៍នឹងត្រូវបានទទួលស្គាល់ជានីតិបុគ្គល។ | លក្ខន្តិកៈដែលបានចុះបញ្ជី និងមានការទទួលស្គាល់ជាផ្លូវការ អាចដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពបាន។<br>មាត្រា ៥ ក៏បានចែងទៀតថា សហគមន៍ជានីតិបុគ្គលស្របច្បាប់ ដែលមានបទបញ្ញាផ្ទៃក្នុងសហគមន៍ចែងអំពីការគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព ព្រមទាំងការកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួន មានជាអាទិ៍ការចាត់ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលកម្រិតសហគមន៍ក្នុងករណីវិវាទលើការប្រើប្រាស់ដីតាមបែបប្រពៃណី។<br>មាត្រា ៤ ចែងថា សហគមន៍ដែលបានបង្កើតជានីតិ | ពេលនោះនឹងត្រូវបញ្ជូនទៅក្រសួង មហាផ្ទៃ ដើម្បីអនុម័តដោយមិនជំទាស់។ | មហាផ្ទៃគឺជាទីភ្នាក់ងារដែលចេញ (លិខិតទទួលស្គាល់សហគមន៍ជានីតិបុគ្គល)។ ការធ្វើឲ្យមានការផ្លាស់ប្តូរលំដាប់លំដោយនៃដំណាក់កាលកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច តម្រូវឲ្យធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ៨៣ មាត្រា ៥។ |

| | | | | | |
|---|---|---|---|---|---|
| | | | បុគ្គលសំដៅដល់សហគមន៍ជនជាតិដើមភាគតិចដែលបានចងក្រង និងចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងមហាផ្ទៃ។ | | |
| ២ | ក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃបញ្ជាក់ភាពត្រឹមត្រូវដល់លក្ខន្តិកៈរបស់សហគមន៍ និងឯកភាពទៅលើគណៈកម្មការគ្រប់គ្រងសហគមន៍ដែលតាមរយៈនេះនឹងផ្ដល់ឲ្យសហគមន៍នូវឋានៈរបស់ខ្លួនជានីតិបុគ្គលរួមមួយដែលមានលក្ខណៈសម្បត្តិដើម្បីកាន់កាប់ដីសមូហភាព។ | ច្បាប់ភូមិបាល មាត្រា៨ ចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។<br>អនុក្រឹត្យលេខ ៨៣, មាត្រា ៥ ចែងថា សហគមន៍ដែលបានបង្កើតជានីតិបុគ្គលស្របច្បាប់ មានលក្ខន្តិកៈដែលបានចុះបញ្ជី និងមានការទទួលស្គាល់ជាផ្លូវការ អាចដាក់ពាក្យសុំចុះបញ្ជីដីកម្មសិទ្ធិសមូហភាពបាន។<br>មាត្រា ៥ ក៏បានចែងទៀតថា សហគមន៍ | បំភ្លឺអំពីវិសាលភាពប៉ុណ្ណាដែលច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអនុវត្តចំពោះសហគមន៍ជនជាតិដើមភាគតិចដែលមានបំណងចុះបញ្ជីជានីតិបុគ្គល។ | ទេ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ជានីតិបុគ្គលស្រប ច្បាប់ ដែលមាន បទបញ្ញាផ្ទៃក្នុង សហគមន៍ចែងអំពី ការគ្រប់គ្រង និង ការប្រើប្រាស់ដីជា សមូហភាព ព្រម ទាំងការកំណត់នូវ ល័ក្ខខ័ណ្ឌមួយចំនួន មានជាអាទិ៍ ការចាត់ ចែងដីជាសមូហភាព ការប្រើប្រាស់ដីទៅ តាមប្រភេទដី និង ការសម្រុះសម្រួល កម្រិតសហគមន៍ ក្នុងករណីវិវាទលើ ការប្រើប្រាស់ដីតាម បែបប្រពៃណី។<br><br>មាត្រា ៤ ចែងថា សហគមន៍ដែល បានបង្កើតជានីតិ បុគ្គលសំដៅដល់ សហគមន៍ជនជាតិ ដើមភាគតិចដែល បានចងក្រង និង ចុះបញ្ជីទទួលស្គាល់ ជាផ្លូវការនៅក្រសួង មហាផ្ទៃ។ | | |

| | | | | | |
|---|---|---|---|---|---|
| ២.៥ | គ្មានក្រសួងជាក់លាក់ទទួលខុសត្រូវនៅឡើយ | ទោះបីជាដំណាក់កាលផ្សេងទៀត នៅក្នុងដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ត្រូវបានកំណត់ភ្ជាប់ច្បាស់លាស់ទៅកាន់ក្រសួងជាក់លាក់ណាមួយហើយក៏ដោយ ក៏ដំណាក់កាលទី២.៥ មិនត្រូវបានកំណត់ភ្ជាប់ទៅនឹងក្រសួងណាមួយឡើយ។ ហេតុដូច្នេះហើយសហគមន៍ជនជាតិដើមភាគតិចនឹងត្រូវទុកចោលនៅក្នុងករណីអវត្តមានអន្តរការី ដោយសារតែផ្នែកមួយនៅក្នុងចំណោមផ្នែកដ៏ស្មុគស្មាញបំផុតនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។ | គ្មានឯកសារយោង | កំណត់អាណត្តិ (មុខងារ និងកាតព្វកិច្ច) ឲ្យបានច្បាស់លាស់សម្រាប់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីគាំទ្រសហគមន៍ជនជាតិដើមភាគតិចនៅក្នុងដំណើរការគូរផែនទីបឋម<br><br>ការផលិតផែនទីបឋមត្រូវជាសកម្មភាពរួមគ្នារវាងមន្ត្រីភូមិបាល និងសហគមន៍ជនជាតិដើមភាគតិច ដោយមានការគាំទ្រពីសមាជិកក្រុមការងារគ្រប់គ្រងដីរដ្ឋថ្នាក់ស្រុក។<br><br>ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់គួរណែនាំមន្ត្រីថ្នាក់ក្រោមជាតិរបស់ខ្លួនដើម្បីគាំទ្រការធ្វើផែនទីបឋម និងវិភាជកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់សម្របសម្រួលការ | សេចក្តីណែនាំអាចចេញដោយក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់បាន |

| | | | | | |
|---|---|---|---|---|---|
| | | | | ចូលរួមរបស់ពួកគេ។ ក្រសួងនឹងអនុម័តផែនទីលម្អិតដែលផលិតរួមគ្នានេះ។ | |
| ២.៥ | គ្មានក្រសួងជាក់លាក់ទទួលខុសត្រូវនៅឡើយ | ផ្អែកលើការអានឲ្យល្អិតល្អន់ទៅលើអនុក្រឹត្យលេខ ៨៣ មាត្រា ៥ វាហាក់ដូចជាថាបទបញ្ញាផ្ទៃក្នុង ហើយនិងលក្ខន្តិកៈ ជាក់ស្តែងគឺតែមួយ។ យ៉ាងនេះក្តី នៅក្នុងការអនុវត្តបច្ចុប្បន្ន នេះមិនមែនជាករណី (បញ្ហា) នោះទេ ពីព្រោះថាលក្ខន្តិកៈបានក្លាយទៅជាផ្នែកមួយនៃដំណាក់កាលទីពីររួចហើយ និងក៏ត្រូវបានដោះស្រាយដោយក្រសួងមហាផ្ទៃដែរ ហើយភាគីទាំងឡាយដែលបានឯកភាពមកដល់បច្ចុប្បន្ននេះក៏បានចូលរួមជាទូទៅ និងជាក់លាក់នៅក្នុងការគ្រប់គ្រងដី និងយន្តការសម្រុះសម្រួលវិវាទផងដែរ។ | អនុក្រឹត្យលេខ ៨៣ មាត្រា ៥ ដែលចែងថាសហគមន៍ជនជាតិដើមភាគតិច "ត្រូវបង្កើតជាផ្លូវការជានីតិបុគ្គលដែលមានបទបញ្ញាផ្ទៃក្នុងចែងអំពីការគ្រប់គ្រងនិងប្រើប្រាស់ដីសមូហភាព ក៏ដូចជាការកំណត់នូវលក្ខខណ្ឌមួយចំនួនដូចជាការគ្រប់គ្រងដី សមូហភាព និងការប្រើប្រាស់ដីទៅតាមប្រភេទដី និងការសម្រុះសម្រួលនៅក្នុងកម្រិតថ្នាក់សហគមន៍ប្រសិនបើមានវិវាទ។" | បង្កើតសេចក្តីព្រាងបទបញ្ញាផ្ទៃក្នុងក្នុងពេលតែមួយជាមួយលក្ខន្តិកៈ ឬបញ្ចូលអោយទៅជាឯកសារតែមួយ។ | ទេ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | នៅក្នុងការវាយតម្លៃពាក្យស្នើសុំចុះបញ្ជីដីសមូហភាព នោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់នឹងទំនាក់ទំនងជាមួយនឹងក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនីមួយៗនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដើម្បីបញ្ជាក់ថាការស្នើសុំនេះមិនត្រួតគ្នាជាមួយនឹងដីដែលបានប្រកាសថាជាតំបន់ការពារឡើយ។ រាល់តំបន់ការពារដែលបានដាក់បញ្ចូលក្នុងពាក្យសុំចុះបញ្ជីត្រូវដកចេញពីប័ណ្ណកម្មសិទ្ធិ រហូតដល់សម្រេចបាននូវការព្រមព្រៀងជាមួយនឹងក្រសួងបរិស្ថានទៅលើរបៀបដាក់បញ្ចូលតំបន់ទាំងនោះទៅក្នុងប័ណ្ណកម្មសិទ្ធិស្ថាពរ។ | -គ្មានឯកសារយោង | គួរធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៨៣ ដើម្បីកំណត់ឲ្យបានច្បាស់នូវតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងបរិស្ថានក្នុងករណីការស្នើសុំមានការត្រួតស៊ីគ្នាជាមួយតំបន់ការពារ។<br>ដំណើរការសម្រាប់សហគមន៍ធ្វើឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់ក្រសួងបរិស្ថាននេះក៏គួរបញ្ជាក់ផងដែរ។ | បាទ |

| | | | | | |
|---|---|---|---|---|---|
| | | មិនទាន់មានដំណើរការសម្រាប់សហគមន៍ដើម្បីប្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចនេះទ្បើយ។ | | | |
| ៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | នៅថ្ងៃទី ០៣ កក្កដា ២០២០ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបាននាយករដ្ឋមន្ត្រីដើម្បី "ធ្វើការវាស់វែដី និងចេញប័ណ្ណកម្មសិទ្ធិជូនពលរដ្ឋដែលបានកាន់កាប់យូរឆ្នាំមកហើយលើដីមានទីតាំងក្នុងតំបន់ការពារ(...) និងត្រូវត្រៀមដប់ភាគរយបន្ថែមទៀតសម្រាប់ការប្រើប្រាស់ជាសមូហភាព"។ | សេចក្ដីប្រកាសព័ត៌មានលេខ ៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីស្ដីពីលទ្ធផលនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃទី០៣ កក្កដា ២០២០។ | នឹងបញ្ជាក់នៅពេលមានការបញ្ចេញនីតិវិធីជាសាធារណៈ | នៅពេលនេះ មិនទាន់ដឹងទេ |

# ផ្នែកទី IV ៖ បញ្ហាដែលត្រូវពិចារណា

## កង្វះខាតទិន្នន័យបំបែកអំពីជនជាតិដើមភាគតិច

នៅកម្ពុជា ជនជាតិដើមភាគតិច ត្រូវបានប៉ាន់ប្រម៉ាណថាមានចំនួនប្រហែល ២០០,២១៦ ឬ ១,២% នៃតួលេខប្រជាពលរដ្ឋសរុប។ រាជរដ្ឋាភិបាលបានចាត់ជនជាតិដើមភាគតិចនៅកម្ពុជាជា២៤ក្រុម[១២២] រស់នៅក្នុងខេត្តចំនួន ១៥។[១២៣] តាមការប៉ាន់ប្រម៉ាណ តួលេខពិតប្រាកដអាចខុសគ្នារវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងភ្នាក់ងារសហប្រជាជាតិ ដោយមានចំនួនតិចជាងពីរភាគរយនៃស្ថិតិប្រជាពលរដ្ឋសរុប។ ស្ថិតិជនជាតិដើមភាគតិចនៃក្រុមនីមួយៗក៏មិនច្បាស់លាស់ ដូចជាតួលេខចន្លោះពី៤៥៥ ដល់៦០០ សហគមន៍។

ទោះជាយ៉ាងណា មានទិន្នន័យអាចជឿទុកចិត្តបានតិចតួច ដើម្បីបញ្ជាក់អំពីស្ថិតិជនជាតិដើមភាគតិចពិតប្រាកដនៅកម្ពុជា។ តាមការជំរឿនជាតិនៅឆ្នាំ២០០៨ និងមិនបានផ្តល់តួលេខប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិចទេ។ កង្វះខាតទិន្នន័យបំបែកនៃជនជាតិនីមួយៗធ្វើអោយពិបាកក្នុងការប៉ាន់ស្មានចំនួនជាក់លាក់ ទាំងចំពោះជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិច។ប្រសិនបើព័ត៌មាន ដែលបានប្រមូលដោយក្រសួងផែនការនៅក្នុងជំរឿនថ្នាក់ជាតិឆ្នាំ១៩៩៨ បានបំពេញតួនាទីត្រឹមជាបញ្ជីបណ្តោះអាសន្នស្តីពីក្រុមជនជាតិដើមភាគតិចយោងលើលក្ខណៈវិនិច្ឆ័យនៃភាសាដើមកំណើត ចំណេះដឹងរបស់ជនជាតិដើមភាគតិចទោះលើអាជ្ញាធររដ្ឋ

១២២ ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ ការ៉ែត ស្ទៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្អូច រដែ ខិ អេង ស្តុង ល្អឺន សំរែ និងជនជាតិដើមភាគតិចផ្សេងៗទៀត។

១២៣ ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិសត្វ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ និងខេត្តសៀមរាប។

និងប្រវត្តិនៃកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាប អាចជាហេតុផលនាំអោយមនុស្សជាច្រើនមិនហានបញ្ចេញភាសាដើមកំណើតរបស់ពួកគេក្នុងកិច្ចសិក្សាស្រាវជ្រាវបែបនេះ។[១២៤]

នៅពេលអវត្តមានទិន្នន័យបំបែកអំពីជនជាតិដើមភាគតិចនេះ ធ្វើឲ្យការរៀបចំកិច្ចអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ចំគោលដៅ និងផ្អែកលើភស្តុតាងនៅតែជាបញ្ហាប្រឈមដដែល។ កិច្ចនេះ រួមបញ្ចូលនូវលទ្ធភាពតាមដានវឌ្ឍនភាពឆ្ពោះទៅរកសមិទ្ធិផល នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែរ។

**អនុសាសន៍របស់ការិយាល័យ OHCHR៖**

សម្រាប់ជំរឿន ថ្នាក់ជាតិលើកក្រោយ ទិន្នន័យគួរបែងចែកទៅតាមជនជាតិភាគតិចនីមួយៗដោយដាក់បញ្ចូលទាំងអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចទាំងនោះផងដែរ ដើម្បីឲ្យអាចវាយតម្លៃយ៉ាងសុក្រឹត្យចំពោះឧបសគ្គដែលរាំងដល់ការទទួលបានសិទ្ធិមនុស្សពេញលេញរបស់ពួកគេដែលកំពុងរស់នៅក្នុងប្រទេស និងដើម្បីឲ្យមានការចាត់វិធានការកែតម្រូវ។

## វិសាលភាពមានកម្រិតនៃការដាក់ពាក្យស្នើសុំវិធានការការពារបណ្ដោះអាសន្ន

ក្នុងខែឧសភាឆ្នាំ២០១១ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញនូវសារាចរអន្តរក្រសួងមួយដែលផ្ដល់នូវវិធានការការពារបណ្ដោះអាសន្នដល់ជនជាតិដើមភាគតិចដែលកំពុងរង់ចាំប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ពួកគេ។[១២៥] នៅក្នុងពេលសហគមន៍ការអភិវឌ្ឍ ការការពារបែរជាខ្វះទៅវិញនៅក្នុងការអនុវត្តជាក់ស្ដែង ពីព្រោះវិធានការការពារ អនុវត្តចំពោះតែសហគមន៍ ដែលបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប៉ុណ្ណោះ។

---

១២៤ IFAD: កំណត់ត្រាបច្ចេកទេសជាតិស្តីពីបញ្ហាជនជាតិដើមភាគតិច – ព្រះរាជាណាចក្រកម្ពុជា, វិច្ឆិកា ២០១២, ទំព័រ.៣. អាចអាននៅ: https://www.ifad.org/documents/៣៨៧១៤១៧០/៤០២២៤៨៦០/cambodia_ctn.pdf/០២១៤៨១៨៦-៤៨e៩-៤c០៨-bc០៩-b៣៥៦៥da៧០afb

១២៥ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ សារាចរអន្តរក្រសួងស្តីពីវិធានការការពារបណ្ដោះអាសន្នដោយការពារទៅលើដីរបស់ជនជាតិដើមភាគតិចដែលបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីជាសមូហភាពរួចហើយ ខណៈពេលដែលរង់ចាំដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិអនុលោមតាមនីតិវិធីត្រូវបំពេញ ចេញនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១។

វិសាលភាព មានកម្រិតនៃការអនុវត្តជាទូទៅពាក់ព័ន្ធជាពិសេស ចំពោះការឈូសឆាយដី ដែនដី និងធនធានផ្សេងៗ ដែលបានកាន់កាប់តាំងពីដើមមក ក៏ដូចជាការបាត់បង់ទីជម្រកដោយមិនស្ម័គ្រចិត្តរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្រោមហេតុផលការអភិវឌ្ឍសេដ្ឋកិច្ចគឺនៅតែបន្ត និងប៉ះពាល់ដល់ការរស់រានមានជីវិត និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា និងជាបញ្ហាប្រឈមដល់ការគ្រប់គ្រង និងសិទ្ធិរបស់ពួកគេ ទៅលើធនធានធម្មជាតិ។

ដូចដែល បានកត់សម្គាល់ពីខាងដើម យន្តការសិទ្ធិមនុស្សអន្តរជាតិបានគូសបញ្ជាក់ថានៅពេលដែលដីរបស់ជនជាតិដើមភាគតិចត្រូវបានកំណត់ព្រំប្រទល់ បោះបង្គោលព្រំប្រទល់ និងចេញប័ណ្ណកម្មសិទ្ធិរួចហើយ នោះរដ្ឋត្រូវជៀសវាងពីការធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់ការរស់រានតម្លៃការប្រើប្រាស់ ឬការអាស្រ័យផលពីទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រដែលកាន់កាប់ និងប្រើប្រាស់ដោយជនជាតិដែលពាក់ព័ន្ធ។[១២៦] ហេតុដូច្នេះហើយ វិធានការការពារបណ្តោះអាសន្នគួរអនុវត្តនៅពេលណាក៏ដោយ ឲ្យតែជនជាតិដើមភាគតិចមានវត្តមាននៅលើដីនោះ ឬមានការភ្ជាប់ជាសមូហភាព (រក្សាការពារជាសមូហភាព) ទៅលើតំបន់ បានស្នើសុំធ្វើសកម្មភាពអភិវឌ្ឍន៍ ឬការលក់ដី ហើយវិធានការទាំងនេះ គួរអនុវត្តរហូតដល់ដំណើរការកំណត់ព្រំប្រទល់ ការបោះបង្គោលព្រំប្រទល់ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីបញ្ចប់រួចរាល់។

**អនុសាសន៍របស់ការិយាល័យ OHCHR ៖**

អភិបាលខេត្ត គួរចេញវិធានការការពារបណ្តោះអាសន្នដែលអនុវត្តចំពោះសហគមន៍ទាំងអស់ ដែលបានបំពេញចប់សព្វគ្រប់នូវដំណាក់កាលទីមួយនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព ពោលគឺដំណាក់កាលដែលត្រូវបាន ទទួលស្គាល់ដោយក្រសួងអភិវឌ្ឍន៍ជនបទជាសហគមន៍ជនជាតិដើមភាគតិច ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពហើយបានបង្ហាញថាពួកគេមានបំណងដាក់ពាក្យសុំចុះបញ្ជីដីសមូហភាព។

១២៦ IACHR, របាយការណ៍លេខ ៤០/០៤, ករណី ១២.០៥៣, សហគមន៍ជនជាតិដើមភាគតិចMaya នៃស្រុក Toledo (Belize), ថ្ងៃទី១២ តុលា ២០០៤, វគ្គខណ្ឌ ១៩៧ – អនុសាសន៍ ២.

## កង្វះខាតកញ្ចប់ថវិកា

ការដាក់ពាក្យ ស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺជាកិច្ចការដែលចំណាយថវិកាខ្ពស់។ ការវាយតម្លៃដោយអង្គការ GIZ បានកំណត់ទឹកប្រាក់នៅក្នុងចំនួន៧០.០០០ដុល្លារអាមេរិកនៅក្នុងមួយសហគមន៍។[១២៧] ការគណនារបស់អង្គការ GIZ នេះលើកឡើងថាចំណាយសម្រាប់ដំណាក់កាលទី១ និងទី២ អាចមានចំនួនទឹកប្រាក់ប្រមាណជា ២០.០០០ ដុល្លារអាមេរិកនៅក្នុងមួយសហគមន៍។ ចំណាយទាំងនេះ ជាទូទៅ ត្រូវបានរ៉ាប់រងដោយអង្គការម្ចាស់ជំនួយ។ ដោយដកចេញនូវចំណាយប្រតិបត្តិការ ដំណាក់កាលទី២.៥ មានទឹកប្រាក់រហូតដល់ ៨.០០០ ដុល្លារអាមេរិកក្នុងមួយសហគមន៍។ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានទទួលនូវថវិកាចាំបាច់សម្រាប់ដំណាក់កាលទី៣ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទឹកប្រាក់មួយផ្នែកធំដែលមិនសមមាត្រគ្នានៃចំណាយសរុបសម្រាប់ដំណើរការ គឺទឹកប្រាក់ចំណាយ ទៅលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (DSA) - ដែលជាចំនួនទឹកប្រាក់សម្រាប់រ៉ាប់រងចំណាយដែលពាក់ព័ន្ធនឹងការធ្វើដំណើរ ដូចជាទីកន្លែងស្នាក់នៅ ការធ្វើដំណើរ និងអាហារសម្រាប់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅពេលទៅចូលរួមនៅក្នុងការពិភាក្សា ដែលរៀបចំដោយសហគមន៍ដើម្បីអនុវត្តតាមល័ក្ខខ័ណ្ឌតម្រូវសំខាន់ៗ របស់កញ្ចប់ពាក្យស្នើសុំ ដែលសម្រាប់ដាក់ជូនក្រសួង ពាក់ព័ន្ធនីមួយៗ។ ចំណាយលើប្រាក់ឧបត្ថម្ភប្រចាំថ្ងៃនេះ ទីបំផុត ក៏ត្រូវទទួលបន្ទុកដោយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលធ្វើការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ពាក់ព័ន្ធនឹងដំណើរការនេះ តាមរយៈថវិកាផ្ទាល់របស់អង្គការ ឬដៃគូអភិវឌ្ឍន៍ទាំងនោះ។ សំណើរបស់ការិយាល័យ OHCHR ក្នុងការសម្រួលនូវដំណាក់កាលដែលមាននៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) នេះមានគោលដៅកាត់បន្ថយចំនួនបេសកកម្មទៅមូលដ្ឋាន របស់អ្នកតំណាងរដ្ឋាភិបាលពីថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកដែលតម្រូវនោះ ឲ្យបានច្រើនបំផុត។

១២៧ មេរៀនរបស់អង្គការ GIZ ដែលបានរៀនពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់ជនជាតិដើមភាគតិច ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០១៦។ អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការទៅលើការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព បានបង្ហាញជូនការិយាល័យ OHCHR ថា តាមបទពិសោធន៍របស់ពួកគេ ចំណាយសរុបសម្រាប់ដំណាក់កាលទាំងបីមានចំនួនទឹកប្រាក់រហូតដល់ ៦០ ០០០ ដុល្លារអាមេរិក។

ឯកសារនេះ ត្រូវបានតម្រង់ទិស ដោយទស្សនៈមួយដែលយល់ឃើញថាដើម្បីឲ្យផែនការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពមានប្រសិទ្ធភាព ផែនការនោះគួរដំណើរការ និងផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់ដោយរដ្ឋខ្លួនឯង។[១២៨] ពឹងផ្អែកលើការវិភាជកញ្ចប់ថវិកាសម្រាប់ការចុះបញ្ជីដីសមូហភាពនេះគឺ វាមិនបានឆ្លុះបញ្ចាំងពីឆន្ទៈមុះមុតដើម្បីធានាថា រាល់ជនជាតិដើមភាគតិចនៅកម្ពុជាអាចទទួលបានការចុះបញ្ជីដីសមូហភាពដោយស្មើភាពដែលស្របជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលការណ៍នៃការមិនទុកនរណាម្នាក់ចោលនោះទេ។

### អនុសាសន៍របស់ការិយាល័យ OHCHR៖

រដ្ឋាភិបាលគួរបន្ថែមកញ្ចប់ថវិកាសម្រាប់ដំណើរការចុះបញ្ជីដីសមូហភាពប្រចាំឆ្នាំ ឬបន្ថែមសហគមន៍ច្រើនជាងនេះដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ។

## ការយល់ដឹង និងសមត្ថភាពមានកម្រិតក្នុង ចំណោមជនជាតិដើមភាគតិច អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រជនជាតិដើម និងអាជ្ញាធរមូលដ្ឋានអំពីច្បាប់ភូមិបាលឆ្នាំ ២០០១

ភាគីពាក់ព័ន្ធជាច្រើន – រួមមានជនជាតិដើមភាគតិច និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការគាំទ្រ ក៏ដូចជាអ្នកតំណាងរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ – ហាក់ដូចជាភាន់ច្រឡំទៅលើជំហាននៃដំណើរការ និងល័ក្ខខ័ណ្ឌតម្រូវ ដែលគួរអនុវត្តតាមសម្រាប់ចុះបញ្ជីដីសមូហភាពរបស់ជនជាតិដើមភាគតិច ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ។ ផ្នែកមួយនៃការភាន់ច្រឡំនេះ គឺដោយសារឯកសារ គតិយុត្តិ និងគោលនយោបាយវាច្រើន (ច្បាប់អនុក្រឹត្យ ប្រកាស សារាចរអន្តរក្រសួង និងសេចក្តីណែនាំគោលនយោបាយ)។ ឧទហរណ៍ ពាក់ព័ន្ធនឹងដំណាក់កាលចុងក្រោយនៃដំណើរការ–ការ

[១២៨] កង្វះខាតកញ្ចប់ថវិកានេះត្រូវបានលើកឡើងជាមួយការិយាល័យOHCHR នៅគ្រប់កិច្ចប្រជុំ

ផ្សៀងផ្ទាត់ការគូរផែនទីបឋម សៀវភៅបណ្តុះបណ្តាលស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅក្នុងឆ្នាំ ២០១២) បានរៀបរាប់ឯកសារគតិយុត្តិ និងឯកសារគោលនយោបាយ រហូតដល់ចំនួនប្រាំបួនឯកសារ បន្ថែមពីលើច្បាប់ភូមិបាល ហើយភាគច្រើននៃឯកសារទាំងនោះ គឺមិនអាចស្វែងរកបានជាសាធារណៈ ឬមានភាពលំបាកខ្លាំងក្នុងការស្វែងរកប្រភពវា (ដើម្បីផ្តល់ឯកសារបាន)។[១២៩]

សហគមន៍ជនជាតិដើមភាគតិចជាទូទៅខ្វះចំណេះដឹងដើម្បីចូលរួមនៅក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពប្រកបដោយប្រសិទ្ធភាព។ ពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលគាំទ្រ ក៏គួរឲ្យកត់សម្គាល់ផងដែរថា សមត្ថភាពរបស់ពួកគេហាក់ដូចជាទាប ជាពិសេស ពាក់ព័ន្ធនឹងជំនាញបច្ចេកទេសដូចជាការប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ដី និងធ្វើផែនទីបឋមតាមឱ្យដីថល។[១៣០] អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក៏ជួបប្រទះនូវអត្រាបុគ្គលិកចេញ-ចូលខ្ពស់ផងដែរ (បុគ្គលិកលាឈប់ ហើយរើសចូលថ្មី) ដែលនេះនឹងធ្វើឲ្យប៉ះពាល់បន្ថែមទៀតដល់ចីរភាពនៃគំនិតផ្តួចផ្តើមកសាងសមត្ថភាព។[១៣១]

ចំណុចខ្សោយក្នុងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាព ក៏ទំនងជាដោយសារការខ្វះការប្តេជ្ញាចិត្តរបស់អាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិ និងអាជ្ញាធរចុះបញ្ជី រួមជាមួយនឹងការយល់ដឹងមានកម្រិតទៅលើច្បាប់ប្រទេសដែលពាក់ព័ន្ធជាមួយនឹងជនជាតិដើមភាគតិច។ កង្វះខាតមួយទៀតនោះ គឺខ្វះផែនការរយៈពេលវែងសម្រាប់កសាងសមត្ថភាពចាំបាច់របស់អាជ្ញាធរថ្នាក់ក្រោមជាតិ ស្តីពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព និងកាតព្វកិច្ចរបស់ពួកគេពាក់ព័ន្ធនឹងការងារនេះ។

នៅក្នុងសិក្ខាសាលាកសាងសមត្ថភាពថ្នាក់តំបន់ចំនួនបួន ដែលបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងការិយាល័យ OHCHR នៅក្នុងខែតុលា ឆ្នាំ ២០១៦ និងឆ្នាំ២០១៧

១២៩ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖ សៀវភៅបណ្តុះបណ្តាលស្តីពីការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ឆ្នាំ ២០១២, ទំព័រ៨។

១៣០ អង្គការ GIZ មេរៀនដែលបានរៀនទី១២។

១៣១ ប្រភពដដែល។

(នៅក្រុងព្រះសីហនុ ថ្ងៃទី២៤-២៥ ខែ តុលា ២០១៦ នៅខេត្តស្ទឹងត្រែងថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១៦ ១៧-១៩ តុលា ២០១៧ នៅខេត្តកំពង់ធំ និង ១៤-១៦ វិច្ឆិកា ២០១៧ នៅខេត្តពោធិ៍សាត់) មានការព្រមព្រៀងថា ការិយាល័យ OHCHR ដោយសហការជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវធ្វើការរួមគ្នាឆ្ពោះទៅរកការរៀបចំជាសៀវភៅបណ្ដុះបណ្ដាលមួយ ដែលតម្រង់ទិសសកម្មភាពច្បាស់លាស់ទៅលើដំណើរការនៃការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព និងដោយមានយោងច្បាស់លាស់ទៅលើមូលដ្ឋានគតិយុត្តិ និង/ឬគោលនយោបាយនៃដំណាក់កាលនីមួយៗ។ នៅខែធ្នូ ២០១៨ ការិយាល័យ OHCHR បានរៀបចំនូវសៀវភៅណែនាំការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិលដែលគាំទ្រជនជាតិដើមភាគតិច ដោយសហការជាមួយនឹងក្រសួងពាក់ព័ន្ធសំខាន់ៗចំនួនបី ដែលសៀវភៅនេះ នឹងដាក់បញ្ចូលនូវទិដ្ឋភាពទូទៅនៃដំណើរការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព (ដោយដាក់បញ្ចូលដំណាក់កាលទាំងបី) និងប្រមូលចងក្រងនូវរាល់ឯកសារ និងទម្រង់លិខិតដែលតម្រូវឲ្យ មានជាចាំបាច់ ទាំងអស់របស់ក្រសួងនីមួយៗ។[១៣២]

**អនុសាសន៍របស់ការិយាល័យ OHCHR៖**

រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាបង្កើតផែនការ រយៈពេលវែងសម្រាប់ការបណ្ដុះបណ្ដាលកសាង សមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិស្ដីពីដំណើរការ ចុះបញ្ជីដីសមូហភាព និងតួនាទីរបស់ពួកគេក្នុងការងារនេះ។

## កិច្ចសហប្រតិបត្តិការមានកម្រិតរវាងក្រសួងពាក់ព័ន្ធ

ដោយសារដំណើរការ (ផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព) ពេលខ្លះពាក់ព័ន្ធជាមួយនឹងក្រសួងចំនួនបី និងពេលខ្លះទៀតអាចពាក់ព័ន្ធជាមួយនឹងក្រសួងចំនួនបួន ដូច្នេះការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច តម្រូវឲ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធរួមគ្នា រវាងក្រសួងទាំងនោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១៣២ សៀវភៅណែនាំស្ដីពីការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីជានីតិបុគ្គល និងដំណើរការចុះបញ្ជីដីសមូហភាពនៅ កម្ពុជា។ សហការផលិតដោយ ការិយាល័យ OHCHR ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ខែមករា ឆ្នាំ២០១៩។ អាចរកអានបាននៅ៖https://cambodia.ohchr.org/sites/default/files/Promotional-materials-soft/CLT%២0Manual-Khmer.pdf

បច្ចុប្បន្ននេះ មិនមានកិច្ចសហប្រតិបត្តិការផ្ទៃកបច្ចេកទេសរវាងក្រសួងទាំងនោះឡើយ។

### អនុសាសន៍របស់ការិយាល័យ OHCHR៖

ជាដំណាក់កាលដំបូង ក្រុមការងារបច្ចេកទេស ដែលមានដូចជាអ្នកតំណាងថ្នាក់ក្រសួង មកពីក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គួរត្រូវបានបង្កើតឡើង និងជួបប្រជុំជាទៀងទាត់ដើម្បីពិភាក្សាអំពីស្ថានភាពនៃការស្នើសុំដីធ្លីដែលមិនទាន់ឆ្លើយតបនៅឡើយ និងស្វែងរកដំណោះស្រាយឆ្លើយតបទៅ នឹងឧបសគ្គចំពោះករណីនីមួយៗ។

## គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច

នៅក្នុងឆ្នាំ២០០៩រដ្ឋាភិបាលកម្ពុជាបានអនុម័តនូវគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (ពីពេលនេះប្រើថាគោលនយោបាយជាតិ) ដែលទទួលស្គាល់នូវការផ្សារភ្ជាប់ជាពិសេស ដែលជនជាតិដើមភាគតិចមានជាមួយនឹងដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ ហើយក៏បានកត់សម្គាល់នូវបញ្ហាប្រឈមមួយចំនួន ដែលពួកគេជួបប្រទះផងដែរ ពាក់ព័ន្ធទៅនឹងការទទួលបានសេវាមូលដ្ឋាន ដែលមានដូចជាការអប់រំ និងការថែទាំសុខភាព។ រីតតែសំខាន់ទៀតគោលនយោបាយជាតិនេះក៏ខិតខំធានាផងដែរថា វប្បធម៌របស់ជនជាតិដើមភាគតិចនៅទូទាំងប្រទេស នឹងត្រូវបានការពារ ហើយថាល័ក្ខខ័ណ្ឌនៃការរស់នៅរបស់ពួកគេត្រូវបានទទួលយកដូចៗគ្នានៅគ្រប់ វិស័យទាំងអស់។[១៣៣]

កាន់តែច្បាស់លាស់ទៀតនោះ គោលនយោបាយក៏បានកំណត់នូវគោលដៅរបស់ខ្លួនថា ជនជាតិដើមភាគតិចនឹងទទួលបានជីវភាពរស់នៅ ផុតពីកង្វះស្បៀងអាហារ និងភាពក្រីក្រធ្ងន់ធ្ងរបំផុត និងទទួលបានការអប់រំចំនួនប្រាំបួនឆ្នាំយ៉ាងតិច បន្ថែមពីលើនោះមានការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈសមស្រប ព្រមទាំងសេវាថែទាំសុខភាពល្អ ហើយវប្បធម៌របស់ពួកគេ នឹងត្រូវបានថែរក្សា

១៣៣ គោលនយោបាយដីធ្លីស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិចរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអនុម័តដោយគណៈរដ្ឋមន្ត្រី នៅក្នុងសម័យប្រជុំពេញអង្គរបស់ខ្លួន កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៩, ១ បញ្ជាក់បន្ថែម។

និងការពារ។[១៣៤] គោលនយោបាយនេះបានកត់សម្គាល់ទៀតថា ការចូលរួម និងការចូលពាក់ព័ន្ធរបស់សហគមន៍ជនជាតិដើមភាគតិច គឺចាំបាច់ណាស់សម្រាប់ភាពជោគជ័យរបស់វា។[១៣៥]

ដើម្បីសម្រេចនូវគោលបំណងទាំងនេះ គោលនយោបាយជាតិ បានគូសបញ្ជាក់អំពីគោលដៅរបស់ខ្លួន ទៅលើវិស័យតាមប្រធានបទចំនួនដប់-ដែលមានដូចជា វិស័យវប្បធម៌ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធយុត្តិធម៌ទេសចរណ៍និងឧស្សាហកម្មរ៉ែនិងថាមពល-ដែលជាប់ទាក់ទងជាមួយនឹងក្រសួងពាក់ព័ន្ធនានា។ ការិយាល័យ OHCHR កត់សម្គាល់ឃើញថា គ្មានការកំណត់ច្បាស់លាស់ថាតើក្រសួងណាខ្លះ "ពាក់ព័ន្ធ" ជាមួយនឹងវិស័យនីមួយៗឡើយ។ ចំណុចនេះបង្កឲ្យមានផលវិបាកអាក្រក់ ដែលក្រសួងនៅក្នុងវិស័យទាំងនោះ មិនបានយល់ដឹងច្បាស់លាស់អំពីអាណត្តិ (មុខងារ និងកាតព្វកិច្ច) របស់ខ្លួននិងថាតើពួកគេត្រូវធ្វើអ្វីខ្លះ ដើម្បីធានានូវការអនុវត្តគោលនយោបាយជាតិហើយជាលទ្ធផល វាធ្វើឲ្យរាំងស្ទះដល់ការអនុវត្តគោលនយោបាយប្រកបដោយភាពស៊ីសង្វាក់គ្នាលើគ្រប់វិស័យ។

ពាក់ព័ន្ធនឹងវិស័យដីធ្លី គោលនយោបាយជាតិ ក៏បានលើកឡើងថាច្បាប់ និងឯកសារបទដ្ឋានគតិយុត្តិសម្រាប់ការពារកម្មសិទ្ធិដីសមូហភាព និងការអនុវត្តផែនការប្រើប្រាស់ដី គួរត្រូវបានផ្សព្វផ្សាយនៅក្នុងរូបភាព និងទម្រង់ដែលអាចឲ្យ (សមាជិកទាំងអស់) នៃជនជាតិដើមភាគតិចយល់បាន។[១៣៦] គោលនយោបាយនេះ ក៏បានបញ្ជាក់ឡើងវិញអំពីមាត្រាដែលការពារ (ជនជាតិដើម) ដែលមានចែងនៅក្នុងច្បាប់ភូមិបាល ដោយកត់សម្គាល់ថា ដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលប្រើប្រាស់រួមគ្នាមិនគួរលក់ ឬផ្ទេរទៅឲ្យបុគ្គលឯកជន ឬក្រុមណាមួយក្រៅសហគមន៍ឡើយ។[១៣៧]

ចំពោះការអនុវត្តគោលនយោបាយជាតិ ការិយាល័យ OHCHR កត់សម្គាល់អំពីអវត្តមាននៃការសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ

១៣៤ ប្រកពដដែល មាត្រា ២។
១៣៥ ប្រកពដដែល មាត្រា ១៣
១៣៦ ប្រភពដដែល មាត្រា ៨
១៣៧ ប្រភពដដែល សូមមើលច្បាប់ភូមិបាល មាត្រា ២៨។

និងគ្មានការតាមដានជាប្រចាំទៅលើការអនុវត្ត តាំងពីការអនុម័តនាឆ្នាំ២០០៩មក។ជាងនេះទៅទៀត ពុំមានកញ្ចប់ថវិកាសម្រាប់អនុវត្តគោលនយោបាយនេះទេ។

នៅខែឧសភាឆ្នាំ២០១៩ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើត "ក្រុមការងារបច្ចេកទេសដើម្បី អភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច" (សេចក្ដីសំរេចលេខ ១៤៨/១៩ ចុះថ្ងៃទី ០៦ ឧសភា ២០១៩)[១៣៨] ដែលត្រូវបានសំរេចនិរាករណ៍វិញនៅដើមឆ្នាំ ២០២០ (សេចក្ដីសំរេចលេខ០៤១ចុះថ្ងៃទី០៤កុម្ភៈ២០២០) ដោយពុំមានផ្ដល់ហេតុផលផ្លូវការណាមួយឡើយ។

សេចក្ដីសំរេចនិរាករណ៍នេះ គឺផ្ទុយពីការប្ដេជ្ញារបស់កម្ពុជានៅឆាកអន្តរជាតិ ជាឧទាហរណ៍ ឯកសារលទ្ធផលនៃវេទិកាពិភពលោកស្ដីពីជនជាតិដើមភាគតិចដែលត្រូវបានអនុម័តអនាមឹកដោយរដ្ឋភាគីនៃអង្គការសហប្រជាជាតិ រួមទាំងកម្ពុជាផង នៅខែកញ្ញាឆ្នាំ២០១៤។[១៣៩] នៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នេះ រដ្ឋភាគីបានបញ្ជាក់អំពីការប្ដេជ្ញារបស់ពួកគេក្នុងការអនុវត្តសេចក្ដីប្រកាស របស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច និងសហការជាមួយជនជាតិដើមភាគតិចដើម្បីអភិវឌ្ឍ និងអនុវត្តផែនការជាតិ យុទ្ធសាស្ត្រ ឬវិធានការដទៃដើម្បីទទួលបានលទ្ធផលនៅពេលបញ្ចប់សេចក្ដីប្រកាស។[១៤០]

### អនុសាសន៍របស់ការិយាល័យ OHCHR៖

ដើម្បីធានាការអនុវត្តគោលនយោបាយគោលដៅរបស់វា គឺត្រូវចាត់តាំងក្រសួងជាក់លាក់ ជាមួយនឹងកញ្ចប់ថវិកា។ ត្រូវកំណត់សូចនាករ និងចំណុចគោល (benchmark) សម្រាប់ការតាមដានការអនុវត្ត។ ដើម្បីធានាថា សម្លេងរបស់ជនជាតិដើមភាគតិច ត្រូវបានស្ដាប់នៅថ្នាក់ជាតិ ការិយាល័យ OHCHR ផ្ដល់អនុសាសន៍ថា គួរបង្កើតយន្តការ ឬវេទិកាពិគ្រោះយោបល់ និងសម្របសម្រួលថ្នាក់ជាតិថ្មីមួយ ដែល

១៣៨ បន្ថែមពីលើក្រុមការងារលេខាធិការដ្ឋានដែលមកពីនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមការងារបច្ចេកទេសនេះរួមមានតំណាង៧៩រូបមកពីក្រសួងពាក់ព័ន្ធចំនួន២០ តំណាងខេត្តដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ និងអង្គការសង្គមស៊ីវិល/ដៃគូ អភិវឌ្ឍន៍ដែលធ្វើការទៅលើបញ្ហាជនជាតិដើមភាគតិចចំនួន៦ស្ថាប័ន។

១៣៩ A/RES/៦៩/២ (២០១៤).

១៤០ A/RES/៦៩/២, វគ្គខណ្ឌ ៨។ ការងាររបស់ប្រទេសនានាក្នុងការបង្កើតផែនការសកម្មភាពបន្ត រួមទាំងកាណាដា និង El-Salvador, ដែលអាចប្រើជាគម្រូនៅក្នុងករណីនេះបាន។

អនុញ្ញាតឲ្យជនជាតិដើមភាគតិចអាចលើក និងពិគ្រោះយោបល់ពីបញ្ហាដែលប៉ះពាល់ ដល់ពួកគេបាន។

## អវត្តមាននៃស្រទាប់យេនឌ័រ

ខណៈដែលគោលនយោបាយជាតិស្តីពីជនជាតិដើមភាគតិចបានកំណត់គោលដៅធំធេង និងទិសដៅក្នុងវិស័យផ្សេងៗនោះ គឺគោលនយោបាយមិនបានពិចារណាដាក់លាក់ទៅលើស្ថានភាពរបស់ស្ត្រីជនជាតិដើមភាគតិច និងការរើសអើងដែលពួកគេប្រឈមមុខទាំងនៅក្នុង សហគមន៍របស់ពួកគេផ្ទាល់ និងនៅក្នុងសង្គមជារួម។ អវត្តមាននៃការវិភាគវិនិច្ឆ័យ និងវិធានការធានាសមភាពយេនឌ័រ និងសង្គមរបស់ស្ត្រី សេដ្ឋកិច្ច និងការលើកម្ពស់ផ្នែកនយោបាយ ត្រូវបានរកឃើញជាទូទៅក្នុងគោលនយោបាយជាតិពាក់ព័ន្ធជនជាតិដើមភាគតិចដែលការិយាល័យOHCHR បានអាន។

### អនុសាសន៍របស់ការិយាល័យ OHCHR៖

ដើម្បីកែសម្រួល និងធានាថាមានការយកចិត្តទុកដាក់កាន់តែខ្ពស់ចំពោះស្ត្រី និងកុមារីជនជាតិដើមភាគតិច ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រសួងកិច្ចការនារី ដោយមានការគាំទ្រពីស្ថាប័ន សហប្រជាជាតិ ត្រូវបង្កើតផែនការសកម្មភាព ដែលអាចដោះស្រាយតម្រូវការរបស់ស្ត្រីជនជាតិដើមភាគតិចជាពិសេស។ ជាងនេះទៅទៀត គួរពិចារណាបញ្ចូលបញ្ហាយេនឌ័រទៅក្នុងច្បាប់ និងគោលនយោបាយនាពេលអនាគត។

# ឧបសម្ព័ន្ធ

លេខយោង៖ OHHR/220/20 រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរព!

តំណាងឲ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR) ខ្ញុំ សូមសរសេរលិខិតនេះ ជម្រាបជូនឯកឧត្តមទាក់ទងនឹងយុទ្ធនាការផ្សព្វផ្សាយស្តីពីតម្រូវការសម្រួលឲ្យសាមញ្ញនូវដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) ក្នុងប្រទេសកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំ សូមថ្លែងអំណរគុណចំពោះឯកឧត្តម ដែលបានចាត់តាំង បណ្ឌិត ថុល ឌីណា ជាជនបង្គោលក្នុងការងារសហការជាមួយការិយាល័យ OHCHR លើយុទ្ធនាការនេះ តាមរយៈលិខិតផ្ទៃក្នុងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ និងការគូសបញ្ជាក់ ដូចដែលបានយល់ព្រមពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី នាថ្ងៃទី២៦ សីហា ឆ្នាំ២០២០។

ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិចលើដីសមូហភាព ការសម្រួលឲ្យសាមញ្ញលើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺជាមធ្យោបាយមួយដែលជម្រុញឆ្ពោះទៅដល់កិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យរបស់ខ្ញុំ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងឯកឧត្តម បានកំពុងបង្កើតចេញនូវឯកសារពិភាក្សាមួយ ដែលមានចំណងជើង "ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅកម្ពុជា-តើជាករណីសម្រាប់ធ្វើកំណែទម្រង់មែនទេ?" ។ ឯកសារពិភាក្សានេះ កំពុងត្រូវបានធ្វើបញ្ចប់ហើយ នៅបច្ចុប្បន្ននេះ និងត្រៀមរៀបចំបោះពុម្ពផ្សព្វផ្សាយនាប៉ុន្មានខែខាងមុខនេះ។ នៅក្នុងស្មារតីសហប្រតិបត្តិការ និងកិច្ចសហការរវាងការិយាល័យ OHCHR និងក្រសួងឯកឧត្តម ខ្ញុំសូមការអនុញ្ញាតយល់ព្រមពីឯកឧត្តមដើម្បីដាក់បង្ហាញនិមិត្តសញ្ញាតំណាង (Logo) ក្រសួងរបស់ឯកឧត្តមនៅលើឯកសារបោះពុម្ពនេះ។ ខ្ញុំបានភ្ជាប់នូវសេចក្តីព្រាងចុងក្រោយនៃឯកសារពិភាក្សានេះ សម្រាប់ជាឯកសារយោងជូនឯកឧត្តម។

ខ្ញុំ សូមអះអាងជាថ្មីថា ការិយាល័យ OHCHR ប្រចាំនៅកម្ពុជា ប្តេជ្ញាក្នុងការបន្តឃ្លាំមើល លើកស្ទួយ និង ការអនុវត្តសិទ្ធិជនជាតិដើមភាគតិចនៅក្នុងប្រទេស រួមមានសិទ្ធិដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ ព្រមទាំងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបំពេញនូវកាតព្វកិច្ចរបស់ខ្លួនដែលស្ថិតក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលខ្លួនបានផ្តល់សច្ចាប័ន។

ជំនួយការរបស់ខ្ញុំ លោក ទូច ហួន នឹងទំនាក់ទំនងជាមួយការិយាល័យរបស់ឯកឧត្តម ឬក៏ជំនួយការរបស់ឯកឧត្តម អាចទាក់ទងមកគាត់បានតាមរយៈទូរស័ព្ទលេខ ០១២ ៤៧៦ ៤៩៣ ឬ អ៊ីម៉ែល htouch@ohchr.org ដើម្បីផ្តល់ការបញ្ជាក់ពីការយល់ព្រមរបស់ក្រសួងឯកឧត្តមលើការដាក់បង្ហាញនូវនិមិត្តសញ្ញាតំណាង (Logo)នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅលើឯកសារពិភាក្សានេះ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ប្រាឌីព វ៉ាគ្លេ
តំណាងការិយាល័យស្តីទី

គោរពជូន៖ **ឯកឧត្តម ជា សុផារ៉ា**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគារលេខ ៧៧១- ៧៧៣ មហាវិថីព្រះមុន្នីវង្ស ភ្នំពេញ

លេខយោង៖ OHCHR/221/20 ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

សម្តេចក្រឡាហោមជាទីគោរពរាប់អាន!

តំណាងឲ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR) ខ្ញុំ សូមសរសេរលិខិតនេះ ជម្រាបជូនសម្តេចក្រឡាហោមទាក់ទងនឹងយុទ្ធនាការផ្សព្វផ្សាយស្តីពីតម្រូវការសម្រួលឲ្យសាមញ្ញនូវដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) ក្នុងប្រទេសកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំ សូមថ្លែងអំណរគុណចំពោះសម្តេចក្រឡាហោម ដែលបានចាត់តាំង លោក អាំ វាសនា អនុប្រធាននាយកដ្ឋានកិច្ចការគណៈបក្សនយោបាយ និងសមាគម នៃក្រសួងមហាផ្ទៃ (MoI) ជាជនបង្គោលក្នុងការងារសហការជាមួយការិយាល័យ OHCHR លើយុទ្ធនាការនេះ។

ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិចលើដីសមូហភាព ការសម្រួលឲ្យសាមញ្ញលើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺជាមធ្យោបាយមួយដែលជម្រុញឆ្ពោះទៅដល់កិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យរបស់ខ្ញុំ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងរបស់សម្តេចក្រឡាហោម បានកំពុងបង្កើតចេញនូវឯកសារពិភាក្សាមួយ ដែលមានចំណងជើង "ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅកម្ពុជា-តើជាករណីសម្រាប់ធ្វើកំណែទម្រង់មែនទេ?" ។ ឯកសារពិភាក្សានេះ កំពុងត្រូវបានធ្វើបញ្ចប់ហើយ នៅបច្ចុប្បន្ននេះ និងត្រៀមរៀបចំបោះពុម្ពផ្សព្វផ្សាយនាប៉ុន្មានខែខាងមុខនេះ។ នៅក្នុងស្មារតីសហប្រតិបត្តិការ និងកិច្ចសហការរវាងការិយាល័យ OHCHR និងក្រសួងរបស់សម្តេច ខ្ញុំសូមការអនុញ្ញាតយល់ព្រមពីសម្តេចដើម្បីដាក់បង្ហាញនិមិត្តសញ្ញាតំណាង (Logo) ក្រសួងរបស់សម្តេចនៅលើឯកសារបោះពុម្ពនេះ។ ខ្ញុំបានភ្ជាប់នូវសេចក្តីព្រាងចុងក្រោយនៃឯកសារពិភាក្សានេះ សម្រាប់ជាឯកសារយោងជូនសម្តេច។

ខ្ញុំ សូមអះអាងជាថ្មីថា ការិយាល័យ OHCHR ប្រចាំនៅកម្ពុជា ប្តេជ្ញាក្នុងការបន្តឃ្លាំមើល លើកស្ទួយ និង ការអនុវត្តសិទ្ធិជនជាតិដើមភាគតិចនៅក្នុងប្រទេស រួមមានសិទ្ធិដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ ព្រមទាំងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបំពេញនូវកាតព្វកិច្ចរបស់ខ្លួនដែលស្ថិតក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលខ្លួនបានផ្តល់សច្ចាប័ន។

ជំនួយការរបស់ខ្ញុំ លោក ទូច ហួន នឹងទំនាក់ទំនងជាមួយការិយាល័យរបស់សម្តេច ឬក៏ជំនួយការរបស់សម្តេច អាចទាក់ទងមកគាត់បានតាមរយៈទូរស័ព្ទលេខ ០១២ ៤៧៦ ៤៩៣ ឬ អ៊ីម៉ែល htouch@ohchr.org ដើម្បីផ្តល់ការបញ្ជាក់ពីការយល់ព្រមនៃក្រសួងសម្តេចលើការដាក់បង្ហាញនូវនិមិត្តសញ្ញាតំណាង (Logo)នៃក្រសួងមហាផ្ទៃនៅលើឯកសារពិភាក្សានេះ។

សូមសម្តេចក្រឡាហោម មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ប្រាឌីព វ៉ាគ្លេ
តំណាងការិយាល័យស្តីទី

គោរពជូន៖
**សម្តេចក្រឡាហោម ស ខេង**
ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
អគារលេខ ២៧៥ មហាវិថីព្រះនរោត្តម ភ្នំពេញ

លេខយោង៖ OHCHR/222/20

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

ឯកឧត្តមជាទីគោរពរាប់អាន!

តំណាងឲ្យការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR) ខ្ញុំ សូមសរសេរលិខិតនេះ ជម្រាបជូនឯកឧត្តមទាក់ទងនឹងយុទ្ធនាការផ្សព្វផ្សាយស្តីពីតម្រូវការសម្រួលឲ្យសាមញ្ញនូវដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព (CLT) ក្នុងប្រទេសកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំ សូមថ្លែងអំណរគុណចំពោះឯកឧត្តមសម្រាប់ការយល់ព្រមក្នុងការងារសហការជាមួយការិយាល័យ OHCHR លើយុទ្ធនាការនេះ ដែលតាមរយៈឯកឧត្តម សួន សេរីរដ្ឋា រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទនៅក្នុងកិច្ចប្រជុំនាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០។

ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីការពារសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិចលើដីសមូហភាព ការសម្រួលឲ្យសាមញ្ញលើដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គឺជាមធ្យោបាយមួយដែលជម្រុញឆ្ពោះទៅដល់កិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យរបស់ខ្ញុំ ក្នុងកិច្ចពិគ្រោះយោបល់ជាមួយក្រសួងឯកឧត្តម បានកំពុងបង្កើតចេញនូវឯកសារពិភាក្សាមួយ ដែលមានចំណងជើង "ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅកម្ពុជា-តើជាករណីសម្រាប់ធ្វើកំណែទម្រង់មែនទេ?" ។ ឯកសារពិភាក្សានេះ កំពុងត្រូវបានធ្វើបញ្ចប់ហើយ នៅបច្ចុប្បន្ននេះ និងត្រៀមរៀបចំបោះពុម្ពផ្សព្វផ្សាយនាប៉ុន្មានខែខាងមុខនេះ។ នៅក្នុងស្មារតីសហប្រតិបត្តិការ និងកិច្ចសហការរវាងការិយាល័យ OHCHR និងក្រសួងឯកឧត្តម ខ្ញុំសូមការអនុញ្ញាតយល់ព្រមពីឯកឧត្តមដើម្បីដាក់បង្ហាញនិមិត្តសញ្ញាតំណាង (Logo) ក្រសួងរបស់ឯកឧត្តមនៅលើឯកសារបោះពុម្ពនេះ។ ខ្ញុំបានភ្ជាប់នូវសេចក្តីព្រាងចុងក្រោយនៃឯកសារពិភាក្សានេះ សម្រាប់ជាឯកសារយោងជូនឯកឧត្តម។

ខ្ញុំ សូមអះអាងជាថ្មីថា ការិយាល័យ OHCHR ប្រចាំនៅកម្ពុជា ប្តេជ្ញាក្នុងការបន្តឃ្លាំមើល លើកស្ទួយ និង ការអនុវត្តសិទ្ធិជនជាតិដើមភាគតិចនៅក្នុងប្រទេស រួមមានសិទ្ធិដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ ព្រមទាំងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបំពេញនូវកាតព្វកិច្ចរបស់ខ្លួនដែលស្ថិតក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សនានាដែលខ្លួនបានផ្តល់សច្ចាប័ន។

ជំនួយការរបស់ខ្ញុំ លោក ទូច ហួន នឹងទំនាក់ទំនងជាមួយការិយាល័យរបស់ឯកឧត្តម ឬក៏ជំនួយការរបស់ឯកឧត្តម អាចទាក់ទងមកគាត់បានតាមរយៈទូរស័ព្ទលេខ ០១២ ៤៧៦ ៤៩៣ ឬ អ៊ីម៉ែល htouch@ohchr.org ដើម្បីផ្តល់ការបញ្ជាក់ពីការយល់ព្រមនៃក្រសួងឯកឧត្តមលើការដាក់បង្ហាញនូវនិមិត្តសញ្ញាតំណាង (Logo)នៃក្រសួងអភិវឌ្ឍន៍ជនបទនៅលើឯកសារពិភាក្សានេះ។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ប្រាឌីព វ៉ាគ្គេ
តំណាងការិយាល័យស្តីទី

<u>គោរពជូន៖</u>

**ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន**
រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ
មហាវិថីសហព័ន្ធរុស្ស៊ី កែងផ្លូវមហាវិថីសាធារណរដ្ឋឆែក (១៦៩) ភ្នំពេញ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា


ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

ខែកញ្ញា ឆ្នាំ២០២០



@OHCHRCambodia
@OHCHR_Cambodia
UNCOHCHR
https://cambodia.ohchr.org
cambodia@ohchr.org